ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ខួបលើកទី១០០នៃទិវានារីអន្តរជាតិ : ទីវនារីខ្មែរ
- សាសនាអ៊ីស្លាមកំពុងមានការផ្លាស់ប្តូរនៅកម្ពុជា

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៣៦ ខែមេសា ឆ្នាំ២០១១

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៣៦ ខែមេសា ឆ្នាំ២០១១


## មាតិកា


◆ខួបលើកទី១០០នៃទិវានារីអន្តរជាតិ ៖ វីរនារីខ្មែរ ............................១

**ផ្នែកឯកសារ**

◆ភាពភ័យខ្លាចនៅក្នុងជីវិតកុមារភាព.................................................៣

◆ម៉ាឡៃ ៖ ដប់ប្រាំឆ្នាំក្រោយសមាហរណកម្ម ....................................៥

◆សិល្បៈការិនីមជ្ឈិមខ្មែរក្រហម .......................................................៧

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆កុមារភាពរបស់ ប៊ុត កន.......................................................១១

◆"ខ្ញុំអាណិតម្តាយខ្ញុំណាស់" .......................................................១៤

◆សាសនាអ៊ីស្លាមកំពុងមានការផ្លាស់ប្តូរនៅកម្ពុជា ..........................២១

**ផ្នែកច្បាប់**

◆អាពាហ៍ពិពាហ៍ដោយបង្ខំជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ...............២៥

◆ការស្វែងរកការពិតតាមដំណើរការនិតីវិធីមិនលម្អៀង....................៣៦

**វេទិកាពិភាក្សាសាធារណៈ**

◆សាលក្រម ឌុច មានលក្ខណៈស្រាលពេក .................................៤៣

◆ការចងក្រងប្រវត្តិសាស្ត្រកម្ពុជា ..........................................៤៤

◆ដំណើរស្វែងយល់ពីអំពើប្រល័យពូជសាសន៍..............................៥៣

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆កេរដំណែលនៃសង្គ្រាម ......................................................៥៧




ពិធីដង្ហែនំនៃបុណ្យម៉ាឡុត នៅស្រុកកំពង់ត្រឡាច ឆ្នាំ២០១១


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



**ស្នេរលេខនេះ ៖** ផេង ពង្សរ៉ាស៊ី, អេង កុកថាយ, ណាតាលី អេនដឺសុន, សែន វិចិត្រ, សារ៉ា ចូនឌីកឃិន, សើ សាយ្យាណា, ជែន អានហ៊ីល, ជីណា ខតថេស, **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** គាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា **អ្នកបកប្រែ ៖** ជា ផល្លា **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ជំនួយការនិពន្ធនាយក ៖** ញាណ សុជាតិ **ក្រាហ្វិកកុំព្យូទ័រ ៖** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ ៖** ម៉ម សុផាត Email: dccam@online.com.kh, Homepage: www.dccam.org

# ខួបលើកទី១០០នៃទិវានារីអន្តរជាតិ ៖ វីរនារីខ្មែរ

ស្ត្រីខ្មែរទាំងអស់ដែលជាជនរងគ្រោះ និងរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យគឺជាវីរនារីខ្មែរ ។ អ្នកដែលបានរស់រានមានជីវិតពីរបបខ្មែរក្រហមប្រមាណចិតសិបភាគរយគឺជាស្ត្រី ភាគច្រើនជាស្ត្រីមេម៉ាយ ។ ក្រោយរបបកម្ពុជាប្រជាធិបតេយ្យដួលរលំក្នុងឆ្នាំ១៩៧៩ ស្ត្រីគឺជាកម្លាំងស្នូលក្នុងការកសាងមាតុភូមិកម្ពុជានិងជាអ្នកស្តារសេដ្ឋកិច្ចជាតិឡើងវិញក្នុងអំឡុងទសវត្សរ៍៨០ និង៩០ ពេលដែលប្រទេសជាតិកំពុងប្រឈមមុខនឹងសង្គ្រាមស៊ីវិលជាមួយនឹងក្រុមទ័ព្ទាមខ្មែរក្រហម ដែលជាហេតុធ្វើឲ្យដំណើរការអភិវឌ្ឍមានភាពរអាក់រអួល ។ លើសពីនេះទៅទៀត ដោយសារតែកិច្ចខំប្រឹងប្រែងរបស់ស្ត្រីទាំងអស់នេះហើយដែលធ្វើឲ្យវប្បធម៌ ការអប់រំ ទំនៀមទម្លាប់ និងប្រពៃណីដែលស្ទើររលាយសាបសូន្យដោយស្នាដៃខ្មែរក្រហមរស់ឡើងវិញក្នុងមូលដ្ឋានសង្គមប្រចាំថ្ងៃរបស់កម្ពុជា ។ ក្រោមសម្ពាធសង្គមដ៏លំបាកលំបិនបែបនេះ ស្ត្រីខ្មែរបានបង្ហាញនូវភាពរឹងមាំនិងភាពអត់ធន់យ៉ាងអង់អាច ។

ក្នុងឱកាសគម្រប់ខួបលើកទី១០០នៃទិវានារីអន្តរជាតិនៅក្នុងឆ្នាំនេះ ខ្ញុំសូមស្នើតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនិងជាសាធារណៈឲ្យមានការសាងសង់រូបសំណាកស្ត្រីជាមាតាម្នាក់ដើម្បីរំឭកដល់វីរភាពនិងភាពអង់អាចក្លាហាននៃស្ត្រីខ្មែរដែលរួចរស់ជីវិតពីរបបខ្មែរក្រហម ហើយរូបសំណាកនេះ នឹងជាបូជនីយដ្ឋានមួយដើម្បីឧទ្ទិសដល់អ្នកដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហម ។ រូបសំណាកនេះនឹងជានិមិត្តរូបនៃការតស៊ូដ៏ស្វិតស្វាញរបស់ស្ត្រីខ្មែរនិងរបស់ប្រទេសជាតិទាំងមូល ។ រូបសំណាកនេះក៏ដើម្បីជាការចងចាំនូវប្រវត្តិសាស្ត្រដ៏ជូរចត់មួយទុកជាមេរៀនសម្រាប់កូនខ្មែរនិងសាកលលោក ហើយអតីតកាលដែលកន្លងផុតទៅនឹងទុកជាមេរៀនមួយដើម្បីទប់ស្កាត់របបដដែលនេះកុំឲ្យកើតមានជាថ្មីម្តងទៀត ។

សណ្ឋាននៃរូបសំណាកនោះអាចជារូបស្ត្រីម្នាក់កាន់ដៃកូន ឬរូបស្ត្រីម្នាក់ឯង មួយជំហរមនុស្សដែលមានកម្ពស់ ២០ហ៊ីត (ប្រហែលជា៧ម៉ែត្រ) ដែលតំណាងឲ្យសតវត្សរ៍ទី២០ជាពេលដែលប្រជាជនកម្ពុជាទទួលរងនូវវិបត្តិនយោបាយ សង្គម និងសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរ ។ រូបសំណាកទាំងមូលនឹងត្រូវបែងចែកជាប្រាំពីរផ្នែកដែលបង្ហាញនូវអត្ថន័យដាច់ដោយឡែកពីគ្នា ក្នុងនោះបីផ្នែកខាងក្រោមនៃរូបសំណាកនឹងត្រូវកប់ទៅក្នុងដី ដែលតំណាងឲ្យប្រជាជនកម្ពុជាចំនួនបីលាននាក់ដែលស្លាប់នៅក្នុងរបបខ្មែរក្រហម ហើយបួនផ្នែកដែលស្ថិតនៅផុតពីដី តំណាងឲ្យប្រជាជនកម្ពុជាដែលបានរួចរស់ជីវិតពីការកាប់សម្លាប់ដែលភាគច្រើនគឺជាស្ត្រី ។

រូបសំណាកនេះគួរតែកសាងបែរមុខទៅទិសខាងលិចដែលជាទិសនៃសេចក្តីស្លាប់តាមផ្លូវពុទ្ធសាសនា ។ ផ្នែកខាងក្រោយនៃរូបសំណាកនឹងចាប់រូបភាពដ៏កក់ក្តៅនៃព្រះអាទិត្យដែលកំពុងរះឡើងពីផ្ទៃទឹកទន្លេសាប ។ នៅពេលព្រះអាទិត្យរះពីទិសខាងកើត ស្រមោលព្រះអាទិត្យនឹងដើរស្របគ្នាជាមួយនឹងរូបសំណាកដែរ ។ នៅពេលព្រះអាទិត្យធ្វើដំណើរទៅទិសខាងលិច ស្រមោលព្រះអាទិត្យនឹងប្តូរទិសដៅ នឹងចេញជាស្រមោលនៅពីក្រោយរូបសំណាកវិញ ។ ស្រមោលដែលរំកិលចុះឡើងជាប្រចាំនេះ គឺជានិមិត្តរូបនៃវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ចំនួនបីលាននាក់នៅក្នុងរបបខ្មែរក្រហម ។ នៅពេលព្រះអាទិត្យរៀបលិច ពន្លឺពណ៌មាសដ៏ឆ្អិនឆ្អៅនៃកាំរស្មីព្រះអាទិត្យនឹងចែងចាំងមកលើផ្ទៃរបស់រូបសំណាកដែលពន្លឺនេះជានិមិត្តរូបនៃការចងចាំជាអមតៈ ។

មនុស្សជាតិមិនអាចរស់នៅដោយគ្មានការចងចាំបានទេ ។ ការចងចាំទាំងនោះនឹងធ្វើឲ្យយើងចងចាំថាតើយើងជានរណា ហើយមានប្រភពមកពីណា ។ ស្រមោលពណ៌ខ្មៅ និងពន្លឺពណ៌លឿងទុំគឺជានិមិត្តរូបនៃការចងចាំនៃអំពើប្រល័យពូជសាសន៍ ។ រូបសំណាកនេះនឹងធ្វើឲ្យមានអារម្មណ៍ក្តុកក្តួលនិងក្តីអាណិតអាសូរមិនមែនជាការសងសឹកនិងគុំកួនទេ ។ រូបសំណាកនេះនឹងជាស្នាដៃសិល្បៈមួយដែលជានិមិត្តរូបនៃសន្តិភាព និងការអភិវឌ្ឍទៅមុខសម្រាប់ប្រទេសកម្ពុជា ។

ទីតាំងដ៏សមរម្យសម្រាប់កសាងរូបសំណាកនេះគួរតែនៅសួនច្បារសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ក្បែរមាត់ទន្លេឬសួនច្បារខាងលិចវិមានឯករាជ្យ ព្រោះនេះជាទីសាធារណៈសម្រាប់មនុស្សទូទៅទស្សនានិងធ្វើការស្វែងយល់ ។ នៅពេលដែលសាធារណជនទូទៅកំពុងសម្លឹងមើលទៅរូបសំណាកស្ត្រីដ៏មាន

មោទកភាពនោះ សាធារណជននឹងនឹកឃើញឡើងវិញនូវមេរៀននៃរបបប្រល័យពូជសាសន៍ ដូច្នេះនៅថ្ងៃអនាគត សោកនាដកម្មស្រដៀងគ្នានេះនឹងមិនអាចកើតមានម្តងទៀតទេ ទាំងក្នុងប្រទេសកម្ពុជានិងក្នុងសាកលលោកទាំងមូល ។

រូបសំណាកជាតិនេះគួរតែធ្វើឡើងក្នុងអំឡុងពេលនៃការកាត់ក្តីមេដឹកនាំខ្មែរក្រហមជាប្រវត្តិសាស្រ្តនេះ ។ **ឆាំង យុ**

# អ៊ឹម ចែម និង ឆាំង យុ ទស្សនាប្រាសាទព្រះវិហារ

នៅក្នុងរូបថតនេះ អ៊ឹម ចែម កំពុងនៅក្បែរលោក ឆាំង យុ ខណៈពេលដែលអ្នកទាំងពីរអង្គុយថតរូបជុំគ្នានៅក្រោមម្លប់ដើមគគីរដ៏ត្រឈឹងត្រឈៃមួយក្បែរប្រាសាទព្រះវិហារ ដែលមានទីតាំងនៅលើកំពូលភ្នំដងរែក តាមបណ្តោយព្រំដែនកម្ពុជា-ថៃ ។ អ៊ឹម ចែម ដែលសព្វថ្ងៃមានអាយុ៦៥ឆ្នាំ គឺជាអតីតគណៈស្រុកម្នាក់កាលពីជំនាន់កម្ពុជាប្រជាធិបតេយ្យ ជាកន្លែងដែលប្រជាជនកម្ពុជាជាច្រើននាក់បានបាត់បង់ជីវិតដោយសារភាពអត់ឃ្លាន ការធ្វើការបាក់កម្លាំង និងការសម្លាប់ ។ អ៊ឹម ចែម គឺជាអតីតគណៈស្រុកព្រះនេត្រព្រះក្នុងតំបន់៥ ភូមិភាគពាយ័ព្យ ជាកន្លែងដែលលោក ឆាំង យុ និងក្រុមគ្រួសារត្រូវបានជម្លៀសទៅនៅកាលពីជំនាន់ខ្មែរក្រហម ។

នៅថ្ងៃទី១ ខែមិនា ឆ្នាំ២០១១ អ៊ឹម ចែម បានទៅទស្សនាប្រាសាទព្រះវិហារដែលមានអាយុកាលរាប់ពាន់ឆ្នាំ ជាលើកដំបូងក្នុងឆាកជីវិតរបស់គាត់ ។ ចាប់តាំងពីជម្លោះរវាងកម្ពុជានិងថៃបានផ្ទុះឡើងនាពេលថ្មីៗនេះ អ៊ឹម ចែម និងអ្នកភូមិរបស់គាត់បានផ្តល់នូវការគាំទ្រទាំងកម្លាំងកាយ និងចិត្តដល់កងទ័ពដែលកំពុងឈរជើងនៅសមរភូមិតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ។ អ៊ឹម ចែម និងអ្នកភូមិដែលគាត់រស់នៅ ដែលមានចម្ងាយប្រមាណជា៩០គីឡូម៉ែត្រពីប្រាសាទព្រះវិហារដែលទទួលរងនូវការខូចខាតដោយសារជម្លោះថ្មីៗនេះ បានរួបរួមគ្នា និងផ្តល់កម្លាំងចិត្តយ៉ាងខ្លាំងក្លាដើម្បីគាំទ្រក្នុងការប្រយុទ្ធប្រឆាំងទៅនឹងអ្វីដែលហៅថាប្រទេសជាតិកំពុងរងការឈ្លានពានពីសំណាក់ប្រទេសថៃ ។ ដូចគ្នាទៅនឹងស្មារតីរបស់ អ៊ឹម ចែម ដែរ កងទ័ពមួយចំនួនដែលកំពុងឈរជើងនៅតំបន់ដែលកំពុងមានជម្លោះជិតប្រាសាទព្រះវិហារនេះ គឺជាអតីតយោធាខ្មែរក្រហម ហើយកងទ័ពខ្លះគឺជាកូនរបស់អ្នកភូមិដែលត្រូវបានបញ្ជូនមកពីភូមិរបស់ អ៊ឹម ចែម ផ្ទាល់ ។ កងទ័ពទាំងនោះមានការប្តេជ្ញាចិត្ត និងតាំងចិត្តយ៉ាងមោះមុតក្នុងការប្រយុទ្ធប្រឆាំងដើម្បីការពារបូរណភាពទឹកដីរបស់កម្ពុជា ។ បណ្ឌិត ចន ឆរឆីអារី ដែលជាសាស្រ្តាចារ្យបង្រៀនផ្នែកច្បាប់ និងនយោបាយអន្តរជាតិនៅសាកលវិទ្យាល័យមីឈីហ្គិន សហរដ្ឋអាមេរិក និងជាទីប្រឹក្សាច្បាប់ជាន់ខ្ពស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយដែលបានទស្សនាប្រាសាទព្រះវិហារជាមួយ អ៊ឹម ចែម ដែរ បានមានប្រសាសន៍ថា បើនិយាយពីការបង្រួបបង្រួមជាតិវិញ រដ្ឋាភិបាលថៃបានធ្វើឲ្យប្រទេសកម្ពុជាមានការបង្រួបបង្រួមគ្នាជាងមុន ។ បណ្ឌិត ឆរឆីអារី បានបន្ថែមទៀតថា ការបង្រួបបង្រួមគ្នាក្នុងទ្រង់ទ្រាយថ្នាក់ជាតិបែបនេះមិនដែលមានពីមុនមកទេ ហើយការបង្រួបបង្រួមនេះកើតឡើងដោយសារតែជម្លោះថ្មីៗជាមួយប្រទេសថៃ ទាក់ទងនឹងផ្ទៃដីនៅជុំវិញប្រាសាទព្រះវិហារនេះ ។ បណ្ឌិត ឆរឆីអារី បានបន្តថា «អត្តសញ្ញាណរបស់ខ្មែរក្រហមបានផ្លាស់ប្តូរ ។ អតីតខ្មែរក្រហមហាក់បីដូចជាផ្តាច់ពាក្យ "ក្រហម" ចោលហើយឥឡូវនេះ អ្នកទាំងនោះមើលឃើញខ្លួនឯងថាត្រឹមតែជាខ្មែរប៉ុណ្ណោះ ហើយអ្នកទាំងនោះមានមោទកភាពក្នុងការវាយប្រយុទ្ធនិងការពារប្រទេសជាតិពីសំណាក់បរទេសឈ្លានពាន ។ រដ្ឋាភិបាលកម្ពុជាមានការពេញចិត្តនឹងអតីតយោធាខ្មែរក្រហមទាំងនោះ ដែលបានប្តូរផ្តាច់ក្នុងការការពារតំបន់ដែលកំពុងមានជម្លោះ ហើយប្រជាជនកម្ពុជាទូទៅក៏មានចិត្តរីករាយដែរ ដែលអតីតយោធាខ្មែរក្រហមជើងចាស់ទាំងអស់នេះកំពុងប្រយុទ្ធប្រឆាំងយ៉ាងអង់អាចដើម្បីការពារប្រាសាទបុរាណដ៏មានតម្លៃរបស់ខ្មែរ» ។ **ឌី ធេរិទ្ធិ**



# ភាពភ័យខ្លាចនៅក្នុងជីវិតកុមារភាព

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឈឹម សំអុល មិនដែលបានទទួលការថ្នាក់ថ្នមពីឪពុកម្តាយរបស់គាត់ប៉ុន្មានទេ ដោយសារតែរយៈពេលមួយខែឬពីរខែ ទើបឃើញឪពុកម្តាយមកលេងផ្ទះម្តង។ លើសពីនេះទៅទៀត នៅពេលដែលបានជួបមុខគ្នាហើយ ឪពុកម្តាយរបស់គាត់មិនហ៊ានទាំងនិយាយសួរសុខទុក្ខគាត់ផងដោយគ្រាន់តែយំ ហើយយកដៃអង្អែលក្បាលគាត់ប៉ុណ្ណោះ។ ឥឡូវនេះ នៅពេលដែល សំអុល ក្លាយជាគ្រូបង្រៀនប្រវត្តិវិទ្យាម្នាក់នៅខេត្តបន្ទាយមានជ័យគាត់ក៏ចង់ប្រាប់រឿងរ៉ាវរបស់គាត់ឲ្យក្មេងៗជំនាន់ក្រោយបានដឹងពីជីវិតរបស់គាត់ដែរ។

សំអុល មានស្រុកកំណើតនៅភូមិពូនភ្នំ ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ។ នៅពេលខ្មែរក្រហមចូលមកកាន់កាប់ទីក្រុងភ្នំពេញ ក្រុមគ្រួសាររបស់ សំអុល ត្រូវបានជម្លៀសឲ្យទៅរស់នៅភូមិក្រាំងភ្នំជិតទន្លេបាទី។ នៅទីនោះ អង្គការបានបំបែក សំអុល និងឪពុកម្តាយរបស់គាត់មិនឲ្យរស់នៅជាមួយទេ ដោយរយៈពេលឬមួយឬពីរខែ ទើបអនុញ្ញាតឲ្យមកលេងផ្ទះបានមួយថ្ងៃ។ ឪពុកម្តាយរបស់ សំអុល ត្រូវបានចាត់តាំងឲ្យនៅកងភ្ជួរ និងម្តាយខាងកងដេរស្លឹកនៅឆ្ងាយពីផ្ទះ។ ចំណែក សំអុល ដែលមានអាយុប្រហែលដប់ឆ្នាំ ត្រូវបានចាត់តាំងឲ្យចូលកងកុមារមានតួនាទីកាប់ទន្រ្ទានខែត្រ ធ្វើជី កាប់ដីដំបូករាយតាមស្រែ។

ការរស់នៅមិនត្រឹមតែមានការលំបាកប៉ុណ្ណោះទេ ថែមទាំងមានការព្រួយបារម្ភពីសុវត្ថិភាពរបស់ខ្លួនទៀតពីព្រោះ សំអុល តែងតែឃើញឈ្លបខ្មែរក្រហមយកមនុស្សទៅសម្លាប់ស្ទើររៀងរាល់ថ្ងៃ។ យប់មួយក្នុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានយកមនុស្សទៅសម្លាប់ដែលភាគច្រើនជាគ្រូបង្រៀន និង និស្សិតដោយ



ការដ្ឋានលើកទំនប់ក្នុងរបបខ្មែរក្រហម

ប្រាប់ថាយកទៅរៀនសូត្រ ឬធ្វើផ្ទះថ្មី ប៉ុន្តែមិនដែលឃើញត្រឡប់មកវិញឡើយ ។ លើសពីនេះទៅទៀត សំអុល នៅចាំបានថានៅក្នុងកងកុមារ នរណាដែលលួចរត់ត្រឡប់មកផ្ទះ ឈ្លបនឹងចុះទៅចាប់ដល់ផ្ទះតែម្តង ហើយចងវាយធ្វើបាបដោយចងជើងព្យួរឡើងលើក្បាលចុះក្រោម រួចវាយរហូតដល់សន្លប់ទើបស្រាយចំណងវិញ ។ បន្ទាប់មក ឈ្លបទាំងនោះបានស្រោចទឹកពីលើពេលដឹងខ្លួននឹងបន្តសួរចម្លើយម្តងទៀត ។ ការសួរចម្លើយនេះភាគច្រើនគឺធ្វើនៅពេលយប់ ដើម្បីលាក់បាំងមិនឲ្យប្រជាជនដឹង ។ សំអុល នៅចាំពីហេតុការណ៍នោះច្បាស់ថា នៅយប់នោះ ឈ្លបទាំងនោះក៏បានឃើញគាត់ដែរ រួចក៏បានសួរគាត់ថា «តើមកមានការអ្វី? មានដឹងកន្លែងនេះកំពុងធ្វើការទេ?» ដោយសារតែភ័យខ្លាចខ្លាំងពេក សំអុល ក៏បានរត់មកកន្លែងសម្រាកវិញដោយមិនបានឆ្លើយអ្វីទាំងអស់ ។ ពេលត្រឡប់មកវិញ សំអុល គេងមិនលក់ទេ ដោយគាត់នៅតែមានអារម្មណ៍ភ័យខ្លាចថា ខ្មែរក្រហមនឹងចោទគាត់ជាខ្មាំងស៊ើបការណ៍ ហើយអាចយកគាត់ទៅសម្លាប់ទៀត ព្រោះគាត់ឃើញព្រឹត្តិការណ៍ដែលមិនគួរឃើញ ។ ប៉ុន្តែដោយសារតែ សំអុល នៅក្មេងពេក អង្គការក៏មិនបានយកចិត្តទុកដាក់ និងតាមដានសកម្មភាពរបស់គាត់ដែរ ។

ធ្វើការបានមួយរយៈ សំអុល ក៏បានធ្វើឲ្យមានកំហុសមួយ ដោយគាត់និងគ្នារបស់គាត់បីបួននាក់នាំគ្នាប្រានពាងមួយរហូតដល់បែក ដោយសារតែពាងនោះអត់មានទឹក និងរាងប្រេះបន្តិច ។ បន្ទាប់មក មេកងក៏បានរាយការណ៍ទៅអង្គការថ្នាក់លើរួចហៅក្រុមរបស់គាត់ទៅសួរ ។ ពេលដែលសួរអំពីរឿងនេះ ម្នាក់ៗសុទ្ធតែឆ្លើយដោះសាយករួចខ្លួន រួចនិយាយថាគាត់ជាអ្នកធ្វើឲ្យបែកពាងនោះតែម្នាក់ឯង ។ គណៈកងបាននិយាយគំរាមថា «អ្នកឯងអត់រួចខ្លួនទេ អ្នកឯងខ្មាំងប្រានពាងបំបែកចោល អញនឹងចាប់អ្នកឯងចងយកទៅវាយចេញម្តងហើយ ព្រោះអ្នកឯងខ្មាំងក្បត់បដិវត្តន៍» ។ ដូច្នេះហើយ នៅពេលដែលធ្វើការបណ្តើរ សំអុល យំបណ្តើរ ព្រោះមិនដឹងថាអង្គការនឹងដាក់ទោសគាត់កម្រិតណានោះទេ ។ ក្រោយមក ដើម្បីទទួលបាននូវការទុកចិត្តពីអង្គការ ទោះបីជាអង្គការឲ្យឈប់សម្រាក ឬក៏គាត់ឈឺធ្ងន់យ៉ាងណាក៏ដោយ ក៏ សំអុល នៅតែខិតខំធ្វើការដែរដូចជា រែកដី រើសអាចម៍គោដើម្បីសាងគុណសម្បត្តិ ។ ដោយមើលឃើញ ថាគាត់ពិតជាខំកែប្រែខ្លួន អង្គការក៏លែងយកទោសពៃរ៍ពីគាត់ ។ ប៉ុន្តែនៅអំឡុងពេលនោះ សំអុល មិនដែលសប្បាយចិត្តនោះទេ ដោយគាត់រស់នៅក្នុងភាពភ័យខ្លាចរហូត ។ ក្រោយមក ដោយសារតែការហូបចុកមិនបានគ្រប់គ្រាន់ និងខិតខំធ្វើការខ្លាំងពេក សំអុល ក៏បានធ្លាក់ខ្លួនឈឺ ។ ពេលនោះអង្គការបានអនុញ្ញាត ឲ្យ សំអុល ឈប់សម្រាកមួយថ្ងៃដែរ និងឲ្យថ្នាំអាចម៍ទន្សាយលេប ប៉ុន្តែថ្នាំនេះគ្មានប្រសិទ្ធភាពទេ ពីព្រោះមិនអាចធ្វើឲ្យជំងឺរបស់គាត់ជាសះស្បើយ ។

ទោះបីជារបបនេះដួលរលំផុតទៅអស់រយៈពេលជាង ៣០ឆ្នាំហើយក៏ដោយ ក៏ សំអុល នៅតែនឹកឃើញពីការរស់នៅក្នុងរបបខ្មែរក្រហម ជាពិសេសពេលដែលខ្មែរក្រហមមានបំណងយកគាត់ទៅសម្លាប់ ។ នៅឆ្នាំ១៩៨៧-៨៩ ក្រោយពីឪពុកម្តាយរបស់គាត់បានស្លាប់ទៅ គាត់ក៏បានមករស់នៅជាមួយបងស្រី និងបន្តការសិក្សានៅវិទ្យាល័យបាទីវិញ ។ ក្រោយពីប្រឡងជាប់សញ្ញាបត្រទុតិយភូមិ សំអុល ក៏ដាក់ពាក្យមករៀននៅសាកលវិទ្យាល័យភ្នំពេញ ផ្នែកប្រវត្តិវិទ្យា បន្តសាលាគរុកោសល្យរួចក៏មកធ្វើជាគ្រូបង្រៀននៅខេត្តបន្ទាយមានជ័យ ។

សំអុល ចូលចិត្តមុខវិជ្ជាប្រវត្តិវិទ្យានេះជាខ្លាំង ពីព្រោះគាត់ចង់ដឹងពីអតីតកាលរបស់ប្រទេសកម្ពុជា ។ ប៉ុន្តែការងារជាគ្រូបង្រៀននេះពេលខ្លះក៏បានជួបនឹងការលំបាកដែរ ដោយពេលបង្រៀននៅស្រុកម៉ាឡៃនេះ មានអតីតកម្មាភិបាលមួយចំនួនមិនសូវពេញចិត្តចំពោះការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនេះទេ ដោយអ្នកទាំងនោះនិយាយថា «សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះ សរសេររិះគន់តែពួកខ្ញុំអាក្រក់ទាំងអស់អាងតែពួកខ្ញុំចាញ់សង្គ្រាមសរសេរយ៉ាងម៉េចក៏សមដែរ» ។ និងខ្លះទៀតនិយាយថាមិនអាចទទួលយកសៀវភៅនេះបានតែម្តង ។

សំអុល ក៏បានព្យាយាមប្រាប់ទៅកូនសិស្សរបស់គាត់ដែលជាកូនរបស់អតីតកម្មាភិបាលខ្មែរក្រហមថា «សូមប្អូនកុំគិតថាការបង្រៀននេះ ប៉ះពាល់ទៅលើអារម្មណ៍របស់ប្អូន និងឪពុកម្តាយប្អូន ។ តាមការពិត សៀវភៅនេះចងក្រងសម្រាប់សិស្សពីថ្នាក់ទី៩-១២ ដើម្បីឲ្យសិស្សបានដឹង ព្រោះឪពុកម្តាយរបស់ប្អូនក៏ជាជនរងគ្រោះដែរ» ។ **គាត លក្ខិណា**

# ម៉ាឡៃ : ដប់ប្រាំឆ្នាំក្រោយសមាហរណកម្ម

ទោះបីជាជីវភាពរស់នៅមានការលំបាកជាធម្មតាក្តី អតីតអ្នកធ្លាប់គាំទ្រចលនាខ្មែរក្រហមនៅស្រុកម៉ាឡៃមានចិត្តរីករាយចំពោះគម្រោងអភិវឌ្ឍនៅក្នុងតំបន់របស់ខ្លួន ។ ពេលនេះ រដ្ឋាភិបាលកំពុងធ្វើការជួសជុលផ្លូវដែលមានចម្ងាយប្រមាណជាចិតសិបគីឡូម៉ែត្រដែលភ្ជាប់ពីផ្លូវជាតិលេខ៥ ត្រង់ម្តុំឃុំនិមិត្ត ស្រុកអូរជ្រៅ ឆ្ពោះទៅទីរួមស្រុកម៉ាឡៃ ។ ប្រជាជនម៉ាឡៃមានក្តីរំពឹងថា ស្រុកម៉ាឡៃនឹងផ្សារភ្ជាប់ទំនាក់ទំនងជាមួយតំបន់ផ្សេងទៀតទូទាំងប្រទេសបានល្អជាងមុន ។

កន្លងមក ផ្លូវទៅកាន់ស្រុកម៉ាឡៃមានសភាពលំបាកយ៉ាងខ្លាំងក្នុងការធ្វើដំណើរដោយផ្លូវមានសភាពរលាក់ខ្លាំងនិងពោរពេញដោយធូលីនៅរដូវប្រាំង ហើយទឹកជំនន់នៅសងខាងផ្លូវបានហូរកាត់នៅរដូវវស្សា ។ អ្នកស្រុកនៅទីនេះ មិនដែលមានឱកាសធ្វើដំណើរប្រកបដោយផាសុខភាពម្តងណាទេចាប់តាំងពីតំបន់ម៉ាឡៃបានចុះចូលជាមួយរដ្ឋាភិបាលក្នុងខែសីហា ឆ្នាំ១៩៩៦មក ។ ការជួសជុលផ្លូវនេះបានធ្វើឲ្យអតីតកម្មាភិបាលខ្មែរក្រហមមានចិត្តរីករាយ ។ នៅតាមផ្លូវឃើញមានស្លាកសញ្ញា «ប្រយ័ត្នគ្រាប់មីន» ទោះបីជាកន្លែងភាគច្រើន មីនត្រូវបានសម្អាតហើយក៏ដោយ ។

ជាងមួយទសវត្សរ៍ក្រោយពីរបបនាសម័ន្ធខ្មែរក្រហមបានដួលរលំក្នុងឆ្នាំ១៩៩៩តំបន់ម៉ាឡៃទើបតែឃើញមានការអភិវឌ្ឍ ប៉ុន្តែចិត្តគំនិតរបស់ប្រជាជនបានផ្លាស់ប្តូរជាយូរមកហើយចាប់តាំងពីតំបន់នេះបានចុះចូលជាមួយរដ្ឋាភិបាលមកម្ល៉េះ ។

ប្រជាជនម៉ាឡៃបានផ្លាស់ប្តូរយ៉ាងខ្លាំងមិនត្រឹមតែជីវភាពរស់នៅមានភាពប្រសើរឡើងជាងមុននោះទេ តែចិត្តគំនិតក៏មានការផ្លាស់ប្តូរដែរ ។ អតីតកម្មាភិបាលខ្មែរក្រហមបានផ្លាស់ប្តូរចិត្តគំនិតពីស្រឡាញ់ខ្មែរក្រហមទៅស្រឡាញ់រដ្ឋាភិបាលវិញ ហើយស្រឡាញ់រដ្ឋាភិបាលបច្ចុប្បន្នខ្លាំងដូចកាលដែលខ្លួនស្រឡាញ់ចលនាខ្មែរក្រហមដូច្នោះដែរ ។ បុរសម្នាក់ឈ្មោះ សេង បាននិយាយថា «កាលពីមុន ខ្ញុំស្រឡាញ់មេដឹកនាំខ្មែរក្រហម តែឥឡូវខ្ញុំស្រឡាញ់សម្តេច ហ៊ុន សែន» ។ សេង គឺជាអតីតយោធាខ្មែរក្រហមម្នាក់ដែលបានពិការដៃស្តាំ និងជើងឆ្វេងពេលដែលគាត់ប្រយុទ្ធក្នុងសមរភូមិជាមួយទាហានរដ្ឋាភិបាល ។ ប្រជាជនម៉ាឡៃភាគច្រើនមានគំនិតស្រដៀងនឹង សេង ដែរ ។

ប៉ុន្តែ សេង មានអារម្មណ៍ខ្មាសខ្លួនឯងដែលធ្លាប់គាំទ្រខ្មែរក្រហមអស់រយៈពេលជាងពីរទសវត្សរ៍ ។ សេង បាននិយាយថា «ខ្ញុំចង់ធ្វើជាមនុស្សល្អដោយគាំទ្រពេញទំហឹងដល់រដ្ឋាភិបាល ។ ខ្ញុំមិនចង់ឲ្យខ្មែរបែកបាក់គ្នាដូចមុនទៀតទេ» ។

ប៉ុន្តែ សេង មិននិយាយអ្វីទាំងអស់អំពីបទពិសោធន៍របស់គាត់កាលពីអតីតកាល ទោះបីជាត្រូវបានសួរយ៉ាងណាក៏ដោយ ។ អ្វីដែល សេង អាចនិយាយបានគឺថា គាត់បានចូលជាមួយចលនាខ្មែរក្រហមតាំងពីឆ្នាំ១៩៧០មក ។ បន្ទាប់ពីបានបម្រើខ្មែរក្រហមអស់ជាងពីរទសវត្សរ៍ សេង បាននិយាយថា «គេ (ខ្មែរក្រហម) ធ្វើឲ្យខ្ញុំឆ្កួតវង្វេង ។ ឥឡូវនេះ ខ្ញុំលែងឆ្កួតដូចមុនទៀតហើយ» ។ សេង បាននិយាយយ៉ាងម៉ឺងម៉ាត់ថា គាត់នឹងមិន


ផ្លូវទៅកាន់ទីរួមស្រុកម៉ាឡៃ

ទៅគាំទ្រខ្មែរក្រហមទៀតជាដាច់ខាត បើសិនជាមានការបញ្ចុះបញ្ចូលម្តងទៀត ហើយគាត់ក៏នឹងណែនាំកូនចៅមិនឲ្យចាញ់បោកខ្មែរក្រហមដូចគាត់ដែរ ។

ស្ត្រីដែលជាប្រពន្ធរបស់អតីតយុទ្ធជន និងកម្មាភិបាលខ្មែរក្រហមនៅម៉ាឡៃចង់និយាយរឿងរ៉ាវរបស់ខ្លួនកាលពីជំនាន់ខ្មែរក្រហម និងកាលពីជំនាន់តស៊ូក្នុងព្រៃក្នុងទសវត្សរ៍៨០ ។ អ្នកភូមិម្នាក់ឈ្មោះ ស៊ុំ តែងតែចង់បន្លាញពីជីវិតតស៊ូរបស់គាត់ដោយនិយាយថា គាត់មិនដែលចង់មករស់នៅម៉ាឡៃទេ ទោះបីជាគាត់បានចូលជាមួយខ្មែរក្រហមតាំងពីឆ្នាំ១៩៧២ក៏ដោយ ។ បន្ទាប់ពីម៉ាឡៃធ្វើសមាហរណកម្មជាមួយរដ្ឋាភិបាល ស៊ុំ បានត្រឡប់ទៅស្រុកកំណើតនៅខេត្តតាកែវវិញ ប៉ុន្តែអ្នកភូមិមិនបានគាំទ្រគាត់ទេ ដោយចោទថាគាត់ជា «ខ្មែរក្រហម» ។ ស៊ុំ បានត្រឡប់មកកាន់ម៉ាឡៃវិញ ហើយបន្តរស់នៅរហូតដល់សព្វថ្ងៃ ចំណែកឯឪពុករបស់គាត់កំពុងរស់នៅឯស្រុកកំណើតនៅខេត្តតាកែវ ។

ម៉ាឡៃគឺជាស្រុកមួយរបស់ខេត្តបន្ទាយមានជ័យដែលមានចម្ងាយប្រមាណជាប៉ែតសិបគីឡូម៉ែត្រភាគខាងលិចសេរីសោភ័ណ ។ ទីរួមស្រុកម៉ាឡៃមានចម្ងាយប្រហែលជាប្រាំរយម៉ែត្រប៉ុណ្ណោះពីព្រំដែនថៃ ។ ម៉ាឡៃគឺជាតំបន់គ្រប់គ្រងដោយខ្មែរក្រហមពេញមួយទសវត្សរ៍៨០ រហូតដល់ពាក់កណ្តាលទសវត្សរ៍៩០ ក្រោមការដឹកនាំរបស់អតីតរដ្ឋមន្ត្រីក្រសួងការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យ អៀង សារី ។ កាលពីឆ្នាំ១៩៨៤-១៩៨៥ ទាហានវៀតណាមបានវាយលុកតំបន់នេះដោយបានសម្លាប់អ្នកគាំទ្រខ្មែរក្រហមអស់ជាច្រើនពាន់នាក់ ។ សព្វថ្ងៃប្រជាជនម៉ាឡៃប្រកបរបរចិញ្ចឹមជីវិតដោយការធ្វើស្រែ ដាំសណ្តែក ពោត ដំឡូង ។ល ។

ស្រុកម៉ាឡៃដឹកនាំដោយអតីតបញ្ញវន្ត និងមន្ត្រីទូតម្នាក់របស់ខ្មែរក្រហមឈ្មោះ ទេព ឃុនណាល់ ដែលទទួលតំណែងជាអភិបាលស្រុកតាំងពីខែឧសភា ឆ្នាំ២០០៥មក ។ ទេព ឃុនណាល់ គឺជាបញ្ញវន្តដ៏កម្រម្នាក់ដែលមិនត្រូវបានបញ្ជូនទៅកាន់មន្ទីរស-២១ ក្រោយពេលដែលគាត់ត្រឡប់មកពីបរទេសវិញ ។ គាត់ត្រូវបានដាក់ឲ្យជាប់ឃុំនៅមន្ទីរអប់រំកែប្រែបឹងត្របែករហូតដល់ឆ្នាំ១៩៧៩ ពេលដែលវៀតណាមវាយប្រហារខ្មែរក្រហម ។ ទេព ឃុនណាល់ បានចាកចេញពីប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៧៣ ទៅកាន់ប្រទេសបារាំងដើម្បីរៀនខាងជំនាញវិស្វកម្ម ហើយបានត្រឡប់មកកាន់ប្រទេសកំណើតវិញនៅឆ្នាំ១៩៧៧ ដើម្បីមកកសាងប្រទេសក្រោយខ្មែរក្រហមទទួលបានជ័យជម្នះ ។ សព្វថ្ងៃបណ្ឌិត ទេព ឃុនណាល់ គឺជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យគ្រប់គ្រងនិងសេដ្ឋកិច្ច ក្នុងខេត្តបន្ទាយមានជ័យ ជាកន្លែងដែលគាត់បង្រៀនរៀងរាល់ចុងសប្តាហ៍ ។

ស្រុកម៉ាឡៃមានបួនឃុំ ក្នុងនោះឃុំម៉ាឡៃជាឃុំដែលមានប្រជាជនច្រើនជាងគេ ហើយក៏ជាមូលដ្ឋានរដ្ឋបាលរបស់ស្រុកម៉ាឡៃដែរ ។ ប្រជាជននៅម៉ាឡៃនៅតែចងចាំខ្លួនឯងថា ខ្លួនធ្លាប់ស្រឡាញ់ពេញចិត្តនឹងមេដឹកនាំខ្មែរក្រហមយ៉ាងខ្លាំងកាលពីទសវត្សរ៍៨០ ។ មេឃុំម៉ាឡៃឈ្មោះ ឌឹម សុខ បាន និយាយថា «ប្រជាជននៅទីនេះធ្លាប់ស្រឡាញ់ អៀង សារី ណាស់ ព្រោះគាត់តែងតែយកម្ហូបអាហារឲ្យប្រជាជនហូបពេលកំពុងខ្វះខាត» ។ ឌឹម សុខ ដែលមានឈ្មោះដើម ដួង សារ៉ន ហើយមានស្រុកកំណើតនៅខេត្តពោធិ៍សាត់ បានមករស់នៅម៉ាឡៃតាំងពីឆ្នាំ១៩៧៩មក ។ គាត់បម្រើជាយោធាខ្មែរក្រហមតាំងពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ នៅភូមិភាគពាយ័ព្យ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់ត្រូវខ្មែរក្រហមចាត់ជាប្រធានក្រុមជួសជុលរទេះភ្លើងនៅខេត្តបាត់ដំបង ។

ស្រដៀងគ្នាទៅនឹងប្រជាជនម៉ាឡៃផ្សេងទៀតដែរ ឌឹម សុខ បានផ្លាស់ប្តូរផ្នត់គំនិតរបស់គាត់ទាំងស្រុង ។ ឥឡូវគាត់ស្រឡាញ់និងរីករាយក្រោមការដឹកនាំរបស់សម្តេចនាយករដ្ឋមន្ត្រី ហើយគាត់ចង់បម្រើរដ្ឋាភិបាល ។ ប្រជាជនម៉ាឡៃរីករាយនឹងគម្រោងអភិវឌ្ឍរបស់រដ្ឋាភិបាលក្នុងការជួលជុលផ្លូវឡើងវិញ ដោយរំពឹងថាជីវភាពប្រជាជននិងប្រសើរជាងមុន ។ មេឃុំរូបនេះបាននិយាយដោយក្តីរីករាយថា «ជីវភាពរបស់ប្រជាជន និងប្រសើរឡើងពេលដែលផ្លូវធ្វើរួច» ។

ឌឹម សុខ មិនត្រឹមតែស្រឡាញ់នាយករដ្ឋមន្ត្រីប៉ុណ្ណោះទេ តែថែមទាំងដឹងយ៉ាងច្រើនពីជីវិតផ្ទាល់ខ្លួនរបស់គាត់ ។ ពេលសួរថាតើគាត់មានអាយុប៉ុន្មាន ឌឹម សុខ បានឆ្លើយថា «ខ្ញុំមានអាយុ៦០ឆ្នាំ ។ ខ្ញុំមានអាយុប្អូនសម្តេច ហ៊ុន សែន ពីរខែ» ។

**ញាណ សុជាតិ**

# សិល្បៈការិនីមជ្ឈិមខ្មែរក្រហម

នៅរសៀលថ្ងៃមួយពេលដែលកំពុងបើកមើលសៀវភៅ មុត រាម បានប្រទះឃើញរូបថតរបស់គាត់នៅក្នុងសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ១៩៧៥-១៩៧៩»។ នៅពេលដែលគាត់ឃើញរូបថតនេះដំបូង រាម មានការសង្ស័យ ដោយសារជារូបថតសខ្មៅ ហើយគាត់ថតតាំងពីពេល៣៨ឆ្នាំមកម្ល៉េះ។ ភ្លាមនេះ រាម សម្គាល់ឃើញមិត្តភក្តិដែលឈរថតជាជួរជាមួយគាត់អ្នកលេងព្យាណូឈ្មោះ យ៉ាវ មកពីបូព៌ា និងនារី រឹម ជាអ្នកសម្តែងសិល្បៈដែលមានស្រុកកំណើតនៅខេត្តក្រចេះទើបគាត់ប្រាកដក្នុងចិត្តថារូបនៅក្នុងរូបថតនេះគឺជារូបគាត់។ រាម រន្ធត់ចិត្តយ៉ាងខ្លាំងពេលឃើញរូបថតរបស់គាត់នៅសេសសល់ ព្រោះគាត់មិនដែលនឹកគិតថាបានរស់ជីវិតទេ។

មុត រាម កើតនៅភូមិព្រៃកអន្ទរថ្មី ឃុំជីក្រែង ស្រុកជីក្រែង ខេត្តសៀមរាប។ រាម មានបងប្អូនទាំងអស់១០នាក់ និងមានឳពុកម្តាយប្រកបរបរធ្វើស្រែ។ នៅពេល រាម មានអាយុបាន ១០ឆ្នាំម្តាយមីងរបស់ រាម ឈ្មោះ រឿន ជាអនុប្រធានសិល្បៈតំបន់បានមកយក រាម ទៅនៅមន្ទីរសិល្បៈស្វាលោត ស្ថិតនៅក្នុងព្រៃក្នុងភូមិពង្រ ឃុំពង្រ ស្រុកជីក្រែង ដោយមិនបានប្រាប់ម្តាយ រាម ឲ្យបានដឹងឡើយ។ នៅទីនោះ រាម សង្កេតឃើញយោធាខ្មែរក្រហមជាច្រើននាក់បានបោះទីតាំងនៅជុំវិញមន្ទីរដែលគាត់រស់នៅ ហើយយោធាទាំងនោះតែងតែចេញចូលទាក់ទងនិងរាយការណ៍មកក្រុមសិល្បៈរបស់គាត់ឲ្យប្រុងប្រយ័ត្ននៅពេលដែលមានការវាយប្រយុទ្ធគ្នា។


មុត រាម ឆ្នាំ២០១១

រាម បានចូលហាត់សិល្បៈជាមួយក្មេងប្រុសស្រីប្រមាណ ១០០នាក់ផ្សេងទៀត ដោយចែកជាច្រើនផ្នែក ដូចជា ផ្នែកចម្រៀង ផ្នែកសម្តែង និងផ្នែកភ្លេង។ រាម បានជ្រើសរើសយកផ្នែកសម្តែងរបាំព្រោះគាត់មិនសូវមានទេពកោសល្យខាងច្រៀងទេ។ ចំណែកការរស់នៅ ក្មេងប្រុសនិងក្មេងស្រីរស់នៅក្នុងរោងដាច់ដោយឡែកពីគ្នា ហើយឆ្លៀតពេលទំនេរពីហាត់រៀនកងសិល្បៈទាំងអស់ត្រូវកាប់ដីដាំបន្លែដូតដុតំកងទាំងមូល។

រាម បានហ្វឹកហាត់ខាងសិល្បៈរយៈពេលជិតពីរខែជាមួយគ្រូដែលត្រូវជាបងជីដូនមួយគាត់ឈ្មោះ រឿន, នារី ដាន និងលោកគ្រូឈ្មោះ ចេក និង វុធ។ ក្រោយពេលហ្វឹកហាត់ចប់ រាម និងក្រុមសិល្បៈប្រមាណ៥០-៦០នាក់បានទៅសម្តែងនៅតាមកន្លែងផ្សេងៗដែលខ្មែរក្រហមរៀបចំធ្វើពិធីអបអរដល់យោធានិងធ្វើមិទ្ទិងដូចជានៅស្រុកវ៉ារិន ស្រុកបន្ទាយស្រី នៅលើភ្នំគូលែន ខេត្តកំពង់ធំ និងកន្លែងផ្សេងៗទៀត ដោយមានការចូលរួមពី អៀង សារី, ខៀវ សំផន និង ធុច (កុយ ធួន) លេខាភូមិភាគឧត្តរ។ នៅពេលខ្លះ រាម ជួបនូវការលំបាកនៅពេលគ្មានឡានមកទទួលព្រោះគាត់ត្រូវដើរថ្មើរជើងតាមផ្លូវលំតូចៗហើយត្រូវស្ពាយឧបករណ៍សម្រាប់សម្តែងសម្លៀកបំពាក់និងសម្ភារៈផ្សេងៗ។ នៅពេលចេញទៅសម្តែងនៅលើភ្នំគូលែន រាម បានចំណាយពេលពីរថ្ងៃដើម្បីធ្វើដំណើរហើយត្រូវឈប់សម្រាកនៅផ្ទះប្រជាជនឬផ្ទះប្រធានភូមិ ហើយយប់ខ្លះ គាត់ត្រូវដេកនៅតាមផ្លូវតែម្តង។ ក្រុមសិល្បៈរបស់ រាម ចេញសម្តែងរយៈពេលមួយខែ ទើបគាត់ត្រឡប់ចូលក្នុងមន្ទីរវិញ ហើយភាគច្រើនសម្តែងនៅពេលយប់ដោយមានកងយោធាខ្មែរក្រហមយាមការពារនិងមានអ្នកថតរូប

ម្នាក់ប្រចាំនៅតំបន់នោះចាំថតក្រុមសិល្បៈរបស់គាត់ទុកជាអនុស្សាវរីយ៍ រួចហើយផ្ញើតរូបផ្ញើមកឲ្យមន្ទីររបស់គាត់វិញ ។

នៅឆ្នាំ១៩៧៣ រាម បានថតរូបជាច្រើនសន្លឹកនៅប្រាសាទបន្ទាយស្រី ។ ប៉ុន្តែរូបថតទាំងនោះបានខូចនិងបាត់បង់ពេលគាត់រត់គេចពីសង្គ្រាមអំឡុងទសវត្សរ៍៨០ ។

រាម នៅសិល្បៈតំបន់បានប្រាំឆ្នាំ ប្រធានសិល្បៈបានជ្រើសរើសអ្នកដែលមានសមត្ថភាព និងអ្នកសម្តែងល្អចំនួនប្រាំនាក់ឲ្យទៅហ្វឹកហាត់បន្ថែមនៅសិល្បៈភូមិភាគឧត្តរស្ថិតក្នុងស្រុកចម្ការលើ ខេត្តកំពង់ចាម ដែលក្នុងនោះមាន ឈ្មោះ រាម, លាង ផ្នែកខាងចម្រៀង, យ៉ាវ, រិន និង ម្នាក់ទៀត (មិនចាំឈ្មោះ) ផ្នែកខាងភ្លេង ។ រាម បានចូលហ្វឹកហាត់ជាមួយកងសិល្បៈភូមិភាគដែលមានសមាជិកទាំងអស់ប្រមាណ១០០នាក់ក្រោមការគ្រប់គ្រងរបស់សមមិត្ត ធុច ប្រធាន សមមិត្ត ចន្ទ្រា អនុប្រធាននិងសមមិត្ត ធិ ជាសមាជិកនិងជាគ្រូបង្ហាត់ផ្នែកសម្តែងរបាំ ។ ជារឿយៗ ធុច បានមកមើលការហ្វឹកហាត់របស់ក្រុមសិល្បៈនិងណែនាំក្រុមសិល្បៈទាំងអស់ហាត់ឲ្យទន់ភ្លន់ស័ក្តិសមដើម្បីយកទៅសម្តែងអប់រំប្រជាជនឲ្យជឿជាក់មកលើបក្ស ។

នៅទីនោះ ក្រៅពីហ្វឹកហាត់សិល្បៈ រាម ត្រូវជួយកាប់ដីនិងលើករងដាំដំឡូង ។ ក្រោយពីហ្វឹកហាត់បានមួយរយៈ រាម បានចេញទៅសម្តែងក្នុងពិធីមីទ្ទិងនិងពិធីបើកសន្និបាតបក្សនៅកន្លែងផ្សេងៗក្នុងខេត្តកំពង់ចាម ។

ហ្វឹកហាត់រយៈពេលពីរឆ្នាំ រាម ក៏ត្រឡប់មកសិល្បៈតំបន់៣៥ភូមិភាគរបស់គាត់វិញ ដោយគាត់មានតួនាទីជ្រើសរើសនិងបង្ហាត់សិស្សផ្នែកសម្តែងរបាំចំនួន៩០នាក់ដែលមានអាយុចាប់ពី១០ឆ្នាំទៅ១៥ឆ្នាំ ។ នៅពេលបង្ហាត់ម្តងៗ រាម មានការលំបាកក្នុងការណែនាំឲ្យសិស្សធ្វើត្រាប់តាម និងចេះស្តាប់ចង្វាក់ភ្លេងព្រោះសិស្សទាំងនោះនៅវ័យក្មេងពេក ។ ក្រៅពីបង្ហាត់សិស្ស រាម ត្រូវចេញទៅសម្តែងនៅកន្លែងផ្សេងៗ ហើយក្រុមសិល្បៈរបស់គាត់តែងតែទទួលបានការឧបត្ថម្ភជាប្រេង ម្សៅ សម្លៀកបំពាក់ និងប្រដាប់ប្រដាសម្តែងពីភ្ញៀវដែលមកទស្សនា ។


ក្រុមសិល្បៈខ្មែរក្រហម ថតក្នុងឆ្នាំ១៩៧៣ (មុត រាម រូបឈរទីពីររាប់ពីឆ្វេង)

នៅពេលកងយោធាខ្មែរក្រហមទទួលជ័យជម្នះនៅខែមេសា ឆ្នាំ១៩៧៥ ក្រុមសិល្បៈរបស់ រាម ចេញមកសម្តែងសិល្បៈទាំងយប់ទាំងថ្ងៃរយៈពេលមួយសប្តាហ៍នៅប្រាសាទអង្គរវត្តដើម្បីអបអរថ្ងៃជ័យជម្នះ និងជូនភ្ញៀវបរទេសទស្សនាដោយមានការចូលរួមពី អៀង សារី, ខៀវ សំផន និងមេដឹកនាំខ្មែរក្រហមសំខាន់ជាច្រើនទៀត ។

រយៈពេល១០ថ្ងៃក្រោយពីចប់កម្មវិធីសម្តែងសិល្បៈ ប្រធានមន្ទីរតំបន់៣៥ បានជ្រើសរើសក្រុមសិល្បៈដប់នាក់ (ស្រីប្រាំ ប្រុសប្រាំ) ដែលនារីមានឈ្មោះដូចជា វ៉ាន់, លាង, រិន, វ៉ែម និង រាម ចំណែកខាងបុរសមានឈ្មោះ អួន, រិន និងបីនាក់ទៀតមិនចាំឈ្មោះឲ្យមកនៅមន្ទីរសិល្បៈមជ្ឈិមនៅស៊ីងមានជ័យ (បច្ចុប្បន្នប៉ុស្តិ៍វិទ្យុជាតិ) ក្រុងភ្នំពេញ ក្រោមការគ្រប់គ្រងរបស់ ហ៊ូ នឹម ។ នៅមន្ទីរសិល្បៈមជ្ឈិមមានក្រុមសិល្បៈសរុបទាំងអស់ប្រមាណជិត ១០០នាក់ បន្ទាប់មកបែងចែកទៅតាមផ្នែកដូចជា ខាងផ្នែកច្រៀង ផ្នែកភ្លេង ផ្នែកសម្តែងរឿងនិងផ្នែកវិទ្យុ ។ រាម បានចូលធ្វើការក្នុងផ្នែកសម្តែង ។ ចំណែកផ្នែកចម្រៀង រាម ស្គាល់ឈ្មោះ ពេជ្រ អ្នកចម្រៀងស្រីមានសម្បុរស្រអែមមានស្រុកកំណើតនៅកំពង់ធំច្រៀងបទ «ជូនពរថ្ងៃ១៧ មេសា» ។

នៅទីនោះ (នារី) ថា មកពីខេត្តកំពង់ចាមដែលត្រូវជាអនុប្រធានមន្ទីរសិល្បៈ និងសមមិត្ត ទ្រា ដែលទទួលរៀបចំផ្នែកសម្តែងបានដឹកនាំក្រុមសិល្បៈរបស់ រាម ទៅសម្តែងក្នុងពិធីអបអរកងទ័ពនៅស្តាតអូឡាំពិកនិងសម្តែងរបាំជូនសម្តេចនរោត្តម សីហនុ, ប៉ុល ពត, អៀង សារី, ខៀវ សំផន, នួន ជា, ហ៊ូ នឹម និងមេទ័ពខ្មែរក្រហមជាច្រើននាក់ទៀតនៅសាលមហោស្រព (បច្ចុប្បន្នសាលសន្និសីទចតុមុខ) ។ តមកទៀត ទោះបីក្រុមសិល្បៈរបស់ រាម នៅពុំទាន់មានសម្ភារៈ មកុដ និងគ្រឿងតុបតែងខ្លួនគ្រប់គ្រាន់ក៏ដោយ ក៏សម្តេចនរោត្តម សីហនុ យាងមកទតក្រុមសិល្បៈរបស់គាត់ដែរ ។ ក្រៅពីសម្តែងជូនឥស្សរជនសំខាន់ៗ រាម ត្រូវសម្តែងជូនភ្ញៀវដែលមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា ដូចជា ចិន កូរ៉េ អាហ្វ្រិក និងជនជាតិស្បែកសជាច្រើនទៀត ។ បន្ទាប់ពីចប់កម្មវិធីនេះ រាម ត្រូវចេញទៅសម្តែងអបអរកងទ័ពនៅកំពង់សោម កំពង់ចាម តាកែវ និងនៅកន្លែងជាច្រើនទៀត ។

រាល់ថ្ងៃក្រោយពីសម្តែងចប់ រាម និងកងសិល្បៈទាំងអស់ត្រូវមកសម្រាកនៅមន្ទីរសិល្បៈ ប៉ុន្តែគាត់មានភារកិច្ចទៀតគឺរៀបចំបាយទឹកសម្រាប់គ្រួសារ ហ៊ូ នឹម ។ នៅវេលាម៉ោង៦ព្រឹក ឆ្នាំ១៩៧៧ ពេល រាម អញ្ជើញ ហ៊ូ នឹម មកហូបបបរដូចសព្វដង គាត់បានឆ្លើយបដិសេធថា «អ៊ំហូបមិនចូលទេ ហើយចាប់ពីពេលនេះទៅអ៊ំលែងបានជួបមុខក្មួយៗទៀតហើយ» ហ៊ូ នឹម គាត់ទទួលដំណឹងតាមតេអូថាអង្គការរកចាប់គាត់ ។ ទោះបីដឹងរឿងនេះមុនក៏ដោយ ក៏ ហ៊ូ នឹម មិនបានរត់គេចខ្លួនដែរ ព្រោះគាត់គិតថា គាត់មិនបានប្រព្រឹត្តខុសនឹងអង្គការទេ ចំណែកបុគ្គលិកនៅក្នុងក្រុមសិល្បៈទាំងអស់ក៏គាំទ្រនិងគោរពស្រឡាញ់រាប់អានគាត់ដែរ ។ មួយរយៈក្រោយមក រាម ឃើញឡានមួយគ្រឿងមកឈប់នៅមុខក្រុមសិល្បៈនិងឃើញកងសន្តិសុខបីនាក់មកហៅ ហ៊ូ នឹម រួចហើយដាក់ខ្នោះដៃដឹកចេញទៅបាត់ ដោយនៅពេលនោះ ប្រពន្ធ និងកូនគាត់បានត្រឹមតែទ្រហោយំប៉ុណ្ណោះ ។ បន្ទាប់ពីចាប់ ហ៊ូ នឹម បានរយៈពេលមួយសប្តាហ៍ កងសន្តិសុខក៏មកចាប់ ម្តាយ (ជរា) ប្រពន្ធ កូនប្រុសពីរនាក់ និងកូនស្រីម្នាក់យកទៅបាត់ទៀត ។

បន្ទាប់ពីចាប់គ្រួសារ ហ៊ូ នឹម អស់ អង្គការបានផ្លាស់នារីម្នាក់ (មិនចាំឈ្មោះ) មកពីខាងនិរតីគ្រប់គ្រងជំនួសវិញ ។ ប្រធានថ្មីនោះបានបង្ខំ រាម និងកងសិល្បៈទាំងអស់ហ្វឹកហាត់សម្តែងដោយគ្មានពេលសម្រាក ទោះបីមានជំងឺក៏ដោយ ចំណែកសមាជិកសិល្បៈខ្លះបានបាត់ខ្លួន និងចាប់ខ្លួនជាបន្តបន្ទាប់ដែរដូចជា បងជីដូនមួយរបស់ រាម ឈ្មោះ សោម ឡុង (ហៅ ឡុង) និងប្តីឈ្មោះ លីន ព្រមទាំងកូនស្រីអាយុប្រាំបីឆ្នាំ ក៏ត្រូវចាប់ខ្លួនដោយចោទថាក្បត់ ។ បន្ទាប់ពីចាប់គ្រួសារ លីន បានរយៈពេលមួយសប្តាហ៍ កងយោធាខ្មែរក្រហមយកឡានឃ្លុបបិទជិតមកដឹក រាម ទាំងនៅមានជំងឺគ្រុនយកទៅដាក់នៅកន្លែងលត់ដំនៅវត្តស្ទឹង (ខាងលិចភ្នំពេញ) ក្រោមការគ្រប់គ្រងរបស់បុរសម្នាក់ឈ្មោះ គី ។ ស្របពេលនោះ យុន យ៉ាត (ប្រពន្ធរបស់ សុន សេន) ដែលធ្លាប់ស្គាល់និងបង្ហាត់បង្រៀនទ្រឹស្តីនយោបាយដល់ រាម នៅក្នុងអង្គភាពសិល្បៈបានឲ្យនិរសារបស់គាត់ទៅរក រាម ទើបដឹងពីការចាប់ខ្លួននេះ ហើយគាត់ក៏ទូរស័ព្ទឲ្យយោធាយាមតាមផ្លូវស្ទាក់ឡាននិងបញ្ជាឲ្យ

ដឹក រាម មកព្យាបាលជំងឺនៅផ្ទះគាត់ជិតស្ពានអូឡាំពិកវិញ ។

មិនយូរប៉ុន្មាន យោធាបានមកចាប់ រាម ទៅដាក់នៅមន្ទីរលត់ដំនៅវត្តស្វែង ។ ទៅដល់ដំបូង រាម ត្រូវកម្មាភិបាលខ្មែរក្រហមសួរគាត់ពីកំហុសដែលបានប្រព្រឹត្តនិងរកអ្នកអប់រំគាត់ឲ្យបន្តប់ក្នុងកងសិល្បៈ ។ ប៉ុន្តែដោយសាររកមិនឃើញកំហុសរបស់ រាម ទើបគឺ បញ្ជូនគាត់ឲ្យមកផ្នែកដាំបាយឲ្យអ្នកទោសវិញ ។ រាល់ថ្ងៃអ្នកទោសត្រូវទៅធ្វើការងារភ្ជួររាស់ ដកស្ទូង ក្រោយមក ទើប គឺចាត់តាំងឲ្យធ្វើផ្លូវរទេះភ្លើង និងអ្នកទោសខ្លះទៀតត្រូវបញ្ជូនឲ្យទៅខេត្តបាត់ដំបង ។

រាម នៅមន្ទីរលត់ដំវត្តស្វែងរហូតដល់វៀតណាមវាយលុកប្រទេសកម្ពុជា ទើបគាត់រត់ទៅជួបកងយោធាមជ្ឈិមខ្មែរក្រហមនៅតាមព្រំដែនខ្មែរ-ថៃ ក្នុងខេត្តបាត់ដំបង ។

នៅទីនោះ កងយោធាខ្មែរក្រហមបានជ្រើសរើស រាម ឲ្យចូលធ្វើការនៅផ្នែកនារីស្នាក់ការសម្រាប់សែងអ្នករបួស ហើយកងរបស់គាត់បានផ្លាស់ប្តូរទីតាំងជាច្រើនកន្លែង ដូចជានៅកំរៀង អំពិលប្រាំដើម ភ្នំកុយ ភ្នំត្រាំង និងចុងក្រោយនៅម៉ាឡៃ ។ រាម មកនៅម៉ាឡៃបានមួយរយៈ អៀង សារី បានជ្រើសរើសគាត់ឲ្យទៅថែទាំក្មេងក្នុងជំរំថ-១០០ក្នុងខេត្តច័ន្ទបុរីប្រទេសថៃ ក្រោមការមើលខុសត្រូវរបស់នារី មិញ (ត្រូវជាកូនរបស់ អៀង សារី) ។ រាម មើលថែទាំក្មេងៗប្រហែលដប់នាក់ដែលឪពុកម្តាយរបស់គេចេញទៅបំពេញបេសកម្មផ្នែកការទូតនៅប្រទេសចិន កូរ៉េ និងប្រទេសអាមេរិក ហើយយូរម្តងៗទើបមកមើលកូនរបស់គេ ។ នៅទីនោះ រាម បានឃើញ ខៀវ សំផន និង មេដឹកនាំខ្មែរក្រហមផ្សេងៗទៀតមកស្នាក់នៅនិងប្រជុំការងារ ។

ក្រោយមក រាម ចាប់ផ្តើមឈឺគ្រុន និងសន្លប់រយៈពេលមួយសប្តាហ៍ ប៉ុន្តែដោយមានការជួយព្យាបាលពីវេជ្ជបណ្ឌិត ដួន ជឿន ទើបគាត់ធូរស្បើយ ។ នៅឆ្នាំ១៩៨២ រាម បានសុំអនុញ្ញាតពី អៀង សារី មករស់ជាមួយមិត្តភក្តិរបស់គាត់នៅម៉ាឡៃវិញ ។ មកដល់ដំបូង សមមិត្ត ថុន ប្រធានខាងបោះពុម្ពកាសែត និង សមមិត្ត ដួន ប្រធានផ្ដិតហ្វីលរូបថតបានស្នើយក រាម មកជួយធ្វើការងារ ប៉ុន្តែ អៀង សារី បានបដិសេធ ហើយឲ្យគាត់មកធ្វើក្នុងកងសិល្បៈដែលមានសមមិត្ត រិន ជាអ្នកគ្រប់គ្រងវិញ ។ នៅទីនោះ រាម ជាគ្រូបង្ហាត់សម្តែង ។

នៅឆ្នាំ១៩៨៥ រាម បានសុំអនុញ្ញាតពីប្រធានផ្លាស់ទៅកងដឹកជញ្ជូនវិញ ។ នៅពេលនោះ រាម បានរៀបការជាមួយយោធាខ្មែរក្រហមម្នាក់នៅបន្ទាយខ្លាំងរាប់ក្នុងស្រុកម៉ាឡៃ ។ ក្រោយពីរៀបការបានរយៈពេលបីខែ កងទ័ពវៀតណាមបានវាយយកបានបន្ទាយខ្លាំងរាប់ហើយ រាម និងប្តីបានរត់ភៀសខ្លួនទៅនៅជំរំថ-៨៥ក្នុងខេត្តអារញ្ញប្រាថេត ។ នៅជំរំ រាម កើតបានកូនប្រុសមួយប៉ុន្តែពិការជើងទាំងពីរដោយសារជំងឺខ្វះជីវជាតិ ចំណែកប្តីរបស់គាត់ត្រូវបានបញ្ជូនឲ្យទៅវាយនៅសមរភូមិ ។

បន្ទាប់ពីកងទ័ពវៀតណាមដកចេញពីប្រទេសកម្ពុជា ឆ្នាំ១៩៨៩ រាម និងកូនបានត្រឡប់មកចាប់យកដី និងសង់ផ្ទះរស់នៅដែលបច្ចុប្បន្នស្ថិតក្នុងស្រុកម៉ាឡៃ ។ នៅទីនោះ រាម កើតបានកូនប្រុសម្នាក់ទៀត ហើយដោយសារមានការខ្វះខាតផ្នែកជីវភាព ប្តីរបស់ រាម បានចេញទៅកាប់ឈើក្នុងព្រៃក៏ត្រូវចោរប្លន់បាញ់សម្លាប់ ។ ក្រោយពីប្តីស្លាប់ រាម បានដើរស៊ីឈ្នួលធ្វើចម្ការឲ្យអ្នកស្រុកនិងនៅប្រទេសថៃ ។

**សោម ប៊ុនថន**

# ដំណឹងស្វែងរកសាច់ញាតិ

នាងខ្ញុំឈ្មោះ កង ឃិន អាយុ ៧០ឆ្នាំ សព្វថ្ងៃរស់នៅភូមិអន្លង់ជ្រៃ ឃុំអំពើន ស្រុកបន្ទាយមាស ខេត្តកំពត ។ សូមប្រកាសស្វែងរកកូននិងប្តីដែលបាត់ខ្លួនកាលពីជំនាន់កម្ពុជាប្រជាធិបតេយ្យ ។ កូនរបស់ខ្ញុំឈ្មោះ ហូម ហើយប្តីឈ្មោះ ពីន ។ អ្នកទាំងពីរត្រូវខ្មែរក្រហមចាត់តាំងឲ្យទៅធ្វើស្រែអំបិលនៅកែប ហើយមិនឃើញត្រឡប់មកវិញរហូតដល់សព្វថ្ងៃ ។

ប្រសិនបើបងប្អូនណាបានស្គាល់ឈ្មោះ ឬឮដំណឹងនេះ សូមមេត្តាទាក់ទងមកអាសយដ្ឋានរបស់នាងខ្ញុំដូចបានរៀបរាប់ខាងលើ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ឬទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ ***សូមអរគុណ***

# កុមារភាពរបស់ ប៉ុត កន

ប៉ុត កន មានបងប្អូន៨នាក់ និងកើតនៅឆ្នាំ១៩៥៤ នៅភូមិត្រពាំងវែង ឃុំព្រៃស្លឹក ស្រុកទ្រាំង ខេត្តតាកែវ ។ នៅឆ្នាំ១៩៦៦ ឪពុកម្តាយរបស់ កន បានបញ្ជូនគាត់ឲ្យទៅរៀន និងរស់នៅជាមួយឪពុកមាដែលមានឈ្មោះថា ង៉ែត ទិត្យ ដែលជាអនុគណនៅស្រុកមោងឫស្សីខេត្តបាត់ដំបង ។ នៅទីនោះ ព្រះតេជគុណ ទិត្យ បានរៀបចំឲ្យ កន ចូលរៀននៅសាលាបឋមសិក្សាព្រៃស្វាយ និងបង្រៀន កន អំពីធម៌អាថ៌ សីលធម៌រស់នៅ និងវិជ្ជាពេទ្យមួយចំនួនដូចជា ការចាក់ថ្នាំ ការរុំរបួស និងការព្យាបាលជំងឺផ្សេងៗ ។ រហូតដល់ថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៧០នៅពេលដែលមានរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុ ស្ថានភាពនៅតំបន់ដែល កន រស់នៅចាប់ផ្តើមមានភាពជ្រួលច្របល់ជាខ្លាំងដែលធ្វើឲ្យព្រះ តេជគុណ ទិត្យ សម្រេចចិត្តបញ្ជូន កន ឲ្យទៅរស់នៅភ្នំពេញដោយស្នាក់នៅវត្តព្រះពុទ្ធមានបុណ្យ កុដិលេខ៦ ដែលមាន សៅ ជឹម ជាមេកុដិវិញ ។ នៅទីនោះ កន បានទៅបន្តការសិក្សានៅសាលាបឋមសិក្សា អ៊ុំង ម៉េងតឹក ។ ក្រោយមក អំឡុងពេលនៃការបោះឆ្នោតនៅទីក្រុងភ្នំពេញខ្មែរក្រហមបានបង្កចលាចលដូចជាបង្កប់គ្រាប់បែក ធ្វើកូដកម្ម និងចាប់ខ្លួន ថាច់ ជា និង កែវ សាំងគីម ដែលជារដ្ឋមន្ត្រីក្រសួងអប់រំចូលមកក្នុងសាលា ១៨មិនា ដោយចោទថា ក្រសួងអប់រំបានចាប់យុវជនដែលបានធ្វើបាតុកម្មនៅប៉ុន្មានថ្ងៃមុន ហើយទាមទារឲ្យអ្នកទាំងពីរដោះលែងយុវជនទាំងនោះ ។ ក្រោយមក ឮដំណឹងថា ថាច់ ជា និង កែវ សាំងគីម ត្រូវបានបាញ់ស្លាប់ ។

ចាប់ពីពេលនោះមក ក៏តែងតែមានការផ្ទុះគ្រាប់បែកមកក្នុងរាជធានីដែលបណ្តាលឲ្យស្ថានភាពកាន់តែច្របូកច្របល់ ។ ឃើញដូច្នោះ ឪពុកមារបស់ កន ដែលនៅបាត់ដំបងក៏បានមកយក កន ត្រឡប់ទៅរស់នៅខេត្តបាត់ដំបង និងបន្តប្រឡងចូលរៀននៅថ្នាក់វិទ្យាល័យ ។ នៅទីនោះ ខ្មែរក្រហមតែងតែចូលមកយាយីភូមិដោយជ្រាតចូលក្រុមសិស្សនិងនិស្សិតដើម្បីដឹកនាំឲ្យមានការធ្វើបាតុកម្មរារាំងដំណើរការសេដ្ឋកិច្ចទីផ្សារ លួចស្បៀង ដុតកម្ទេចឃ្លាំងម៉ូតូ ឡាន ម៉ាស៊ីន និងស្រែកឃោសនាថា “បាតុកម្មនេះគឺដើម្បីទាមទារឲ្យពួកមូលធននិយម ពួកកេងប្រវ័ញ្ចពួកដែលជិះជាន់លើយើងទាំងអស់គ្នា បញ្ចុះតម្លៃទំនិញដើម្បីឲ្យប្រជាជនយើងមានជីវភាពធូរធារ” ។ ដូច្នេះនាយកសាលាបានឲ្យ កន ដែលជាប្រធានថ្នាក់និងប្រធានថ្នាក់ផ្សេងទៀតធ្វើកម្លាំងជួការពារសាលា ។ ក្រោយមក ដោយសភាពការណ៍នៅក្នុងភូមិកាន់តែច្របូកច្របល់មិនអាចទប់ស្កាត់បាន នាយកសាលាក៏បានឲ្យសិស្សទាំងអស់ផ្ទេរទៅរៀននៅវិទ្យាល័យបាត់ដំបងវិញ ។ ភាពច្របូកច្របល់បែបនេះបានបន្តរហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែល កន ឃើញខ្មែរក្រហមដើរឃោសនាឲ្យប្រជាពលរដ្ឋនិងទាហានទម្លាក់អាវុធនិងលើកទង់សដើម្បីទទួលមិត្តយុវជនខ្មែរក្រហមដែលចូលមកក្រុង ។ រហូតដល់ម៉ោង១០យប់ កន បានឮខ្មែរក្រហមផ្សាយបន្តផ្ទាល់នៅក្នុងវិទ្យុចម្ការចេក នៃខេត្តបាត់ដំបង និងវិទ្យុជាតិនៃទីក្រុងភ្នំពេញថា «យើងមកនេះគឺមិនមែនដោយចរចាទេគឺចូលមកដោយចុងអាវុធរបស់យើង ដូច្នេះកងទ័ពនិងមន្ត្រីរាជការប្រដាប់អាវុធត្រូវទម្លាក់អាវុធ បើពុំដូច្នោះទេ យើងនឹងមិនយល់មុខអ្នកណាម្នាក់ឡើយ» ។ លុះដល់ម៉ោងប្រាំបីព្រឹកខ្មែរក្រហមបានប្រកាសឲ្យប្រជាជនចាកចេញពីទីក្រុងរយៈ


ប៉ុត កន

ពេលបីថ្ងៃដោយមិនចាំបាច់យករបស់របរអ្វីទៅតាមខ្លួនឡើយដើម្បីគេចពីផែនការទម្លាក់គ្រាប់បែករបស់អាមេរិក ។ កន បានចាកចេញពីទីរួមខេត្តជាមួយបងប្អូនជីដូនមួយពីរនាក់ ឈ្មោះ សឿន និង ទូច ដោយរថយន្ត ។ ចំណែកឯទាហានដែលមានស័ក្តិខ្លះក៏បានបកស័ក្តិចោលនិងធ្វើដំណើរដោយថ្មើរជើងដើម្បីលាក់អត្តសញ្ញាណរបស់ខ្លួន ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ខ្មែរក្រហមនៅតែចង់វែករកកម្លាំងខ្មាំងបង្កប់ដែលធ្លាប់មានបុណ្យស័ក្តិដោយប្រកាសថា «បងប្អូនមន្ត្រីរាជការ និងទាហានដែលមានបុណ្យស័ក្តិត្រូវពាក់ឯកសណ្ឋានវិញដើម្បីឲ្យអង្គការយើងនាំអស់លោកទៅទទួលសម្តេចនរោត្តមសីហនុ, ហ៊ូ យន់, ហ៊ូ នឹម និង ខៀវ សំផន នៅទីក្រុងភ្នំពេញ» ។ ខ្មែរក្រហមបានកំណត់ឲ្យអ្នកទាំងនោះជួបជុំនៅទីធ្លាវិទ្យាល័យបាត់ដំបង ។ ព្រឹកឡើង កន បានឃើញប្រជាជនស្លៀកពាក់ឯកសណ្ឋានប្រហែលពីររយនាក់ដែលក្នុងមានអ្នកខ្លះជាប្រជាជនសាមញ្ញបន្លំខ្លួនបានឡើងជិះឡានដែលខ្មែរក្រហមបានរៀបចំ ។

ក្រោយមក កន ក៏ឃើញមីងម្នាក់ដែលគាត់ធ្លាប់គោរពស្រឡាញ់ដូចជាម្តាយធម៌ និងត្រូវជាប្រពន្ធពេទ្យ ភំ (ដែលធ្លាប់ជាពេទ្យទាហានស័ក្តបី ប៉ុន្តែត្រូវខ្មែរក្រហមយកទៅសម្លាប់) និងកូនរបស់គាត់នៅតាមផ្លូវ ។ ពេលនោះ មីងនោះក៏លើកដៃសំពះ កន ដែលជាអ្នកធ្លាប់ស្គាល់គ្នាឲ្យចុះមកជួយដឹកជញ្ជូនឥវ៉ាន់ដោយសារតែកូនរបស់គាត់សុទ្ធតែជាស្រី និងមានកូនពៅប្រុសម្នាក់ដែលមានវ័យក្មេង ។ កន ក៏ចុះពីឡាន ហើយស្នើឲ្យអ្នករួមដំណើរជាមួយគាត់ទៅមុន ។ បន្ទាប់ពីលាគ្នា មីងម្នាក់នោះក៏ហុចសោផ្ទះឲ្យ កន ដើម្បីចូលទៅយកឥវ៉ាន់ ។ កន បានយកអង្ករមួយបាវ និងខោអាវមួយចំនួនដាក់លើម៉ូតូសង់វ៉ាំងសែងតួធ្វើដំណើរជាមួយមីងនោះ ។ នៅតាមផ្លូវ កន បានឃើញលុយនៅពាសពេញផ្លូវ ដូច្នេះគាត់បានដើររើសលុយមួយចំនួនទុកសម្រាប់ទិញសាំងចាក់ម៉ូតូដែលកំពុងតែជិះ ។ បីថ្ងៃក្រោយមក កន ក៏បានឃើញប្រជាជនដែលត្រូវបានបោកបញ្ឆោតឲ្យទៅទទួលសម្តេចព្រះនរោត្តម សីហនុ និងមេដឹកនាំដទៃទៀតស្លាប់ជាច្រើននាក់នៅលើទីវាលមួយជិតពីផ្លូវជាតិលេខ៥ ។

ប៉ុន្មានខែក្រោយមក ខ្មែរក្រហមបានស្នើឲ្យ កន យកម៉ូតូនិងរបស់របរទាំងប៉ុន្មានទៅដាក់ជារបស់រួម ។ បន្ទាប់មក ខ្មែរក្រហមក៏ចុះស្រង់ស្ថិតិពីគ្រួសារនីមួយៗ ។ ឃើញដូច្នោះ កន ក៏សម្រេចចិត្តចាកចេញពីស្ត្រីនោះដើម្បីទៅស្វែងរកបងប្អូនជីដូនមួយដែលបានបែកផ្លូវគ្នានិងឪពុកមាដែលធ្លាប់ចិញ្ចឹមបីបាច់ថែរក្សា ។ ពេលទៅដល់ភូមិមួយ កន ក៏ឃើញបងប្អូនជីដូនមួយម្នាក់ទៀតរបស់ខ្លួន ។ បងជីដូនមួយបានសួរ កន ថា «មានភ្ជាប់មកជាមួយនូវកាតសិស្ស ឬអ្វីសម្គាល់ខ្លួនទេ»? កន ឆ្លើយតប ថា «មាន» បងម្នាក់នោះបានណែនាំ កន ឲ្យយកវាទៅដុតចោលទាំងអស់ដើម្បីកុំឲ្យខ្មែរក្រហមធ្វើបាប ពីព្រោះអ្នកដែលធ្លាប់រៀនសូត្របានខ្ពស់គឺជាមុខសញ្ញារបស់ខ្មែរក្រហម ។ មិនយូរប៉ុន្មាន កន បានឮដំណឹងថា ព្រះតេជគុណ ទិត្យ និងឪពុកមាផ្សេងទៀតកំពុងរស់នៅវត្តនៅឯឃុំព្រៃស្វាយដែលគាត់ធ្លាប់ស្នាក់អាស្រ័យ ដូច្នេះគាត់ក៏ទៅរកអ្នកទាំងនោះ ។ ប៉ុន្តែ បន្ទាប់ពីស្នាក់នៅជាមួយគ្នាបានមួយរយៈ ខ្មែរក្រហមបានបញ្ជាឲ្យផ្សឹកលោកទាំងអស់ដែលនៅក្នុងវត្តដើម្បីឲ្យទៅបម្រើការងារជូនអង្គការ ។ ប៉ុន្មានម៉ោងក្រោយមកព្រះសង្ឃទាំងអស់ដែលនៅក្នុងវត្តត្រូវបានផ្សឹកទាំងអស់ ។ ដោយឡែកលោកសង្ឃប្រាំពីរអង្គដែលរួមមាន ឪពុកមារបស់ កន និងក្មេងពីរនាក់ទៀតដែលមានស្រុកកំណើតនៅខេត្តតាកែវដែរ និងចង់វិលត្រឡប់ទៅស្រុកកំណើតក៏បានអង្វរករខ្មែរក្រហមកុំទាន់ផ្សឹកលោកដើម្បីងាយស្រួលដល់ពេលធ្វើដំណើរ ពីព្រោះខ្មែរក្រហមអាចមានការលើកលែងខ្លះចំពោះព្រះសង្ឃ ។ នៅពេលធ្វើដំណើរអ្នកទាំងអស់គ្នាបានសុំដោយសារឡានដឹកស្បៀងរបស់ខ្មែរក្រហមដែលនឹងឈប់នៅពោធិ៍សាត់ទៅជាមួយគ្នា បន្ទាប់មកក៏ចុះដើររហូតដល់ទំនប់លើកដែកស្រុកទឹកផុសខេត្តកំពង់ឆ្នាំង ។

នៅទីនោះ ខ្មែរក្រហមបានឃាត់ដំណើរ កន និងអ្នកធ្វើដំណើរជាមួយគ្នាឲ្យនៅជួយកសាងទំនប់ជ័យជម្នះ ឬទំនប់លើកដែកដោយឃោសនាថា «សុំបងប្អូនជួយកសាងទំនប់នៅទីនេះសិន ។ ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នឹម នឹងមកសម្ពោធបន្ទាប់មកយើងនឹងអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅស្រុកកំណើតវិញ» ។ កន ត្រូវបានចាត់តាំងឲ្យធ្វើជាមេក្រុមគ្រប់គ្រងបីសាខាដែលមួយសាខាមានគ្នាបីនាក់និងស្នាក់នៅក្នុងខ្ទមប្រក់កៅស៊ូដែលមានចម្ងាយបីគីឡូម៉ែតពីការដ្ឋានសាងសង់ ដោយបែកខោអាវមួយកំផ្លេ ចានមួយ និងស្លាបព្រាមួយ រីឯព្រះសង្ឃដែលធ្វើ

ដំណើរជាមួយត្រូវទៅរស់នៅកងផ្សេង។ ពីរខែក្រោយមក កន មានគំនិតចង់បន្តដំណើរទៅខេត្តតាកែវដើម្បីស្វែងរកឪពុក ម្តាយ ដូច្នេះក៏ណាត់ជាមួយព្រះសង្ឃ ដែលមកជាមួយគ្នារត់ទៅជួបគ្នានៅក្នុងព្រៃនៅពេលដែលខ្មែរក្រហមវាយជួងឲ្យបើកបបរដែលជារបបអាហារប្រចាំថ្ងៃ។ ពេលធ្វើដំណើរ កន យកតែស្លាប ព្រា ឆ្នាំង និងអំបិលបន្តិចបន្តួចទៅតាមខ្លួនប៉ុណ្ណោះ។ យប់ឡើង កន និងក្មេងម្នាក់ទៀតដែលក្នុងកងបានរត់ចូលព្រៃ ប៉ុន្តែមិនបានជួបព្រះសង្ឃដែលគាត់ចង់ជួបទេ បែរជាជួបព្រះសង្ឃដទៃទៀតដែលមានជំងឺគ្រុនចាញ់ទើបតែចេញពីពេទ្យ ហើយក៏ឲ្យសម្រាកជាមួយគ្នា។ ពេលមកដល់ភូមិស្រែនោង ស្រុកត្រាំកក់ គ្រួសារខ្មែរក្រហមដែលធ្លាប់គោរពប្រណិប័តន៍សាសនាបានស្វាគមន៍ កន និង អ្នករួមដំណើរជាមួយដោយរៀបចំបាយម្ហូបនិងកន្លែងស្នាក់អាស្រ័យឲ្យគាត់ទាំងអស់គ្នា ហើយស្នើឲ្យរស់នៅទីនោះតែម្តង។ ព្រះសង្ឃនិងក្មេងដែលមកជាមួយសម្រេចចិត្តរស់នៅទីនោះ ប៉ុន្តែ កន បានបដិសេធ ដូច្នេះគាត់ក៏ធ្វើដំណើរតែម្នាក់ឯងទៅភូមិកំណើតដើម្បីជួបជុំឪពុកម្តាយ។ ពេលមកដល់ភូមិត្រពាំងវែង កន មានសេចក្តីត្រេកអរនិងសប្បាយរីករាយជាខ្លាំងដោយបានឃើញប្អូនស្រីរបស់ខ្លួន នៅទីនោះ ប៉ុន្តែប្អូនរបស់ កន មិនស្គាល់បងប្រុសទេ ពីព្រោះ កន បានចាកចេញពីផ្ទះទៅរស់នៅជាមួយឪពុកមាតាំងពីតូចមក។ ក្រោយពីដឹងដំណឹងពីប្អូនថា ឪពុកម្តាយដែលកំពុងដេរស្លឹកនៅក្នុងសហករណ៍ កន ក៏ទៅជួបលោកទាំងពីរដោយក្តីរីករាយ។

នៅទីនោះ ឪពុករបស់ កន ដែលមានឈ្មោះថា ប៊ុត លួន គឺជាប្រធានដំណាំនិងជាអ្នកមូលដ្ឋានមិនពេញសិទ្ធិ រីឯឪពុកមារបស់ កន ដែលឈ្មោះ ងួន គឺជាគណៈឃុំ។

នៅចុងឆ្នាំ១៩៧៦ អង្គការបានចាប់ផ្តើមដើរប្រមូលផ្តុំកម្លាំងដែលធ្វើឲ្យ កន ត្រូវចាត់តាំងឲ្យទៅកងចល័តដោយធ្វើជាប្រធានក្រុមគ្រប់គ្រងសមាជិក១២នាក់។ ក្រោយមក បន្ទាប់ពីប្រឡាយមធ្យមមួយបានជីករួច ខ្មែរក្រហមបានកាប់គោជប់លៀងឲ្យប្រជាជនទាំងអស់គ្នា។ មិនយូរប៉ុន្មាន ស្ថានភាពនៅក្នុងតំបន់ដែល កន រស់នៅក្លាយទៅជាមានភាពតឹងតែងជាងមុន គឺខ្មែរក្រហមតែងតែហៅប្រជាជនឲ្យមកប្រជុំ បន្ទាប់មកមានមនុស្សជាច្រើនបានបាត់ខ្លួន។ ជាក់ស្តែង ទ្រុង និង ទ្រឿង ដែលត្រូវជាសាច់ញាតិ របស់ កន ត្រូវខ្មែរក្រហមហៅទៅសួរសុខទុក្ខពូដែលឈឺខ្លាំងនៅភូមិក្បែរនោះ បន្ទាប់មកក៏បាត់ដំណឹងរហូត។

នៅពាក់កណ្តាលឆ្នាំ១៩៧៧ ខ្មែរក្រហមបានផ្លាស់ កន ឲ្យទៅធ្វើការនៅកងពិសេស ដំបូងឲ្យគាត់លើកភ្លឺ និងជីកប្រឡាយដោយកំណត់តាមទិសនៃត្រីវិស័យ។ ពីរ-បីខែក្រោយមក ខ្មែរក្រហមបានបញ្ជាឲ្យ កន ទៅធ្វើស្រូវប្រាំង ជីកប្រឡាយ និងលើកនិងធ្វើការធ្ងន់ៗជាច្រើនទៀត។ ការងារធ្ងន់ទាំងនោះ រួមជាមួយនឹងរបបអាហារមិនគ្រប់គ្រាន់បានធ្វើឲ្យ កន កើតជំងឺហើម។ ប៉ុន្តែគាត់នៅតែព្យាយាមធ្វើការដើម្បីកុំឲ្យខ្មែរក្រហមធ្វើបាប។ រហូតដល់ចុងឆ្នាំ១៩៧៧ បន្ទាប់ពីខ្មែរក្រហមបានធ្វើមីទ្ទីងរំឭកខួបជ័យជម្នះ១៧មេសាដែលមានការចូលរួមពីគណៈស្រុក ប្រធានឃុំ ប្រធានឈ្លប និងគណៈតំបន់ដែលនិយាយពីការរៀបចំផែនការកែច្នៃជីវភាពនិងប្រមូលចាប់បណ្តាញខ្មាំងនៅក្នុងជួរបដិវត្តន៍ កន ក៏ត្រូវបានផ្លាស់ប្តូរទៅធ្វើការនៅសហករណ៍វិញ។ នៅទីនោះ ដោយ កន មានពូ និងបងគឺជាពេទ្យសង្គមកិច្ច និងឪពុកគឺជាអ្នកមូលដ្ឋានមិនពេញសិទ្ធិ គាត់ត្រូវបានអនុញ្ញាតឲ្យស្នាក់នៅជាមួយពូនៅពេទ្យព្យាបាលជំងឺហើមដែលមិនទាន់ជា។ ក្រោយពីសម្រាកព្យាបាលអស់រយៈពេលប្រហែលកន្លះខែ កន ក៏ចាកចេញពីមន្ទីរពេទ្យទៅធ្វើការលើកប្រព័ន្ធភ្លឺ។

រហូតដល់ចុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានរៀបចំឲ្យ កន រៀបការជាមួយនារីម្នាក់ឈ្មោះ សែ ស៊ុនតាភាវី។ មួយខែក្រោយមក កងទ័ពវៀតណាមបានចូលមកដល់ខេត្តតាកែវដែលធ្វើឲ្យយោធាខ្មែរក្រហមបែកខ្ញែកគ្នានិងជាសញ្ញាណនៃការដួលរលំរបបខ្មែរក្រហម។ ក្រោយមក ឪពុកម្តាយរបស់ កន និងឪពុកម្តាយរបស់ប្រពន្ធគាត់បានរៀបចំឲ្យគាត់ទាំងពីរនាក់រៀបការម្តងទៀតតាមប្រពៃណីទំនៀមទម្លាប់។ នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៧៩ កន ត្រូវបានជ្រើសរើសឲ្យធ្វើគ្រូបង្រៀនថ្នាក់បឋមសិក្សា ហើយនៅឆ្នាំ១៩៨០ គាត់បានប្រឡងធ្វើគ្រូមធ្យម។ បច្ចុប្បន្ន កន គឺជាគ្រូបង្រៀននៅអនុវិទ្យាល័យវត្តបារាយវិហារពីរ និងមានកូនប្រាំនាក់ រីឯប្រពន្ធរបស់គាត់គឺជាគ្រូបឋមសិក្សាដែរ។

**ឌា ផល្លា**

# “ខ្ញុំអាណិតម្តាយខ្ញុំណាស់”

«នៅពេលដែលខ្ញុំហត់នឿយពីការរៀនសាលានិងធ្វើកិច្ចការផ្ទះ ខ្ញុំតែងសម្រាកនិងមិនចង់ធ្វើការអ្វីទាំងអស់ ។ ពេលនោះឪពុកម្តាយខ្ញុំតែងតែស្តីបន្ទោសឲ្យខ្ញុំដោយធ្វើការប្រៀបធៀបទៅនឹងរបបខ្មែរក្រហមថា ខ្ញុំនឹងត្រូវនាំយកទៅដាក់គុក ធ្វើទារុណកម្ម បង្អត់បាយ ឬសម្លាប់ចោលដោយកម្មាភិបាល ខ្មែរក្រហមបើសិនជាខ្ញុំខ្ជិលច្រអូសបែបនេះ ។ ខ្ញុំតែងតែសួរគាត់ពីរឿងនេះ (ខ្មែរក្រហម) នេះ ។ ជួនកាលគាត់ប្រាប់ ជួនកាលគាត់មិនបានប្រាប់ខ្ញុំទេ» ។--ម៉ែន សុភ័ក្រ

ម៉ែន សុភ័ក្រ អាយុ១៦ឆ្នាំ មានស្រុកកំណើតនៅក្នុងភូមិទឹកល្អក់ ឃុំជីផាត ស្រុកថ្មបាំង ខេត្តកោះកុង ជាយុវសិស្សរៀនថ្នាក់ទី៩នៃអនុវិទ្យាល័យជីផាតនិងជាគ្រូបង្រៀនភាសាអង់គ្លេសនៅក្នុងសហគមន៍អេកូទេសចរណ៍ប្រចាំឃុំជីផាត ។ សុភ័ក្រ បានសម្តែងទឹកមុខរីករាយ រួចបានបញ្ជាក់ពីទឹកចិត្តផ្ទាល់ខ្លួនពីចំណេះដឹងបន្ថែមអំពីរបបខ្មែរក្រហមនៅក្នុងវេទិកាសាធារណៈមួយស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដែលបានធ្វើឡើងអស់រយៈពេលពេញមួយព្រឹកកាលពីថ្ងៃទី៩ ខែមករា ឆ្នាំ២០១១នៅក្នុងភូមិជីផាតដែលមានចម្ងាយប្រមាណជាមួយរយគីឡូម៉ែត្រពីទីរួមខេត្តកោះកុង ។ សុភ័ក្រ បានសួរសំណួរទាក់ទងនឹងរបបខ្មែរក្រហមមួយចំនួនដែលខ្លួនមានចម្ងល់ជាយូរមកហើយ ដូចជា តើហេតុអ្វីបានជាមេដឹកនាំខ្មែរក្រហមដឹកនាំប្រទេសឆ្ពោះទៅរកការកាប់សម្លាប់មនុស្ស? តើរបបខ្មែរក្រហមកើតចេញមកពីណា? ហើយហេតុអ្វីបានជារបបនេះត្រូវបានបង្កើតឡើង? ហេតុអ្វីបានជាប្រជាជនត្រូវធ្វើការហួសកម្លាំង និងអត់មានរបបអាហារគ្រប់គ្រាន់? ហេតុអ្វីបានជាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានចំណាយពេលវេលាយូរម្ល៉េះដើម្បីកាត់ទោសមេដឹកនាំទាំងប្រាំរូបនេះ?

ចម្ងល់របស់ សុភ័ក្រ មិនខុសពីចម្ងល់របស់ប្រជាពលរដ្ឋនិងសិស្សានុសិស្សមួយចំនួនដែលបានកប់នៅក្នុងផ្នត់គំនិតជាយូរមកហើយទេ ហើយសំណួរទាំងនេះជាសំណួរដែលមិនមានចម្លើយច្បាស់លាស់សម្រាប់ជនរងគ្រោះអស់រយៈពេលជាង៣០ឆ្នាំកន្លងមកហើយ ។ យុវតីម្នាក់ឈ្មោះ ទុយ រដ្ឋា រៀនថ្នាក់ទី៩នៅអនុវិទ្យាល័យជីផាតដែលតែងតែទទួលបានការរៀបរាប់ពីឪពុកម្តាយអំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម ។ រដ្ឋា តែងសួរសំណួរជាច្រើនទៅកាន់ឪពុកម្តាយទាក់ទងនឹងជីវិតរស់នៅប្រចាំថ្ងៃនិងបុព្វហេតុដែលធ្វើឲ្យកើតមានរបបខ្មែរក្រហម ។

ក្នុងវេទិកាសាធារណៈនេះ អ្នកភូមិមួយចំនួនបានធ្វើការចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនព្រមទាំងបានជួយឆ្លើយសំណួរមួយចំនួនទៅកាន់សិស្សានុសិស្សទាំងអស់ ។ មាស ផល្លី ជាប្រជាជនរស់នៅក្នុងឃុំជីផាតបានរៀបរាប់ពីប្រវត្តិរឿងរ៉ាវរបស់គាត់



ម៉ែន សុភ័ក្រ កំពុងឆ្លើយសំណួរទាក់ទងរបបខ្មែរក្រហម

និងបានជួយឆ្លើយសំណួរមួយដែលទាក់ទងនឹងការហូបមិនគ្រប់គ្រាន់និងការធ្វើការហួសកម្លាំងរបស់ប្រជាជនដោយលើកឡើងពីបទពិសោធន៍របស់គាត់ផ្ទាល់ដែលត្រូវកម្មាភិបាលខ្មែរក្រហមចាប់ចងស្លាបសេកដោយសារគាត់បានលួចដំឡូងមីមួយមើមពីក្នុងចម្ការដែលគាត់បានដាំមកហូបដើម្បីចម្អែតក្រពះ ។ ដល្លី បានបង្ហាញស្នាមដាំនៅលើដើមដៃរបស់គាត់ទាំងពីរព្រមទាំងបានបញ្ជាក់សម្ដីធ្ងន់ខ្លាំងៗថា «ស្នាមនេះគឺជាភ័ស្តុតាងជាក់ស្ដែងដែលបានបន្សល់ទុកតាំងពីជំនាន់ខ្មែរក្រហមដើម្បីទុកឲ្យកូនៗរបស់ខ្ញុំដឹងថាទំរាំបានរស់ដល់ប៉ុណ្ណេះ ខ្ញុំត្រូវឆ្លងកាត់ការលំបាកច្រើនណាស់ ។ លោកអភិបាលរងស្រុកថ្មបាំង កែវ នីបូរ៉ា បានស្រក់ទឹកភ្នែកនៅពេលដែលគាត់រំឭកឡើងវិញពីជីវិតរបស់គាត់នៅក្នុងរបបខ្មែរក្រហមប្រាប់ទៅអ្នកចូលរួមទាំងអស់នៅក្នុងអង្គវេទិកាសាធារណៈព្រមទាំងបានធ្វើការផ្ដាំផ្ញើដល់សិស្សានុសិស្សទាំងអស់ឲ្យខិតខំប្រឹងប្រែងរៀនសូត្រពីប្រវត្តិសាស្ត្ររបស់ខ្លួនដែលបានកើតមានកន្លងមកទាំងប្រវត្តិសាស្ត្រដែលល្អនិងប្រវត្តិសាស្ត្រដែលមិនល្អដូចជាប្រវត្តិសាស្ត្រខ្មែរក្រហមជាដើម ។ ចំណែកលោកជំទប់ឃុំជីផាត ឈួន មិន ក៏បានចែករំលែកប្រវត្តិខ្លះៗទាក់ទងនឹងការកាន់កាប់របស់ខ្មែរក្រហមនៅក្នុងឃុំជីផាតថា ខ្មែរក្រហមបានបង្ខំប្រជាជនទាំងអស់ដែលរស់នៅក្នុងឃុំជីផាតឲ្យទៅលើកទំនប់ជាមួយនឹងប្រជាជនមកពីស្រុកបុទុមសាគរ ។ ក្នុងឆ្នាំ១៩៧៥-១៩៧៦ ប្រជាជនភាគច្រើនបានស្លាប់ដោយសារការធ្វើការហួសកម្លាំងនិងហូបមិនគ្រប់គ្រាន់ ហើយសាកសពត្រូវនាំយកទៅកប់ចោលនៅក្បែរការដ្ឋានលើកទំនប់នេះតែម្ដង ។ ទំនប់នេះមានឈ្មោះហៅថា «ទំនប់ព្រលាន» ដែលលាតសន្ធឹងតាំងពីស្ពានស្រែអំបិលរហូតដល់ស្ពានអណ្ដូងទឹកដែលមានចម្ងាយប្រមាណ ។ នៅដើមឆ្នាំ១៩៧៧ទំនប់នេះបានត្រូវលើករួចរាល់ ហើយប្រជាជនទាំងអស់ត្រូវវិលទៅកាន់ភូមិកំណើតរៀងៗខ្លួនវិញលើកលែងតែប្រជាជនដែលមកពីឃុំជីផាតមួយគត់ដែលត្រូវជម្លៀសឲ្យទៅរស់នៅនិងធ្វើការក្នុងឃុំផ្សេងៗទៀតក្នុងស្រុកបុទុមសាគរនិងស្រុកស្រែអំបិល ។ ទឹកដីឃុំជីផាតទាំងមូលបានក្លាយជាទឹកដីដែលគ្មានប្រជា



សិស្សានុសិស្សនៅវិទ្យាល័យជីផាត ខេត្តកោះកុង ចូលរួមក្នុងវេទិកាសាធារណៈ

ជនរស់នៅលើកលែងតែផ្នែកខ្លះប៉ុណ្ណោះដែលត្រូវកម្មាភិបាលខ្មែរក្រហមប្រើប្រាស់ធ្វើជារោងម៉ាស៊ីនអារឈើ មន្ទីរនានា និងកន្លែងស្នាក់នៅ ។

ក្រៅពីរឿងរ៉ាវទាក់ទងនឹងប្រវត្តិឃុំជីផាត ការជម្លៀស ការធ្វើការហួសកម្លាំងនិងការស្លាប់ដោយអត់អាហារប្រជាជនដទៃទៀតបានសម្តែងនូវការជួបប្រទះផ្ទាល់ពីព្រឹត្តិការណ៍ផ្សេងៗទៀតដូចជា ការបំបែកក្រុមគ្រួសារ ការសម្លាប់ និងការដកហូតកម្មសិទ្ធិផ្ទាល់ខ្លួនធ្វើជាសម្បត្តិសមូហភាព ។ សុភ័ក្រ បានរំឭកប្រាប់ថា «ម្តាយខ្ញុំបាននិយាយប្រាប់ខ្ញុំថា គាត់មិនដែលបានឃើញមុខម្តាយគាត់ឡើយ ព្រោះខ្មែរក្រហមបានបំបែកម្តាយគាត់ឲ្យទៅកាន់កងផ្សេង ហើយគាត់ត្រូវបានបញ្ជូនទៅកាន់កងកុមារដែលមិនដែលបានមកជួបគ្នាទាល់តែសោះរហូតមកដល់បច្ចុប្បន្ននេះ ។ ខ្ញុំបានដឹងទៀតថា នៅក្នុងរបបខ្មែរក្រហម ប្រជាជនគ្រប់រូបហូបមិនឆ្អែតឡើយ ហើយត្រូវធ្វើការទាំងយប់ទាំងថ្ងៃ ។ ម្តាយរបស់ខ្ញុំបានត្អូញត្អែរថា សម័យនេះស្រួលហើយ មិនចង់ធ្វើការក៏បានដែរគ្មាននរណារករឿង ឬមកបង្ខិតបង្ខំ ឬគំរាមរកសម្លាប់ដោយសារភាពខ្ជិលទាំងអស់នេះឡើយ ។ ប៉ុន្តែនៅក្នុងសម័យគាត់វិញ (ខ្មែរក្រហម) មិនស្រួលអ៊ីចឹងទេ» ។ ខ្ញុំមានសំណួរជាច្រើនសួរទៅគាត់ទាក់ទងពីរឿងខ្មែរក្រហម ។ មានសំណួរខ្លះគាត់មិនបានឆ្លើយប្រាប់ខ្ញុំទេ ប៉ុន្តែគាត់បែរជាផ្លាស់ប្តូរទឹកមុខ និងបានបង្ហូរទឹកភ្នែកដែលអាចបញ្ជាក់ប្រាប់ខ្ញុំវិញថា ជាសំណួរដែលមិនគួរសួរទៅកាន់គាត់តទៅទៀតទេ ហើយខ្ញុំគិតថាសំណួរនេះគឺពិតជាសំណួរមួយដែលធ្ងន់ធ្ងរ និងធ្វើឲ្យប៉ះពាល់ដល់អារម្មណ៍របស់ម្តាយខ្ញុំជាខ្លាំង ។ ខ្ញុំអាណិតម្តាយខ្ញុំណាស់» ។ ក្រុមគ្រួសាររបស់ រដ្ឋា ក៏មានសាច់រឿងមិនសូវខុសគ្នាប៉ុន្មានពីគ្រួសាររបស់ សុភ័ក្រ ដែរ ។ ម្តាយរបស់ រដ្ឋា មិនដែលបានស្គាល់មុខម្តាយរបស់គាត់ឡើយ ព្រោះត្រូវកម្មាភិបាលខ្មែរក្រហមបំបែកតាំងពីគាត់មានអាយុពីរឆ្នាំមកម្ល៉េះ ។ ចំណែកប្អូនប្រុសរបស់ម្តាយ រដ្ឋា វិញ បានបាត់ខ្លួនរហូតមកដល់សព្វថ្ងៃនេះ ។

នៅចុងឆ្នាំ១៩៧៨ ប្រជាជនភាគច្រើននៅក្នុងភូមិទឹកល្អក់ ឃុំជីផាត ត្រូវបានប្រមូលផ្តុំឲ្យនៅមួយកន្លែង ដើម្បីទទួលផែនការឲ្យទៅរៀនសូត្រនៅកន្លែងឆ្ងាយពីភូមិ ។ សុភ័ក្រ បានពន្យល់តាមអ្វីដែលម្តាយខ្លួនបានប្រាប់ថា ពាក្យ «រៀនសូត្រ» មានន័យថា «នាំយកទៅសម្លាប់» ។ «នៅសល់តែរយៈពេលប្រាំថ្ងៃទៀតប៉ុណ្ណោះដែលគ្រួសារខាងម្តាយខ្ញុំត្រូវខ្មែរក្រហមនាំយកទៅរៀនសូត្រប៉ុន្តែបែជន្យត្រូវកងទ័ពរំដោះបាននៅឆ្នាំ១៩៧៩» នេះជាសម្តីរបស់ សុភ័ក្រ ក្នុងពេលធ្វើសម្ភាស ។ ចំណែកក្រុមគ្រួសារខាងឪពុករបស់ សុភ័ក្រ វិញ ក៏មានស្លាប់ច្រើននៅក្នុងរបបខ្មែរក្រហមដែរ ក្រោមពាក្យចោទប្រកាន់ថាជា «ជនក្បត់ជាតិ» ។ សុភ័ក្រ និយាយថា «ឪពុករបស់ខ្ញុំជាអ្នកបេះដូងមួយរូបដែរហើយខ្សែស្រឡាយរបស់គាត់ភាគច្រើនត្រូវបានចាប់ខ្លួននិងសម្លាប់» ។



រយៈពេលជាងសាមសិបឆ្នាំក្រោយរបបខ្មែរក្រហម ប្រវត្តិរឿងរ៉ាវនៅក្នុងឃុំជីផាតត្រូវបានលាតត្រដាងហើយប្រជាជនដែលកំពុងរស់នៅក្នុងឃុំនេះនិងជាអតីតប្រជាជនថ្មីដែលបានចូលមករស់នៅក្នុងទឹកដីនេះក្នុងអំឡុងទសវត្សរ៍៨០ បានស្វែងយល់ច្បាស់អំពីប្រវត្តិរឿងរ៉ាវនេះ ហើយសិស្សានុសិស្សដែលកំពុង

សិក្សានិងមានដើមកំណើតនៅក្នុងឃុំនេះដែរបានសម្តែងនូវការជឿជាក់ពីភាពកើតមានរបបខ្មែរក្រហមនៅក្នុងឃុំរបស់ខ្លួនរស់នៅក៏ដូចជានៅក្នុងសង្គមកម្ពុជាទាំងមូល ។

តាមសម្តីរបស់លោកអភិបាលរងស្រុក ក៏ដូចជាលោកមេឃុំ និងលោកជំទប់ឃុំជីផាតបានឲ្យដឹងថា ប្រជាជនដែលរស់នៅក្នុងឃុំជីផាតទាំងអស់មិនដែលទទួលបានការផ្តល់ឱកាសឲ្យមានការពិភាក្សា ស្វែងយល់ពីរបបខ្មែរក្រហមរបៀបនេះពីមុនមកទេ ហើយលើកនេះគឺពិតជាលើកដំបូងដែលធ្វើឲ្យសិស្សានុសិស្សនិងប្រជាជនភាគច្រើនមានការយល់ដឹងច្រើនពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ជាពិសេសរឿងរ៉ាវផ្ទាល់ខ្លួនដែលបានកប់បាត់អស់រយៈពេលជាងសាមសិបឆ្នាំកន្លងមកត្រូវបានលើកមកនិយាយដើម្បីជាឧទាហរណ៍ជាក់ស្តែងមួយឆ្លើយតបទៅនឹងមេរៀនអំពីរបបខ្មែរក្រហមដែលមាននៅក្នុងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលបាននឹងកំពុងដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់ក្រសួង



*សិស្សានុសិស្សនៅវិទ្យាល័យជីផាតចូលរួមក្នុងវេទិការសាធារណៈ*

អប់រំ យុវជន និង កីឡា ។

នៅចុងបញ្ចប់កម្មវិធីនៃវេទិកាសាធារណៈ លោកអភិបាលរងស្រុកថ្មបាំងបានផ្តាំផ្ញើដល់ប្រជាពលរដ្ឋទាំងអស់ឲ្យជួយចែករំលែករឿងរ៉ាវផ្ទាល់ខ្លួនដល់កូនៗរបស់ខ្លួន ព្រមទាំងជួយឆ្លើយរាល់សំណួរផ្សេងៗទាក់ទងនឹងរបបខ្មែរក្រហមដែលសួរដោយកូនរបស់ខ្លួន ។ លើសពីនេះទៀត លោកអភិបាលរងស្រុកក៏បានណែនាំដល់សិស្សានុសិស្សទាំងអស់ឲ្យយកចិត្តទុកដាក់ក្នុងការរៀនសូត្រជាពិសេសរៀនអំពីប្រវត្តិសាស្ត្រខ្មែរក្រហមដើម្បីជាចំណេះដឹងក្នុងការទប់ស្កាត់រាល់ការវិលត្រឡប់របស់របបប្រល័យពូជសាសន៍មកកម្ពុជាជាលើកទីពីរទៀត ។ លោកអភិបាលស្រុកក៏បានបន្ថែមទៀតថា ការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺមានសារសំខាន់ណាស់ព្រោះជាការបង្កើតឲ្យមានការផ្សះផ្សាគ្នារវាងជនរងគ្រោះ និងជនដៃដល់តាំងពីថ្នាក់មូលដ្ឋាន រហូតដល់ថ្នាក់ជាតិទាំងមូល និងជាការកសាងសន្តិភាពសម្រាប់ប្រទេសកម្ពុជាទាំងមូលដែរ ។ **ផេង ពង្សរ៉ាស៊ី**

# ពិធីសម្ពោធពាក្យស្លោក និងចែកចាយសៀវភៅនៅ












# វិទ្យាល័យច្បារអំពៅ ថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០១១











# គេហទំព័រឃ្លាំមើលតុលាការខ្មែរក្រហម

គម្រោងឃ្លាំមើលតុលាការខ្មែរក្រហម ផ្តោតទៅលើការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីផ្តល់ឱកាសឲ្យសាធារណជនទូទៅអាចទទួលបានព័ត៌មានថ្មីៗ និងទាន់ហេតុការណ៍ អានឯកសាររបស់សាលាក្តីខ្មែរក្រហម ទស្សនាខ្សែវីដេអូខ្លីៗ និងតាមដានប្រភពព័ត៌មានផ្សេងទៀតអំពីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

គេហទំព័រ www.cambodiatribunal.org ផ្ទុកព័ត៌មានអំពីរឿងរ៉ាវដែលបានកើតឡើងនិងកំពុងដំណើរការ នៅសាលាក្តីខ្មែរក្រហម ។ សវនាការបុរេជំនុំជម្រះ ដំណើរការកាត់ទោស និងព័ត៌មានផ្សេងទៀតអាចរកបាននៅក្នុងគេហទំព័រនេះ ។

នាពេលបច្ចុប្បន្ននេះ គម្រោងឃ្លាំមើលតុលាការខ្មែរក្រហមកំពុងធ្វើការជាមួយសាកលវិទ្យាល័យចំនួន៤២ក្នុងរាជធានីភ្នំពេញ ដើម្បីផ្តល់ព័ត៌មានសំខាន់ៗមួយចំនួនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងផ្តល់ព័ត៌មានទាន់ហេតុការណ៍ថ្មីៗអំពីដំណើរការសាលាក្តីខ្មែរក្រហមដល់និស្សិត ។ គោលបំណងនៃគម្រោងនេះគឺដើម្បីស្តាប់ប្រតិកម្មពីនិស្សិតទាក់ទងនឹងការកាត់ទោសមេដឹកនាំខ្មែរក្រហមនិងដើម្បីលើកទឹកចិត្តនិស្សិតសាកលវិទ្យាល័យឲ្យកាន់តែសកម្មឡើងក្នុងការជជែកជាមួយឪពុកម្តាយ និងជីដូនជីតារបស់ខ្លួនទាក់ទងនឹងរបបខ្មែរក្រហម ។ និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហមគឺនិយាយពីការផ្សះផ្សា អប់រំកូនចៅ អត់ឱន អធ្យាស្រ័យគ្នា ។

ព័ត៌មានបន្ថែមទាក់ទងនឹងកម្មវិធីផ្សព្វផ្សាយតាមសាកលវិទ្យាល័យនានា សូមទាក់ទង វ៉ាន់ថាន់ ពៅដារ៉ា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០១២ ៨៤៦ ៥២៦ ។



នាយករង វ៉ាន់ថាន់ ពៅដារ៉ា បង្ហាញពីគេហទំព័រឃ្លាំមើលតុលាការខ្មែរក្រហមដល់និស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្ម

# សាសនាអ៊ីស្លាមកំពុងមានការផ្លាស់ប្តូរនៅកម្ពុជា ៖

## ជម្លោះផ្ទៃក្នុងនៅក្នុងសហគមន៍ចាមអ៊ីម៉ាំសាន់ នៅស្រុកកំពង់ត្រឡាច

ភូមិមួយនៅក្នុងសហគមន៍ចាមអ៊ីម៉ាំសាន់ ក្នុងស្រុកកំពង់ត្រឡាចបានសម្រេចចិត្តសាងសង់វិហារអ៊ីស្លាមដាច់ដោយឡែកមួយផ្សេងទៀត ដែលមានចម្ងាយ៤៥០ម៉ែត្រពីវិហារអ៊ីស្លាមចាស់ ដោយសារតែការមិនយល់ស្របគ្នានៅក្នុងបណ្តាអ្នកដឹកនាំសាសនានៅក្នុងសហគមន៍ ។ សាសនាអ៊ីស្លាមកំពុងមានការផ្លាស់ប្តូរនៅកម្ពុជា ។ អ្នកកាន់សាសនាអ៊ីស្លាមកំពុងតែទទួលបានផលប្រយោជន៍ពីការផ្លាស់ប្តូរទាំងនេះហើយជំនួយអន្តរជាតិតាមរយៈស្ថាប័នសាសនាអ៊ីស្លាមនៅលើសកលលោកកំពុងកែប្រែវិធីប្រណិប័តន៍ទាំងនេះដោយអនុលោមតាមការចង់បាននិងគោលការណ៍របស់ម្ចាស់ជំនួយ ។ អ្នកប្រណិប័តន៍តាមអ៊ីម៉ាំសាន់នៅតែអនុវត្តប្រព័ន្ធជំនឿរួមគ្នារវាងខ្មែរ-ចាម-អ៊ីស្លាមជាប្រវត្តិសាស្ត្រដែលស្ថិតនៅក្រោមសម្ពាធយ៉ាងខ្លាំងដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរ ។

សាសនាអ៊ីស្លាមនៅកម្ពុជាមានបីនិកាយរួមមាន សាសនាអ៊ីស្លាមបែបតឹងរ៉ឹងដែលបង្គាប់បញ្ជាឲ្យអ្នកកាន់សាសនាអ៊ីស្លាមភាគច្រើននៅកម្ពុជាអនុវត្តតាម ជនជាតិជ្វានៅតំបន់ឆ្នេរសមុទ្រនៃប្រទេសកម្ពុជា និងក្រុមអ៊ីម៉ាំសាន់នៅកម្ពុជា ។ ក្រុមអ្នកកាន់សាសនាអ៊ីស្លាមបែបតឹងរ៉ឹងប្រណិប័តន៍តាមសាលាសាហ្វ៊ីអ៊ីនៃសាសនាអ៊ីស្លាមស៊ុននី ។ អ្នកកាន់សាសនាដែលជាជនជាតិជ្វានិងក្រុមអ៊ីម៉ាំសាន់ដើរតាមគន្លងផ្សេងគ្នានៃសាសនាអ៊ីស្លាមស៊ុហ្វី ។ សាសនាអ៊ីស្លាមនៅកម្ពុជាប្រមាណជា៨០ភាគរយគឺជាអ្នកកាន់សាសនាប្រកាន់តឹងដែលមានទំនាក់ទំនងច្រើនបំផុតនិងទទួលឥទ្ធិពលមកពីពិភពមូស្លីម ។ ការប្រណិប័តន៍សាសនាអ៊ីស្លាមបែបតឹងរ៉ឹងនេះមានលក្ខណៈស្រដៀងគ្នាយ៉ាងខ្លាំងទៅនឹងអ្នកដែលបានប្រណិប័តន៍នៅក្នុងពិភពមូស្លីមភាគច្រើន ។ អ្នកប្រណិប័តន៍ទាំងនេះថ្វាយបង្គំប្រាំដងក្នុងមួយថ្ងៃ ។ សម្រាប់សមាជិកខ្លះនៅក្នុងក្រុមប្រកាន់សាសនាតឹងរ៉ឹងនេះជាពិសេសអ្នកដែលរស់នៅស្រុកស្វាយឃ្លាំង ក្នុងខេត្តកំពង់ចាម សត្វឆ្កែត្រូវបានហាមឃាត់ក្នុងការយកមកចិញ្ចឹមនៅផ្ទះព្រោះសត្វឆ្កែត្រូវបានចាត់ទុកថាជាសត្វមិនស្អាតស្អំ ។ ក្រុមអ្នកប្រណិប័តន៍ទាំងនេះត្រូវបានគេជឿថាមានប្រភពមកពីដែនដីចម្ប៉ា ហើយភាគច្រើនទទួលឥទ្ធិពលមកពីការប្រណិប័តន៍បែបតឹងរ៉ឹងដោយវរជនចាមដែលមកប្រទេសកម្ពុជា ។ ដោយសារឥទ្ធិពលមកពីការប្រណិប័តន៍ពីពិភពខាងក្រៅតាមរយៈ



ក្រុមអ៊ីម៉ាំសាន់ប្រារព្ធពិធីបុណ្យម៉ាឡុតនៅស្រុកកំពង់ត្រឡាច ឆ្នាំ២០១១

អង្គការមនុស្សធម៌នានាពីប្រទេសគុយវ៉ែត អារ៉ាប់ប៊ីសាអូឌីត ម៉ាឡេស៊ី និងបណ្តាប្រទេសផ្សេងទៀត ការប្រណិប័តន៍ដោយលាយបញ្ចូលគ្នាជាមួយវប្បធម៌ក្នុងស្រុកចាប់ផ្តើមសាបរលាបពីមួយឆ្នាំទៅមួយឆ្នាំ ។ ដោយសារឥទ្ធិពលនេះ ការប្រណិប័តន៍សាសនាអ៊ីស្លាមមានលក្ខណៈកាន់តែតឹងរ៉ឹងឡើង ។

ជនជាតិជ្វាភាគច្រើនរស់នៅតាមតំបន់ឆ្នេរសមុទ្រនៃប្រទេសកម្ពុជា ។ ជ្វាអ៊ីស្លាមនេះមានសមាជិកប្រហែលជាបួន

ម៉ឺននាក់ ។ ក្រុមនេះមិនចេះនិយាយភាសាចាមទេ ។ ក្រុមនេះត្រូវបានគេស្គាល់ថាជ្វាដែលមានកំណើតមកពីប្រជុំកោះនានានៅអាស៊ីអាគ្នេយ៍ក្នុងនាមជាអ្នកធ្វើពាណិជ្ជកម្មតាមសមុទ្រ ។ ក្រុមនេះក៏ត្រូវបានគេជឿថាជាអ្នកកាន់សាសនាអ៊ីស្លាមដើមដែលបានកែប្រែជនភៀសខ្លួនចាមពីសាសនាហិណ្ឌូឲ្យកាន់សាសនាអ៊ីស្លាមវិញ នៅពេលដែលក្រុមនេះមកដល់ប្រទេសកម្ពុជាលើកដំបូងបន្ទាប់ពីវៀតណាមបានកាន់កាប់រាជធានីរបស់ចម្ប៉ាកាលពីឆ្នាំ១៤៧១ ។ ក្រុមនេះក៏ទំនងជាក្រុមដែលទទួលឥទ្ធិពលពីការសម្រេចចិត្តរបស់ឈ្មោះ អ៊ីម៉ាំសាន់ ដែលប្រកាន់សាសនាអ៊ីស្លាមបែបបុរាណហើយបានស្លាប់និងបូជានៅលើកំពូលភ្នំឧត្តុង្គដែលជាអតីតរាជធានីរបស់ប្រទេសកម្ពុជា ។ ក្រុមអ៊ីម៉ាំសាន់ គឺជាក្រុមតូចជាងគេបំផុតក្នុងចំណោមក្រុមទាំងបី ហើយមានចំនួនប្រហែលជាបីម៉ឺនប្រាំបីពាន់នាក់ប៉ុណ្ណោះ ។ ក្រុមនេះភាគច្រើនរស់នៅស្រុកកំពង់ត្រឡាចខេត្តកំពង់ឆ្នាំង ប៉ុន្តែក៏ឃើញមាននៅតាមបណ្ដាខេត្តមួយចំនួនដែរដូចជា កណ្ដាល ពោធិ៍សាត់ បាត់ដំបង និង កំពតដែរ ។ ឧកញ៉ាឃ្លូរ កៃទាំ ដែលជាអ្នកដឹកនាំក្រុមអ៊ីម៉ាំ សាន់ បានរៀបរាប់ថា


ក្រុមអ៊ីម៉ាំសាន់ប្រារព្ធពិធីបុណ្យម៉ាឡុតនៅស្រុកកំពង់ត្រឡាច

ចម្ប៉ាដើម្បីធ្វើការផ្លាស់ប្តូរដ៏ធំមួយទៅកាន់សាសនាអ៊ីស្លាមតាមរយៈទំនាក់ទំនងពាណិជ្ជកម្មរវាងចម្ប៉ា សូម៉ាត្រា ឧបទ្វីបម៉ាឡេស៊ី និងពាណិជ្ជករមកពីមជ្ឈិមបូព៌ា ។ ក្រុមជ្វាអ៊ីស្លាមមិនសូវប្រណិប័តន៍តឹងរ៉ឹងដូចក្រុមទីមួយទេ ។ ក្រុមនេះធ្វើការថ្វាយបង្គំតែម្ដងគត់ក្នុងរយៈពេលប្រាំពីរថ្ងៃ ហើយវប្បធម៌របស់ក្រុមនេះមានលក្ខណៈស្រដៀងគ្នាយ៉ាងខ្លាំងទៅនឹងវប្បធម៌ខ្មែរភាគច្រើន ។

ក្រុមទីបីគឺអ្នកដើរតាមក្រុមអ៊ីម៉ាំសាន់ដែលជាអ្នកកាន់ប្រពៃណីចាមដ៏ខ្ជាប់ខ្ជួន ។ ក្រុមនេះមានមេដឹកនាំដំបូងបំផុតបច្ចុប្បន្ននេះមានវិហារអ៊ីស្លាមស៊ូរ៉ាវចំនួន៥៣សម្រាប់ក្រុមអ៊ីម៉ាំសាន់នៅកម្ពុជា ។ ក្រុមអ៊ីម៉ាំសាន់ត្រូវក្រុមពីរផ្សេងទៀតចាត់ទុកថាជាក្រុមដែលមិនតឹងរ៉ឹងក្នុងការប្រណិប័តន៍សាសនា អ៊ីស្លាម ព្រោះក្រុមអ៊ីម៉ាំសាន់នេះថ្វាយបង្គំតែម្ដងគត់ក្នុងរយៈពេលប្រាំពីរថ្ងៃ ។ លក្ខណៈនៃការថ្វាយបង្គំ ការប្រណិប័តន៍សាសនាអ៊ីស្លាមនិងប្រពៃណីប្រចាំថ្ងៃក៏មានលក្ខណៈផ្សេងគ្នាពីក្រុមផ្សេងទៀតដែរ ។ ឧទាហរណ៍ ដូចជាក្រុមនេះមិនលុបមុខទេ ក្រោយពេលថ្វាយបង្គំ បុរសមិនចាំបាច់ទុកពុកចង្កាវែងៗទេ ។ មួកសម្រាប់បុរសប្ញុស្តគក៏មិនមានលក្ខណៈដូចជាមួកដែរដែលពាក់

នៅជុំវិញក្បាលដូចក្រុមទីមួយដែរ ។ បុរសខ្លះបានប្រើក្រមារបស់ខ្មែរជាគ្រឿងសម្រាប់ពាក់ពីលើក្បាល ។ ហេតុដូច្នេះគេអាចមើលឃើញថា គ្រឿងសម្រាប់រុំក្បាលមិនបានធ្វើតាមគោលការណ៍ណាមួយច្បាស់លាស់ទេចំពោះបុរស ។ បុរសខ្លះជួតកន្សែងពណ៌សជុំវិញក្បាលដូចខ្មែរដែរ ប៉ុន្តែមិនរុំក្បាលជិតទេ ។ បុរសចំណាស់ៗស្លៀកពាក់ខោជើងវែង អាវដៃវែង ពណ៌សរបៀបសាមញ្ញ ។ បើសិនជាមិនពាក់កន្សែងនៅលើក្បាល ក្រុមនេះមើលទៅដូចជាបុព្វជិតរបស់ពុទ្ធសាសនាអ៊ីចឹងដែរ ។ ក្នុងអំឡុងពេលពិធីបុណ្យម៉ាឡូត បុរសដែលនៅលីវពាក់រ៉ូបពណ៌បៃតង ចំណែកឯបុរសដែលរៀបការរួចពាក់រ៉ូបពណ៌ខ្មៅ ។ ប៉ុន្តែទាំងបុរសនៅលីវឬមិននៅលីវមិនពាក់កន្សែងរុំក្បាលក្នុងលក្ខណៈជាអ៊ីស្លាមទេ ។

ក្រុមអ៊ីមុាំសាន់ធ្វើការប្រណិប័តន៍តាមសាសនាអ៊ីស្លាមពីអ៊ីមុាំសាន់ដែលជាអ្នកកាន់សាសនាដ៏អាថ៌កំបាំង និងល្បីល្បាញមួយរូបដែលត្រូវបានទទួលស្គាល់ដោយព្រះមហាក្សត្រកម្ពុជា ហើយព្រះមហាក្សត្របានផ្តល់ព្រះរាជសិទ្ធក្នុងការសាងសង់វិហារនៅជើងភ្នំឧត្តុង្គ ។ អ៊ីមុាំ សាន់ គឺជាអ្នកប្រឹក្សាដ៏ជិតស្និទ្ធម្នាក់របស់ព្រះមហាក្សត្រ ។ អ្នកកាន់សាសនាអ៊ីស្លាមខ្លះនិយាយថា អ៊ីមុាំសាន់ បេះធ្វើមន្តអាគមន៍ ដែលបញ្ជាក់ពីឥទ្ធិពលនៃសាសនាហិណ្ឌូ ។ វិធីប្រណិប័តន៍របស់អ៊ីមុាំសាន់គឺមានលក្ខណៈប្លែក និងខ្លាំងល្មមគ្រប់គ្រាន់ដែលកំណត់បញ្ជាឲ្យអ្នកប្រណិប័តន៍តាមមានការតាំងចិត្តខ្ពស់ ។ សព្វថ្ងៃនេះ ក្រុមអ៊ីមុាំសាន់នេះកំពុងស្ថិតនៅក្នុងដំណាក់កាលវង់គ្រោះដោយការជ្រាបចូលក្នុងក្រុមភាគច្រើនមកពីនិកាយស៊ុអ៊ិត ។ ក្រុមអ៊ីមុាំសាន់ ត្រូវបានគេសន្មតថានិយាយភាសាចាម និងសរសេរអក្សរចាមច្រើនជាងក្រុមផ្សេងទៀត ។ ក្រុមនេះក៏ជឿថាខ្លួនគឺជាអ្នកអភិរក្សមរតកវប្បធម៌ចាមដើមដែរ ។ យោងទៅតាម ឧកញ៉ា យូរ កែទាំ ចំនួនអ្នកប្រណិបត៌ន៍នោះបានថយចុះ ។ អង្គការមនុស្សធម៌ខ្លះបានផ្តល់ជំនួយអភិវឌ្ឍសហគមន៍ដោយកំណត់លក្ខខណ្ឌខ្លះឲ្យអ្នកទាំងនោះប្រណិបត៌ន៍តាម ឧទាហរណ៍គឺការថ្វាយបង្គំប្រាំដងក្នុងមួយថ្ងៃ ។ អ្នកកាន់សាសនាអ៊ីស្លាមខ្លះជឿថា វិធីនៃការប្រណិបត៌ន៍សាសនាអ៊ីស្លាមរបស់ខ្លួនឆ្ពះបញ្ចាំងពីការខ្វះខាតការយល់ដឹងពីសាសនាអ៊ីស្លាមឲ្យបានទូលំទូលាយជាងនេះ ។ ឧស្ទាន ហាសាន់ ជឿថានៅពេលដែលក្រុមនេះយល់ថាខ្លួនខុសពីក្រុមមូស្លីមផ្សេងទៀតនៅក្នុង «ពិភពលោក» អ្នកទាំងនោះនឹងផ្លាស់ប្តូរ ។ ប៉ុន្តែ ឧស្ទាន ហាសាន់ មិនចង់បង្ខំឲ្យអ្នកទាំងនោះផ្លាស់ប្តូរ ឬផ្តល់ជំនួយដោយដាក់លក្ខខណ្ឌឲ្យផ្លាស់ប្តូរនោះទេ ។ ប៉ុន្តែ អ៊ីមុាំសាន់ ជឿថា ខ្លួនកំពុងដែលនៅជិតព្រះរួចទៅហើយ ដូច្នេះមិនចាំបាច់គោរពប្រាំដងក្នុងមួយថ្ងៃទេ ។

ថ្មីៗនេះ មានបញ្ហាវិវាទមួយនៅក្នុងក្រុមអ៊ីមុាំសាន់ ។ នៅក្នុងឃុំអូរបុស្សី ស្រុកកំពង់ត្រឡាច មានភូមិចាមបីគឺ ភូមិចាន់កៀក ភូមិអូរបុស្សី និងភូមិស្រែប្រិយ ។ ភូមិចាន់កៀកមាន ២០៥គ្រួសារ ភូមិអូរបុស្សីមាន១៦០គ្រួសារ ហើយភូមិស្រែប្រិយមាន២៨០គ្រួសារ ។ ភូមិនីមួយៗមានអ្នកគ្រប់គ្រងម្នាក់ ហើយក៏មានអ៊ីមុាំម្នាក់សម្រាប់គ្រប់គ្រងទៅលើការប្រណិបត៌ន៍សាសនានៅក្នុងសហគមន៍ដែរ ។ ឆ្នាំមុន បុណ្យម៉ាឡូតត្រូវបានប្រារព្ធឡើងនៅក្នុងស៊ូរ៉ាវឃុំនៅក្នុងភូមិស្រែប្រិយ ដែលមានមេដឹកនាំអ៊ីមុាំសាន់ឈ្មោះ កែទាំ ជាអ្នកគ្រប់គ្រងទៅលើពិធីបុណ្យ ។ ពីរឆ្នាំមុន ភូមិទាំងបីបានប្រារព្ធពិធីបុណ្យម៉ាឡូតដាច់ដោយឡែកពីគ្នាដែលធ្វើឲ្យ កែទាំ មិនយល់ស្របជាខ្លាំង ។ ភូមិអូរបុស្សីបានសាងសង់ស៊ូរ៉ាវមួយសម្រាប់ភូមិ ។ ភូមិចាន់កៀក ក៏បានសាងសង់ម៉ាស្ជិតថ្មីមួយដែរ ។

ការសម្រេចរបស់ភូមិចាន់កៀកឲ្យប្រារព្ធពិធីបុណ្យដាច់ដោយឡែកពីគ្នាបានបង្កឲ្យមាន ជម្លោះរវាង កែទាំ និងអ្នកភូមិចាន់កៀកដែលដឹកនាំដោយ អ៊ីមុាំឈ្មោះ ស៊ូ លី ។ កែទាំ បាននិយាយថា គាត់មិនមានការយល់ទាស់ទៅលើភូមិអូរបុស្សីដែលប្រារព្ធពិធីបុណ្យដាច់ដោយឡែកពីគ្នាទេ ពីព្រោះវាយោងទៅតាមច្បាប់ និងការប្រណិបត៌ន៍ប្រពៃណីដាច់ដោយឡែកពីគ្នា ។ យោងទៅតាម កែទាំ បានឲ្យដឹងថា ច្បាប់បានចែងថា សហគមន៍មួយអាចសាងសង់ម៉ាស្ជិតឬស៊ូរ៉ាវដាច់ដោយឡែកពីគ្នានៅពេលដែលទីតាំងម៉ាស្ជិត ឬស៊ូរ៉ាវចាស់មានចម្ងាយពីរគីឡូម៉ែតពីម៉ាស្ជិត ឬស៊ូរ៉ាវថ្មី ។ នៅពេលដែលចម្ងាយនោះស្ថិតនៅក្នុងទីធ្លាវាលស៊ូរ៉ាវឬម៉ាស្ជិតថ្មីត្រូវតែសាងសង់ឲ្យឆ្ងាយដែលមិនអាចមើលឃើញដោយភ្នែក ។ ប្រសិនបើទីតាំងនោះត្រូវបានគ្របដណ្តប់ដោយព្រៃឈើ ស៊ូរ៉ាវឬម៉ាស្ជិតត្រូវតែសាងសង់ដោយមិនឲ្យពុ

សំឡេងវាយស្គរពីស៊ូរ៉ាវ ឬម៉ាស្ជិតមួយទៀត។ ប្រសិនបើមានទន្លេនៅក្នុងភូមិដែលផ្ដល់ការលំបាកក្នុងការធ្វើដំណើរទៅកាន់ស៊ូរ៉ាវ ឬម៉ាស្ជិតដើម គេអាចសាងសង់ម៉ាស្ជិតថ្មីមួយទៀតនៅទន្លេម្ខាងទៀត។ កែទាំ បាននិយាយថា ការសម្រេចរបស់ ស៊ូ លី ក្នុងការសាងសង់ម៉ាស្ជិតថ្មីមួយទៀតមិនបានស្របទៅតាមច្បាប់ទាំងនេះទេពីព្រោះទីតាំងម៉ាស្ជិតថ្មីមានចម្ងាយត្រឹមតែ៤៥០ម៉ែត្រពីម៉ាស្ជិតចាស់ប៉ុណ្ណោះ។

ស៊ូ លី បានពន្យល់ថា កាលពីមុនភូមិនៅក្នុងឃុំមានទំហំតូច។ ប៉ុន្ដែបច្ចុប្បន្នគេបានពង្រីកជាច្រើនលើកច្រើនសា។ ម៉ាស្ជិតចាស់មានទំហំតូចពេកមិនអាចដាក់អ្នកភូមិទាំងអស់បានទេ។ គាត់ក៏បានលើកឡើងដែរថា ភូមិអូរឫស្សីបានបែកចេញពីគ្នាទៅហើយ ដូច្នេះគាត់ក៏ចង់មានម៉ាស្ជិតសម្រាប់ភូមិគាត់មួយដែរ។ គាត់និងអ្នកភូមិគាត់បាននិយាយថា សហគមន៍ជាច្រើនកំពុងតែអភិវឌ្ឍ និងផ្លាស់ប្ដូរដោយមានជំនួយពីបរទេសដូចជា អង្គការមនុស្សធម៌គុយវ៉ែត ដូច្នេះគាត់ចង់ឲ្យភូមិមានមុខមាត់ថ្មី និងមានម៉ាស្ជិតថ្មីដែលសាងសង់ឡើងសម្រាប់អ្នកភូមិ និងកូនចៅរបស់គេ គឺជួយពីការទៅម៉ាស្ជិតដដែលមួយដែលប្រើរួមគ្នានៅក្នុងឃុំ។ ស៊ូ លី បានបន្ថែមទៀតថា ថ្មីៗនេះអង្គការមួយរបស់គុយវ៉ែតនឹងផ្ដល់ជំនួយដល់ការសាងសង់ម៉ាស្ជិតថ្មី ប៉ុន្ដែប្រសិនបើអ្នកទាំងនោះបង្ខំឲ្យគាត់ថ្វាយបង្គំប្រាំដងក្នុងមួយថ្ងៃ គាត់នឹងមិនទទួលជំនួយនោះទេ។ ស៊ូ លី បាននិយាយទៀតថា លក្ខខណ្ឌដែល កែទាំ បានលើកឡើងក្នុងគោលបំណងរារាំងគាត់មិនឲ្យសាងសង់ម៉ាស្ជិតថ្មីមិនមានចែងនៅក្នុងសេចក្ដីណែនាំជាលាយលក្ខណ៍អក្សរអ្វីទេ។ គាត់បានសង្កត់ធ្ងន់ថា អ្នកទាំងនោះមិនមានគោលបំណងជាក់ស្ដែងអ្វីទេ បន្ទាប់មកគាត់បានលើកឡើងថា កាលណាម៉ាស្ជិតអ៊ីស្លាមសាងសង់បានកាន់តែច្រើន វាកាន់តែល្អចំពោះអ៊ីស្លាម។

ជម្លោះខាងលើគឺជាជម្លោះរវាងមេដឹកនាំនិងអ្នកប្រណិប័ន៍សាសនា។ នេះក៏ជាជម្លោះរវាងការអភិរក្ស និងការអភិវឌ្ឍន៍ឲ្យទំនើបដែលស្ថិតនៅក្រោមសម្ពាធនៃការផ្លាស់ប្ដូររបស់អ៊ីស្លាមនៅក្នុងកម្ពុជាដែរ។ យើងសង្ឃឹមថា ជម្លោះនេះអាចផ្ដល់មកនូវលទ្ធផលដ៏ល្អសម្រាប់ភាគីទាំងពីរ។ កែទាំ នៅតែរង់ចាំការចរចា និងស្វាគមន៍ការវិលត្រឡប់របស់ ស៊ូ លី មកចូលរួមប្រារព្ធពិធីម៉ាឡុត និងការវិលត្រឡប់របស់អ៊ីស្លាម។ សូមបញ្ជាក់ថា នៅក្នុងឋានានុក្រមគ្រប់គ្រងរបស់អ៊ីម៉ាំសាន់ ស៊ូ លី គឺជាភូឈួយទីបីរបស់ កែទាំ។ អ្នកទាំងពីរក៏ធ្លាប់ត្រូវបានអញ្ជើញដោយមជ្ឈមណ្ឌលឯកសារកម្ពុជាមកទស្សនាសាលាក្ដីខ្មែរក្រហមនិងចូលរួមក្នុងគម្រោងប្រវត្តិសាស្ត្រតាមការសួរនាំក្នុងសហគមន៍ចាមដែរ។

**អេង កុកថាយ**



ក្រុមអ៊ីម៉ាំសាន់ប្រារព្ធពិធីបុណ្យម៉ាឡុតនៅស្រុកកំពង់ត្រឡាច

# អាពាហ៍ពិពាហ៍ដោយបង្ខំជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

## ១) ប្រវត្តិ

នៅពេលមិនទាន់មានយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ខ្មែរក្រហមបានរៀបចំការរៀបការជាប្រព័ន្ធឲ្យបុរសនិងស្ត្រីនៅទូទាំងប្រទេស ។ ទោះបីជាមានបុរសខ្លះបានស្នើប្រធានភូមិឲ្យជ្រើសរើសនារីដែលខ្លួនចង់រៀបការក៏ដោយ ក៏មានបុរសនិងនារីភាគច្រើនផ្សេងទៀតមិនមានឱកាសជ្រើសរើសគូស្រករខ្លួនឯងឡើយ ។ ការបដិសេធមិនព្រមរៀបការ «អាចបណ្តាល ឲ្យមានការធ្វើ ទារុណកម្ម ការឃុំឃាំង និងការសម្លាប់» ។

ពិធីរៀបការទាំងនេះរួមមានគូស្រករមិនតិចជាងបីគូហើយ អាចមានដល់ទៅ១៦០គូ ។ ជាទូទៅ ប្រធានភូមិឬកម្មាភិបាលថ្នាក់ខ្ពស់នៅក្នុងសហករណ៍នឹងប្រកាសប្រាប់ភាគីទាំងពីរថាអ្នកទាំងនោះនឹងត្រូវរៀបការ បន្ទាប់មកពិធីរៀបការនឹងចាប់ផ្តើមនៅកន្លែងនោះ ។ ជារឿយៗ គូស្រករដែលរៀបការទើបតែបានជួបមុខគ្នានៅថ្ងៃរៀបការនោះទេ ។ ឪពុកម្តាយ និងសមាជិកគ្រួសារមិនត្រូវបានអនុញ្ញាតឲ្យជ្រើសរើសគូស្រករឲ្យកូនចៅរបស់ខ្លួន ឬចូលរួមក្នុងពិធីរៀបការទេ ។ ខ្មែរក្រហមបានអះអាងថា អំណាចរបស់ឪពុកម្តាយមិនមានសារសំខាន់អ្វីទេ ពីព្រោះអង្គការគឺជា «ឪពុកម្តាយរបស់អ្នកទាំងនោះ» ។

ប្រជាជនដែលរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានទទួលរងអំពើព្រៃផ្សៃជាច្រើន ប៉ុន្តែអំពើទាំងនោះមិនត្រូវបានយកទៅកាត់ទោសនៅក្រោមច្បាប់ព្រហ្មទណ្ឌអន្តរជាតិទាំងអស់នោះទេ ។ ច្បាប់អន្តរជាតិបានបង្កើនការទទួលស្គាល់ទៅលើឧក្រិដ្ឋកម្មដែលផ្អែកលើយេនឌ័រដូចជា ការរំលោភសេពសន្ថវៈនិងការធ្វើទាសកម្មផ្លូវភេទថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ទោះបីជាយ៉ាងណាក៏ដោយ វានៅតែមានចម្ងល់ថាតើឧក្រិដ្ឋកម្មដែលផ្អែកលើយេនឌ័រអាចគ្របដណ្តប់លើការខូចខាតដែលបណ្តាលមកពីអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬថាតើមានចន្លោះមួយនៅក្នុងច្បាប់អន្តរជាតិ «សម្រាប់កំណត់ឧក្រិដ្ឋកម្មនៃការបង្ខំឲ្យរៀបការដែលដាច់ដោយឡែកពីគ្នាថាជា «អំពើអមនុស្សធម៌ផ្សេងទៀត» ដែរឬទេ ។

## ២) ការខូចខាតបណ្តាលមកពីអាពាហ៍ពិពាហ៍ដោយបង្ខំ

មុនរបបខ្មែរក្រហម ការរៀបចំអាពាហ៍ពិពាហ៍គឺជាបន្ទុករបស់គ្រួសារ ។ ម្តាយនិងឪពុកត្រូវឆ្លងកាត់ការលំបាកជាច្រើនក្នុងការស្វែងរកគូស្រករឲ្យកូនប្រុសស្រីរបស់ខ្លួន ។ ម្តាយនិងឪពុកត្រូវស៊ើបសួរពីអាយុ ស្ថានភាពគ្រួសារ និងកត្តាផ្សេងទៀតរបស់ភាគីម្ខាងទៀតដើម្បីផ្គូផ្គងភាគីទាំងសងខាង ។ ពិធីរៀបការត្រូវចំណាយពេលបីថ្ងៃ ហើយវាគឺជាពិធីដ៏អឺកធឹកមួយដែលមានការចូលរួមពីសាច់ញាតិរបស់កូនក្រមុំ និងកូនកំលោះព្រមទាំងអ្នកភូមិផ្សេងទៀត ។ ការរៀបចំអាពាហ៍ពិពាហ៍នៅមុនពេលរបបខ្មែរក្រហមមានភាពខុសប្លែកគ្នាជាខ្លាំងពីអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងរបបខ្មែរក្រហម ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគូស្រករជាច្រើនត្រូវរៀបការដោយបន្ទាន់ មិនមានវត្តមានគ្រួសារនិងជាទូទៅមិនមានការរៀបចំត្រឹមត្រូវទេ ។ បុរសនិងនារីដែលត្រូវបង្ខំឲ្យរៀបការគឺមិនមានការចូលរួមរបស់គ្រួសារការយល់ព្រមនិងការប្រារព្ធពិធីត្រឹមត្រូវឡើយ ។

ទោះបីជាគូស្រករជាច្រើនដែលរៀបការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ «មានអារម្មណ៍ខឹងនិងមិនពេញចិត្តចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំ» គូស្រករជាច្រើនយល់ថាខ្លួនមានភារកិច្ចរស់នៅជាមួយប្តីប្រពន្ធរបស់ខ្លួនបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ។ បន្ទាប់ពីធ្វើការប្តេជ្ញាចិត្តរស់នៅជាមួយគូស្រកររបស់ខ្លួនអស់មួយជីវិត បុរសនិងនារីជាច្រើនត្រូវប្រឈមមុខនឹងអ្វីដែលអ្នកទាំងនោះគិតថាជាឧបសគ្គវប្បធម៌ដ៏ធំ ។ ទោះបីជាមានការទទួលស្គាល់ថាប្តីប្រពន្ធត្រូវបានបង្ខំឲ្យរៀបការជាសហករណ៍ ប៉ុន្តែការលែងលះក៏មិនត្រូវបានទទួលស្គាល់ដោយសង្គមដែរ ។ ប្តីប្រពន្ធផ្សេងទៀតបន្តនៅជាមួយគ្នាដោយសារតែអ្នកទាំងនោះជឿថាវាអាចផ្តល់ស្ថិរភាពដល់កូនរបស់ឪពុកម្តាយដែលត្រូវបានបង្ខំឲ្យរៀបការ ។ ប៉ុន្តែបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ គូផ្សេងដែលមិនមានធនធានគ្រប់គ្រាន់បានបែកគ្នាដោយសារខ្វះការការពារនិង

ធនធានហិរញ្ញវត្ថុ ។ សូម្បីតែបុរសនិងនារីដែលបានយកឈ្នះទៅលើបញ្ហាវប្បធម៌និងបែកគ្នា បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅតែមិនពេញចិត្តនឹងលទ្ធផលនៃអាពាហ៍ពិពាហ៍បង្ខំ ។ ឧទាហរណ៍ បុរសម្នាក់ដឹងព័ត៌មានពីមិត្តរបស់ខ្លួនថា ប្រពន្ធរបស់គាត់នៅក្នុងរបបខ្មែរក្រហមមានកូនស្រីម្នាក់ជាមួយគាត់ ។ ១៥ឆ្នាំបន្ទាប់ពីខ្មែរក្រហមបង្ខំឲ្យរៀបការ បុរសម្នាក់នោះបានធ្វើដំណើរទៅស្វែងរកអតីតប្រពន្ធនិងកូនស្រីរបស់គាត់ ។ បន្ទាប់ពីរកឃើញអ្នកទាំងពីរ បុរសម្នាក់នោះបានចាប់ផ្តើមផ្ញើប្រាក់ឲ្យអតីតប្រពន្ធសម្រាប់ចិញ្ចឹមកូនស្រី ។ ការធ្វើបែបនេះបានធ្វើឲ្យមានការមិនទុកចិត្តគ្នារវាងគាត់និងប្រពន្ធទីពីរ ។

បុរសនិងនារីដែលត្រូវបានបង្ខំឲ្យរៀបការទទួលរងការឈឺចាប់ទាំងផ្លូវកាយនិងផ្លូវចិត្ត ។ ជនរងគ្រោះត្រូវបាន ១) ដកហូតឱកាសមិនឲ្យជ្រើសរើសគូស្រករបស់ខ្លួនដែលជាសេចក្តីសម្រេចដ៏សំខាន់បំផុតក្នុងជីវិត ២) ប្រើប្រាស់វិធានការបង្ខំដោយគាបសង្កត់ឬហិង្សាមុននឹងរៀបការ ៣) ទទួលខុសត្រូវចិញ្ចឹមកូនដែលបានមកពីអាពាហ៍ពិពាហ៍ដោយបង្ខំ និង ៤) បង្ខំឲ្យមានទំនាក់ទំនងផ្លូវភេទដែលអាចប៉ះពាល់ដល់ជីវិតរបស់អ្នកទាំងពីរទោះបីជាអ្នកទាំងពីរលែងលះគ្នាបន្ទាប់ពីរបបខ្មែរក្រហមដួលរលំក៏ដោយ ។

## ៣) ធាតុផ្សំនៃអាពាហ៍ពិពាហ៍ដោយបង្ខំ

នៅកម្ពុជា អាពាហ៍ពិពាហ៍ដោយបង្ខំអាចនឹងកើតឡើងនៅពេលដែល «ជនដែលប្រើប្រាស់ពាក្យសម្តី ឬដឹកនាំជនណាម្នាក់ដោយការប្រើកម្លាំងបាយ ការគំរាមដោយបង្ខំ ឬការបង្ខំឲ្យរៀបការដែលបណ្តាលឲ្យមានការឈឺចាប់ដ៏ធ្ងន់ធ្ងរគឺបណ្តាលឲ្យជនរងគ្រោះមានរបួសទាំងផ្លូវកាយនិងផ្លូវចិត្ត ។ អាស្រ័យហេតុនេះ ដើម្បីបង្ហាញថាមានអាពាហ៍ពិពាហ៍ដោយបង្ខំ ព្រះរាជអាជ្ញាត្រូវតែបង្កើតធាតុផ្សំបី ១) ការប្រើកម្លាំងបាយ ការគំរាមដោយបង្ខំ ឬការបង្ខំ ២) ទំនាក់ទំនងអាពាហ៍ពិពាហ៍ ៣) ការឈឺចាប់ដ៏ធ្ងន់ធ្ងរ ឬរបួសផ្លូវកាយនិងផ្លូវចិត្តរបស់ជនរងគ្រោះ ។

### ក) ធាតុផ្សំទីមួយ ៖ ការប្រើកម្លាំងបាយ ការគំរាមដោយបង្ខំ ឬការបង្ខំ

ខ្មែរក្រហមគ្រប់គ្រងប្រទេសដោយប្រើប្រាស់ការដាក់ទណ្ឌកម្មជាទម្ងន់ដល់បុគ្គលសូម្បីតែវាជាកំហុសដ៏តូចតាចក៏ដោយ ។ នៅក្នុងស្ថានភាពបែបនេះ ប្រជាជនជាច្រើនមិនមានកម្លាំងប្រឆាំងនឹងបញ្ជារបស់ខ្មែរក្រហមទេ ។ ទោះបីជាមានប្រជាជនខ្លះបានបដិសេធនឹងការបញ្ជាឲ្យរៀបការជាច្រើនលើកក៏ដោយ ក៏នៅទីបញ្ចប់ប្រជាជនមួយចំនួននេះបានយល់ព្រមនឹងបញ្ជានេះដដែល ។ អ្នកដែលបដិសេធមិនព្រមរៀបការ ហើយត្រូវបានសម្លាប់គឺជាអ្នកដែលមានសំណាង ។ នៅក្នុងបរិយាកាសគាបសង្កត់បែបនេះ បុគ្គលជាច្រើនបានយល់ព្រមរៀបការដើម្បីចៀសផុតពីភាពភ័យខ្លាច ។ ដូច្នេះ យើងគួរតែពិចារណាទៅលើបរិស្ថានគាបសង្កត់ដែលបង្កើតឡើងដោយខ្មែរក្រហមនៅពេលបង្កើតធាតុផ្សំនៃការបង្ខំ ។ ស្ថានភាពបែបនោះគួរតែជាភស្តុតាងសច្ចធារណ៍ដែលជនរងគ្រោះនៃអាពាហ៍ពិពាហ៍ដោយបង្ខំនៅរបបកម្ពុជាប្រជាធិបតេយ្យមិនបានយល់ស្របដោយសុច្ចចិត្ត ។

នៅក្នុងករណី កូណារ៉ាក់ ព្រះរាជអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានសង្កេតឃើញថាកត្តាបរិស្ថានជុំវិញមួយចំនួនមានលក្ខណៈបង្ខំជាខ្លាំងដែលធ្វើឲ្យជនរងគ្រោះមិនមានលទ្ធភាពយល់ស្របដោយស្ម័គ្រចិត្ត ។ នៅក្នុងករណី កូណារ៉ាក់ ជនត្រូវចោទទទួលការចោទប្រកាន់ពីអំពើទាសភាពនិងការរំលោភឈ្លើយសឹកស្ត្រីមួយចំនួននៅពេលខុសៗគ្នា ។ អង្គជំនុំជម្រះបានបកស្រាយការបង្ខំថាគ្របដណ្តប់លើ «ការដឹកនាំភាគច្រើនដែលមិនមានឆន្ទៈកាត់ការយល់ស្របដែលធ្វើឲ្យមានការវាយតម្លៃទៅលើលទ្ធភាពរបស់ជនរងគ្រោះក្នុងការយល់ស្របនៅក្នុងបរិបទជុំវិញខ្លួន ។

នៅក្នុងករណី ក្រនដេឡាក់ ព្រះរាជអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីក៏ទទួលស្គាល់ថា បរិយាកាសបង្ខំបានបង្កឲ្យមានការសន្មតថាមិនមានការស្ម័គ្រចិត្ត ។ បន្ទាប់ពីវិភាគទៅលើស្ថានភាពឃុំខ្លួនអ្នកទោសដែលមិនមែនជាជនជាតិស៊ើប សាលាឧទ្ធរណ៍បានអះអាងថា «ការកាត់សេចក្តីដ៏ត្រឹមត្រូវគួរតែកើតឡើងនៅពេលធ្វើសេចក្តីសន្និដ្ឋានគឺថា ស្ថានភាពទូទៅរបស់អ្នកត្រូវបានឃុំឃាំងបានរារាំងមិនឲ្យមានការយល់ស្របដោយសេរី» ។

តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានសង្កត់ធ្ងន់ថា បរិយាកាសបង្ខំធ្វើឲ្យជនរងគ្រោះ

មិនអាចយល់ស្របដោយសេរីទេ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិបានប្រើប្រាស់ការបកស្រាយរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីស្តីពីការបង្ខំនៅក្នុងធាតុផ្សំនៃបទល្មើសដែលរួមមាន ការប្រើកម្លាំងបាយ ការគំរាមដោយបង្ខំ ឬការបង្ខំដែលជាធាតុផ្សំនៃការរំលោភថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងទទួលស្គាល់ថានៅក្នុងបរិយាកាសបង្ខំក៏អាចមានការរំលោភដែរ ។

មិនមែនគូស្រករទាំងអស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យសុទ្ធតែត្រូវបានបង្ខំឲ្យរៀបការទេ ។ ដោយសារតែមានអ្នកខ្លះអាចស្នើការរៀបការរបស់ខ្លួន ដូច្នេះមេធាវីការពារក្តីអាចដាក់ភស្តុតាងនេះទៅខាងអង្គភាពមេធាវីការពារក្តី ។ គូស្រករខ្លះអាចឆ្លៀតឱកាសរៀបចំអាពាហ៍ពិពាហ៍របស់ខ្លួនដែលធ្វើឲ្យភាគីទាំងពីរសុទ្ធតែពេញចិត្ត ។ «អ្នកខ្លះបានស្នើរៀបការដោយពេញចិត្តខ្លួនឯង ឬតាមការជ្រើសរើសរបស់សាច់ញាតិ ។ នៅដើមនិងចុងនៃរបបគ្រួសារជាច្រើនអាចស្នើរៀបការច្រើនជាងនៅពាក់កណ្តាលនៃរបប» ។

**ខ) ធាតុផ្សំទីពីរ ៖ ទំនាក់ទំនងអាពាហ៍ពិពាហ៍**

នៅក្នុងប្រទេសកម្ពុជា ទំនាក់ទំនងអាពាហ៍ពិពាហ៍គឺជាទំនាក់ទំនងខាងក្រៅរវាងមនុស្សពីរនាក់ដែលទទួលការអនុញ្ញាតតាមផ្លូវច្បាប់ពីរដ្ឋឲ្យរៀបការ ។ ភស្តុតាងនេះអាចបង្កើតធាតុផ្សំទំនាក់ទំនងអាពាហ៍ពិពាហ៍ ។ នៅក្នុងករណីខ្លះ ភស្តុតាងជាក់ស្តែងមួយចំនួនដូចជាលិខិតបញ្ជាក់អាចនឹងរកឃើញ ។ ប៉ុន្តែនៅពេលដែលមិនមានភស្តុតាងបែបនេះ តុលាការអាចពឹងផ្អែកទៅលើសក្ខីកម្មរបស់សាក្សីនិងភស្តុតាងផ្សេងទៀត ។ ដោយសារតែអាពាហ៍ពិពាហ៍តែងតែត្រូវបានធ្វើឡើងជាក្រុមនិងមានប្រារព្ធពិធីជាផ្លូវការវាគួរតែមានភស្តុតាងដែលមានជាប់ពាក់ព័ន្ធ ។

**គ) ធាតុផ្សំទីបី ៖ ការឈឺចាប់ដ៏ធ្ងន់ធ្ងរ ឬរបួសផ្លូវកាយ ឬផ្លូវចិត្តរបស់ជនរងគ្រោះ**

បុរសនិងនារីដែលទទួលការបង្ខំឲ្យរៀបការត្រូវទទួលអារម្មណ៍ខឹងសម្បានិងទុក្ខសោក ។ មានមនុស្សជាច្រើនបានបង្ហាញពីបទពិសោធន៍ «ដ៏ឈឺចាប់ដែលខ្លួនបានជួបប្រទះដូចអ្នកដទៃនៅក្នុងអំឡុងរបបដ៏ឃោរឃៅ» ។ អ្នកខ្លះមានការឈឺចាប់ចំពោះអាពាហ៍ពិពាហ៍បង្ខំពេកដែលបណ្តាលឲ្យមានការសម្លាប់ខ្លួនបន្ទាប់ពីប្រារព្ធពិធីរៀបការរួច ។

វិធានការប្រើកម្លាំងបាយនិងបង្ខំដែលមេដឹកនាំខ្មែរក្រហមប្រើប្រាស់ដើម្បីបង្ខំឲ្យបុរសនិងនារីរៀបការក៏អាចបង្កឲ្យមានការឈឺចាប់យ៉ាងធ្ងន់ធ្ងរដែរ ។ អ្នកដែលគិតថាមិនព្រមរៀបការក៏ត្រូវភ័យខ្លាចនឹងទារុណកម្មនិងការស្លាប់ ។ អ្នកខ្លះទៀតដែលមិនព្រមរៀបការក៏ត្រូវប្រឈមមុខនឹងការគំរាមកំហែងដែរ ។ ស្ត្រីម្នាក់បានប្រឆាំងនឹងបញ្ហានេះដោយមិនព្រមចាប់ដៃជាមួយអនាគតប្តីរបស់គាត់នៅពេលរៀបការរហូតដល់យោធាខ្មែរក្រហមយកកាំភ្លើងភ្ជង់គាត់ ។ ការគំរាមសម្លាប់ ការបង្ខំប្រជាជនប្រឈមមុខនឹងអំពើហិង្សានិងវិធានការបង្ខំផ្សេងទៀតដែលប្រើប្រាស់ដោយមេដឹកនាំខ្មែរក្រហមអាចធ្វើឲ្យជនរងគ្រោះទទួលការឈឺចាប់ធ្ងន់ធ្ងរនិងបញ្ហាផ្លូវចិត្ត ។

អាពាហ៍ពិពាហ៍ដោយបង្ខំបានរំលោភទៅលើសិទ្ធិសេរីភាពរបស់បុគ្គលនិងបំបិទសិទ្ធិជ្រើសរើសដែលអាចផ្លាស់ប្តូរជីវិតរបស់បុគ្គលនោះដែលបណ្តាលឲ្យមានរបួសផ្លូវចិត្ត ។ ដោយសារតែជនរងគ្រោះធ្លាប់ទទួលរងនូវស្ថានភាព និងការឈឺចាប់គ្រប់បែបយ៉ាងភស្តុតាងដែលបង្ហាញពីការឈឺចាប់យ៉ាងធ្ងន់ធ្ងរឬរបួសផ្លូវចិត្តនឹងមានលក្ខណៈខុសគ្នាទៅតាមសំណុំរឿងនីមួយៗ ។

**ឃ) សេចក្តីសន្និដ្ឋាន**

ការបំផ្លាញនិងធាតុផ្សំទាំងនេះបង្ហាញថាឧក្រិដ្ឋកម្មនៃអាពាហ៍ពិពាហ៍ដោយបង្ខំនៅកម្ពុជាគឺជាឧក្រិដ្ឋកម្មមិនមានជាប់ពាក់ព័ន្ធនឹងផ្លូវភេទ ។ វាមិនត្រូវបានគេរួមបញ្ចូលនៅក្នុងបទល្មើសដែលផ្អែកលើយេនឌ័រដែលត្រូវបានគេទទួលស្គាល់កាលពីមុនទេ ដូច្នេះវាគួរតែត្រូវបានគេទទួលស្គាល់ជាឧក្រិដ្ឋកម្មដាច់ដោយឡែក ។ ការពិនិត្យលើយុត្តិសាស្ត្រនិងប្រវត្តិនៃឧក្រិដ្ឋកម្មដែលផ្អែកលើយេនឌ័រដែលត្រូវបានទទួលស្គាល់កាលពីមុនបង្ហាញពីចន្លោះប្រហោងនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិរវាងឧក្រិដ្ឋកម្មទាំងនេះនិងអាពាហ៍ពិពាហ៍ដោយបង្ខំ ។

**៤) ឧក្រិដ្ឋកម្មដែលផ្អែកលើយេនឌ័រអាចទទួលការផ្តន្ទាទោសដោយតុលាការអន្តរជាតិ**

**ក) ការរំលោភសេពសន្ថវៈគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ**

ការរំលោភសេពសន្ថវៈគឺជាឧក្រិដ្ឋកម្មតែមួយដែលផ្អែកលើយេនឌ័រនិងជាបទល្មើសដាច់ដោយឡែកមួយដែលមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូននិងតុលាការព្រហ្មទណ្ឌអន្តរជាតិក៏បានទទួលស្គាល់ថាការរំលោភសេពសន្ថវៈគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយនៅក្នុងលក្ខន្តិករបស់ខ្លួនដែរ ។ និយមន័យរបស់តុលាការមានលក្ខណៈធំទូលាយល្មមសម្រាប់គ្របដណ្តប់លើរាល់ការរំលោភផ្លូវភេទទៅលើរាងកាយរបស់ជនរងគ្រោះដោយមិនមានការយល់ព្រម ។


ពិធីរៀបការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ


ពិធីរៀបការនេ

ការរំលោភសេពសន្ថវៈខុសប្លែកពីអាពាហ៍ពិពាហ៍បង្ខំដែលកើតមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងករណីសេសាយ តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនបានធ្វើកំណត់សម្គាល់ថាអាពាហ៍ពិពាហ៍បង្ខំមាន «ធាតុផ្សំខុសប្លែកពីបទល្មើសរំលោភសេពសន្ថវៈ ។ បទល្មើសរំលោភសេពសន្ថវៈតម្រូវឲ្យមានការរួមរ័ក» ។ ការរំលោភសេពសន្ថវៈតម្រូវឲ្យជនដៃដល់ប៉ះពាល់ទៅដល់រាងកាយរបស់ជនរងគ្រោះ ។

ទោះបីជាខ្មែរក្រហមរំពឹងឲ្យគូស្រករមានការរួមរ័កបន្ទាប់ពីរៀបការរួចក៏ដោយ ក៏ប៉ុន្តែមិនមែនគូស្រករទាំងអស់ទេដែលធ្វើតាមបញ្ជានេះ ។ បុរសម្នាក់ដែលយល់ថាខ្លួនមានសំណាងដោយសារតែប្រធានកងរបស់គាត់បានរៀបចំការឲ្យគាត់ជាមួយនារីដែលគាត់ស្រឡាញ់បានរៀបរាប់ពីការដែលគាត់យល់ព្រមមិនរួមរ័កជាមួយប្រពន្ធគាត់ដោយរបៀបណា ។ «ខ្ញុំស្រឡាញ់ស្ត្រីមេម៉ាយម្នាក់ដែលមានអាយុច្រើនជាងខ្ញុំ២ឬ៣ឆ្នាំ ។ ប៉ុន្តែបន្ទាប់ពីរៀបការរួច ខ្ញុំដឹងថានាងមិនស្រឡាញ់ខ្ញុំទេ ។» ប៉ុន្តែទោះបីជាមានការរួមរ័កបន្ទាប់ពីរៀបការហើយក៏ដោយ ក៏យើងមិនអាចភ្ជាប់ទំនាក់ទំនងរវាងជនដៃដល់និងជនរងគ្រោះនៃការរំលោភសេពសន្ថវៈដែរ ពីព្រោះខ្មែរក្រហមមិនមែនជាអ្នកដែលប៉ះពាល់ទៅលើរាងកាយរបស់ជនរងគ្រោះទេ វាគឺជាប្តីដែលត្រូវបានគេបង្ខំឲ្យរៀបការ ។

អាស្រ័យហេតុនេះ ធាតុផ្សំនៃការរំលោភមិនអាចគ្របដណ្តប់លើអាពាហ៍ពិពាហ៍បង្ខំដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ពីព្រោះការរួមរ័កមិនចាំបាច់ត្រូវតែកើតឡើងមិនមានការជាប់ពាក់ព័ន្ធរវាងជនដៃដល់ជនរងគ្រោះដោយមិនមានការរួមរ័កហើយការរំលោភសេពសន្ថវៈមិនបានដោះស្រាយពី «ធាតុផ្សំដែលមិនមានជាប់ពាក់ព័ន្ធនឹងផ្លូវភេទដែលអាចប្រៀបផ្ទឹមទៅនឹងការប្រឆាំងនឹងភាពថ្លៃថ្នូររបស់មនុស្ស» ។ ដោយសារតែ

ការរំលោភសេពសន្ថវៈមិនគ្រប់ដណ្តប់លើអាពាហ៍ពិពាហ៍បង្ខំ ហើយមិនមានបទល្មើសពាក់ព័ន្ធនឹងផ្លូវភេទផ្សេងទៀតស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូច្នេះអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវតែយកទៅចោទប្រកាន់ថាជាសកម្មភាពអមនុស្សធម៌ផ្សេងទៀត ។

### ១) សកម្មភាពអមនុស្សធម៌ផ្សេងទៀត

ច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនបានដាក់អាពាហ៍ពិពាហ៍ដោយបង្ខំថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ ប៉ុន្តែនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតក៏បានចោទប្រកាន់បទល្មើសនេះនៅក្នុងសំណុំរឿង



នាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

០០២នៅក្នុងដីកាបញ្ចប់ការស៊ើបសួរដោល ។ ធម្មនុញ្ញរបស់តុលាការនៅនូរ៉ែមប៊ឺគបានបង្កើតក្រុមនៃសកម្មភាពអមនុស្សធម៌ផ្សេងទៀត ។ ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ដែលត្រូវបានបង្កើតឡើងដើម្បីណែនាំពីការជំនុំជម្រះបទល្មើសក្រោយសង្គ្រាមនៅក្នុងភូមិភាគដែលត្រូវបានគ្រប់គ្រងនៅអាល្លឺម៉ង់និងធម្មនុញ្ញតូក្យូដែលត្រូវបានបង្កើតឡើងដើម្បីកាត់ទោសជប៉ុនពីឧក្រិដ្ឋកម្មនៅក្នុងសង្គ្រាមលោកលើកទីពីរបានទទួលស្គាល់ប្រភេទដែលនៅសេសសល់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត ។ ដោយសារតែ «មិនមាននរណាម្នាក់នឹងស្មានដឹងពីអ្នកធ្វើទារុណកម្មនៅពេលអនាគតដែលចង់បំពេញមហិច្ឆតាអាក្រក់របស់ខ្លួន» ប្រភេទដែលនៅសេសសល់ត្រូវតែកើតឡើងដើម្បីគ្របទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមិនទាន់បានរាប់បញ្ចូល ។ ដើម្បីបំពេញទៅលើធាតុផ្សំនៃសកម្មភាពអមនុស្សធម៌ផ្សេងទៀតដែលតម្រូវឲ្យមាន ជនដែលត្រូវតែ «បានប្រព្រឹត្តសកម្មភាពដែលអាក្រក់និងធ្ងន់ធ្ងរស្រដៀងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងដែលបានរៀបរាប់នៅក្នុងវិធីសាស្ត្រដែលជាប់ពាក់ព័ន្ធក្នុងគោលបំណងបង្កសកម្មភាពអមនុស្សធម៌ផ្សេងទៀត» ។ នៅពេលកំណត់សកម្មភាពអមនុស្សធម៌ អនុសញ្ញាក្រុងហ្សឺណែវនិងបញ្ញត្តិជាច្រើនបានលើកឡើងពីភាពបត់បែនបានដែលផ្ទុយពីបញ្ជីដែលមិនអាចកែប្រែបាន ប៉ុន្តែប្រភេទនៃសកម្មភាពអមនុស្សផ្សេងទៀតមានលក្ខណៈខុសពីគោលការណ៍នៃភាពដាក់លាក់ដោយសារតែភាពបត់បែនបានរបស់ខ្លួន ។ តុលាការអន្តរជាតិ «បានចាប់ផ្តើមយកចិត្តទុកដាក់ទៅលើភាពមិនច្បាស់លាស់និងភាពមិនមាននិយមន័យច្បាស់លាស់នៃលក្ខន្តិកៈនេះ» ។

នៅក្នុងករណីកាយីហ្សិម៉ា ព្រះរាជអាជ្ញាបានលើកឡើងពីបទដ្ឋានសម្រាប់កំណត់ថាសកម្មភាពមួយគឺជាសកម្មភាពអមនុស្សធម៌ផ្សេងទៀតដោយរបៀបណា ។ អង្គជំនុំជម្រះបានសង្កេតឃើញថា សកម្មភាពអមនុស្សធម៌ផ្សេងទៀត «មានភាពសាហាវនិងធ្ងន់ធ្ងរស្រដៀងនឹងសកម្មភាពដែលបានរៀបរាប់នៅក្នុងលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា» ហើយវាគឺជាសកម្មភាពអាចបង្កឲ្យមានរបួស ឬការឈឺចាប់យ៉ាងធ្ងន់ធ្ងរទៅលើផ្លូវកាយ និងផ្លូវចិត្តឬប៉ះពាល់ដល់ភាពថ្លៃថ្នូររបស់មនុស្ស» ។ ទោះបីជាអង្គជំនុំជម្រះបានលើកឡើងពីនិយមន័យមួយក៏ដោយ អង្គជំនុំជម្រះក៏រកឃើញថាចុងចោទមិនមានទោសប្រព្រឹត្តសកម្មភាពអមនុស្សធម៌ផ្សេងទៀតដោយសារតែព្រះរាជអាជ្ញាមិនបាន «ផ្តល់សេចក្តីសង្ខេបអំពីសកម្មភាព» ដែលផ្អែកទៅលើការចោទប្រកាន់នោះ ។

នៅក្នុងករណីអាកាយីស៊ុ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានរកឃើញជនត្រូវចោទមានទោសពីបទប្រព្រឹត្តសកម្មភាពអមនុស្សធម៌ផ្សេងទៀត ។ ព្រះរាជអាជ្ញាបានបញ្ជាក់ពីសកម្មភាពមួយចំនួនខាងក្រោមសម្រាប់ចោទប្រកាន់ថា ៖

១) តាមរយៈសាក្សី ១១ ម្នាក់បានឲ្យដឹងថាមានការបង្ខំឲ្យប្រពន្ធរបស់ ថាស៊ីស ដោះសម្លៀកបំពាក់នៅក្រៅការិយាល័យសហគមន៍បន្ទាប់ពីបញ្ជាឲ្យគាត់អង្គុយនៅក្នុងដីភក់ ។

២) បង្ខំឲ្យ ចាន់គាល ដោះសម្លៀកបំពាក់ និងដើរទាំងអាក្រាតនៅការិយាល័យសហគមន៍ ។

៣) បង្ខំឲ្យ អាឡិចស៊ា ប្រពន្ធរបស់ គីរីយី និងក្មួយស្រីពីរនាក់ លី និង នីស៊ីមវ៉េ ដោះសម្លៀកបំពាក់ និងបង្ខំឲ្យស្ត្រីទាំងនេះហាត់ប្រាណទាំងដោះសម្លៀកបំពាក់នៅការិយាល័យសហគមន៍ អង្គជំនុំជម្រះបានកំណត់សកម្មភាពទាំងអស់នេះថាជាហិង្សាផ្លូវភេទ ហើយធ្វើសេចក្តីសន្និដ្ឋានថាហិង្សាផ្លូវភេទនេះគឺ «ស្ថិតនៅក្នុងដែនកំណត់នៃសកម្មភាពអមនុស្សធម៌ផ្សេងទៀត» ។

តុលាការអន្តរជាតិបានទទួលស្គាល់ទាសកម្មផ្លូវភេទថាជាសកម្មភាពអមនុស្សធម៌ផ្សេងមួយទៀត ។ យើងអាចវិភាគថាតើអាពាហ៍ពិពាហ៍ដោយបង្ខំអាចជាសកម្មភាពអមនុស្សធម៌ផ្សេងទៀតឬទេដោយប្រើប្រាស់ធាតុផ្សំដែលមាននៅក្នុងករណីកាយីហ្សីម៉ា និងវិភាគទៅលើយុត្តិសាស្ត្រនៃទាសកម្មផ្លូវភេទ ។

### ក) ទាសកម្មផ្លូវភេទគឺឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាមិនបានកំណត់ទាសកម្មផ្លូវភេទនៅក្នុងលក្ខន្តិកៈរបស់ខ្លួនឡើយ ។ ប៉ុន្តែនៅក្នុងករណី គូណារ៉ាក់ ដែលជនត្រូវចោទបានឃុំខ្លួននារីមួយចំនួនដោយបង្ខំនៅក្នុងស្ថាប័នផ្សេងៗនិងរំលោភជាបន្តបន្ទាប់ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានចោទប្រកាន់ជនត្រូវចោទថាបានប្រព្រឹត្តអំពើទាសភាព និងរំលោភដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបង្កឲ្យមានបទល្មើសទាសកម្មផ្លូវភេទ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏បានចោទប្រកាន់ឧក្រិដ្ឋកម្មទាំងពីរនេះនៅក្នុងករណី០០២ដែរ ។

មាត្រា៧ (១) (ង)-២ នៃលក្ខន្តិកៈទីក្រុងរ៉ូមបានកំណត់ថាទាសកម្មផ្លូវភេទគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ធាតុផ្សំទាំងនោះរួមមានៈ

១) ជនដែលប្រើប្រាស់អំណាចណាមួយឬទាំងអស់ដែលភ្ជាប់ជាមួយនឹងសិទ្ធិកម្មសិទ្ធិទៅលើជនណាម្នាក់ឬច្រើន ដូចជាទិញ លក់ ឲ្យខ្ចី ឬវាយជននោះ ឬដកសិទ្ធិសេរីភាពស្រដៀងនោះ ។

២) ជនដែលបានបង្កឲ្យជននោះជាប់ពាក់ព័ន្ធនឹងសកម្មភាពផ្លូវភេទម្តង ឬច្រើនដង ។

លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនបានដាក់ទោសទាសកម្មផ្លូវភេទនៅក្រោមមាត្រា២ (ង) ។

នៅក្នុងករណីរូហ្វ អង្គជំនុំជម្រះរកឃើញថាជនត្រូវចោទសេសាយ, កាលន់ និង គ្បោ មានទោសពីបទទាសកម្មផ្លូវភេទដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបន្ទាប់ពីរកឃើញថាអ្នកទាំងនោះបានចាប់ស្ត្រីនិងបង្ខំឲ្យស្ត្រីនោះរួមភេទ ។ ដោយសម្អាងទៅលើសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនៅក្នុងករណី គូណារ៉ាក់ និងនិយមន័យនៃអំពើទាសភាព អង្គជំនុំជម្រះបានធ្វើសេចក្តីសន្និដ្ឋានថា «ទ្រនិចបង្អុលទិស» ខាងក្រោមអាចយកមកបង្ហាញបាននៅពេលមានការត្រួតពិនិត្យថាតើទាសកម្មផ្លូវភេទបានកើតឡើងឬអត់ ៖ «ការគ្រប់គ្រងទៅលើចលនារបស់មនុស្សម្នាក់ ការគ្រប់គ្រងទៅលើបរិយាកាសរូបវន្ត ការគ្រប់គ្រងលើផ្លូវចិត្ត ការប្រើប្រាស់វិធានការរារាំងឬផ្លាស់ប្តូរការរត់គេច ការប្រើកម្លាំងបាយ ការគំរាមកំហែងដោយកម្លាំងបាយ ឬការបង្ខំ រយៈពេលការអះអាងពីសិទ្ធិផ្តាច់មុខការគ្រប់គ្រងការធ្វើបាបដ៏ព្រៃផ្សៃនិងការរំលោភការគ្រប់គ្រងអារម្មណ៍ផ្លូវភេទនិងពលកម្មបង្ខំ» ។ អ្វីដែលគួរឲ្យកត់សម្គាល់គឺអង្គជំនុំជម្រះបដិសេធមិនទទួលស្គាល់អាពាហ៍ពិពាហ៍ដោយបង្ខំដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងទៀត ហើយបានអះអាងទាសកម្មផ្លូវភេទស្ថិតនៅក្នុងអាពាហ៍ពិពាហ៍បង្ខំ ។

នៅក្នុងករណី អេ អេហ្វ អ ស៊ី (AFRC) និងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ព្រះរាជអាជ្ញាបានអះអាងថាទោះបីជាអាពាហ៍ពិពាហ៍បង្ខំរួមមានធាតុផ្សំផ្លូវភេទក៏ដោយប៉ុន្តែវាមានលក្ខណៈខុសពីទាសកម្មផ្លូវភេទដោយសារតែជនដែលបានបង្ខំឲ្យស្ត្រីដើរតួនាទីប្រពន្ធដោយអនុវត្តនូវតួនាទីមិនជាប់ពាក់ព័ន្ធផ្លូវភេទដូចជា ចំអិនអាហារ បោសសម្អាត បោកគក់ និងមើលថែទាំកូន ។ អង្គជំនុំជម្រះមិនបានយល់ស្របនឹងការអះអាង

របស់ព្រះរាជអាជ្ញាទេ ហើយបានធ្វើសេចក្តីសន្និដ្ឋានថា «ព្រះរាជអាជ្ញាមិនបានផ្តល់ភ័ស្តុតាងថាអាពាហ៍ពិពាហ៍បង្ខំគឺជាឧក្រិដ្ឋកម្មមិនពាក់ព័ន្ធនឹងផ្លូវភេទទេ» ។

អង្គជំនុំជម្រះសាលាឧទ្ធរណ៍សម្រេចផ្ទុយពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ។ បន្ទាប់ពីស្តាប់សេចក្តីអះអាងរបស់ព្រះរាជអាជ្ញា អង្គជំនុំជម្រះសម្រេចថាអាពាហ៍ពិពាហ៍ដោយបង្ខំមិនមែនជាឧក្រិដ្ឋកម្មផ្លូវភេទ ដូច្នេះអង្គជំនុំជម្រះសម្រេចថាវាមិនស្ថិតនៅក្នុងទាសកម្មផ្លូវភេទទេ ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានបង្ហាញពីស្លាកស្នាមដែល «ប្រពន្ធរបស់ ប៊ូស» ជួបប្រទះនៅពេលដែលគាត់ព្យាយាមចូលរួមជាមួយសហគមន៍ម្តងទៀត ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក៏បានសង្កត់ធ្ងន់ទៅលើតួនាទីមិនមែនផ្លូវភេទដែលប្តីបានបង្ខំប្រពន្ធឲ្យធ្វើ ។ បន្ទាប់ពីរៀបរាប់ពីភាពខុសគ្នាទាំងនេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានបកស្រាយថាអាពាហ៍ពិពាហ៍ដោយបង្ខំកើតឡើងនៅក្នុង «ស្ថានភាពមួយដែលជនដៃដល់តាមរយៈពាក្យសម្តី ឬការអនុវត្ត ឬអ្នកដែលត្រូវទទួលខុសត្រូវបង្ខំដៃគូដោយប្រើកម្លាំងបាយ គំរាមកំហែងដោយបង្ខំ ឬបង្ខំ ឲ្យបម្រើផ្លូវភេទដែលបណ្តាលឲ្យមានការឈឺចាប់ធ្ងន់ធ្ងរ ឬរបួសផ្លូវកាយផ្លូវចិត្ត ។

សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ទទួលបានការរិះគន់ដោយសារតែបានលើកឡើងពីបទពិសោធន៍របស់ស្ត្រីម្នាក់នៅសេរ៉ាឡេអូនថាជាអាពាហ៍ពិពាហ៍បង្ខំ ។ បញ្ញវ័ន្តម្នាក់បានអះអាងថា អាពាហ៍ពិពាហ៍ដោយបង្ខំគឺជា «ពាក្យឧក្រិដ្ឋកម្មមិនត្រឹមត្រូវដែលបិទបាំងស្ថានភាពដែលគួរជាទាសកម្មផ្លូវភេទនៅក្រោមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ» ។ សេចក្តីសម្រេចក៏ទទួលបានការរិះគន់ចំពោះការបង្ហាញពីតួនាទីរបស់ស្ត្រីដោយកំណត់ថាជាការចម្អិនអាហារ ការបោសសម្អាត និងការងារផ្ទះថាជាតួនាទីផ្លូវភេទជាជាងពលកម្មដោយបង្ខំ ។

ទោះបីជាសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ក្នុងករណី អេ អេហ្វ អ ស៊ី (AFRC) អាចជួយដល់ធាតុផ្សំនៃអាពាហ៍ពិពាហ៍បង្ខំក៏ដោយ ក៏អាពាហ៍ពិពាហ៍បង្ខំដែលកើតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានលក្ខណៈខុសពីអាពាហ៍ពិពាហ៍ ដោយបង្ខំដែលកើតឡើងនៅសេរ៉ាឡេអូន ។ អាពាហ៍ពិពាហ៍ដោយបង្ខំនៅសេរ៉ាឡេអូន មានលក្ខណៈខុសពីកម្ពុជាប្រជាធិបតេយ្យដោយសារ ១) វាជាឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយស្វាមី ២) អំពើហិង្សាផ្លូវភេទឬការរំលោភសេពសន្ថវៈគឺជាធាតុផ្សំចម្បងនៃទំនាក់ទំនងអាពាហ៍ពិពាហ៍ ៣) អាពាហ៍ពិពាហ៍មិនត្រូវបានទទួលស្គាល់តាម-ផ្លូវច្បាប់និង ៤) ស្វាមីបង្ខំឲ្យប្រពន្ធធ្វើការ ។ ដោយសារតែភាពខុសគ្នាទាំងនេះធាតុផ្សំនៃទាសកម្មផ្លូវភេទអាចគ្របដណ្តប់លើឧក្រិដ្ឋកម្មដែលធ្វើទៅលើស្ត្រីនៅសេរ៉ាឡេអូន ហើយធាតុផ្សំនៃអាពាហ៍ពិពាហ៍បង្ខំអាចគ្របដណ្តប់លើឧក្រិដ្ឋកម្មដែលធ្វើទៅលើបុរសនិងនារីដែលត្រូវបានបង្ខំឲ្យរៀបការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

## ៥) គ្មានបទល្មើស គ្មានច្បាប់ចែង

### ក) និយមន័យ

គោលការណ៍គ្មានបទល្មើសគ្មានច្បាប់ចែងបង្ហាញថាដើម្បីធ្វើការចោទប្រកាន់សកម្មភាពមួយ សកម្មភាពនោះត្រូវតែ «ជាឧក្រិដ្ឋកម្មដែលមានការទទួលស្គាល់ថាជាប់ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់បុគ្គលនៅពេលដែលសកម្មភាពនោះកើតឡើង ។ ដើម្បីបញ្ជាក់ពីភាពគ្មានបទល្មើសគ្មានច្បាប់ចែង «អាពាហ៍ពិពាហ៍ដោយបង្ខំ» ត្រូវតែរួមមានធាតុផ្សំបី ១) សកម្មភាពកើតឡើងនៅពេលដែលពាក់ព័ន្ធគ្នា (១៩៧៥-១៩៧៩) ក្នុងឥរិយាបថដែលអាចដាក់ឲ្យជនដៃដល់ទទួលខុសត្រូវ ២) ក្នុងទម្រង់ដែលអាចដាក់ទណ្ឌកម្មលើសកម្មភាពរបស់ជនត្រូវចោទដែលអាចរំពឹងទុកបាននិង៣) ពាក់ព័ន្ធនឹងជនត្រូវចោទជាក់លាក់ ។

### ១) វត្តមាននៃច្បាប់នៅពេលដែលពាក់ព័ន្ធ

ព្រះរាជអាជ្ញាអាចបង្កើតថាមានវត្តមានល្មើសនៅក្នុងច្បាប់ទំនៀមទម្លាប់នៅអំឡុងពេលនៃយុត្តាធិការរបស់តុលាការដោយពិនិត្យទៅលើប្រភពដើមនៃច្បាប់ ។ ប្រភពទាំងនេះរួមមានអនុសញ្ញាអន្តរជាតិទំនៀមទម្លាប់ «គោលការណ៍ទូទៅនៃច្បាប់ដែលទទួលស្គាល់ដោយប្រជាជាតិស៊ីវិល» និងសេចក្តីសម្រេចរបស់តុលាការ ។ ដោយសារតែច្បាប់ទំនៀមទម្លាប់ «ត្រូវចំណាយពេលសម្រាប់កសាង» ដូច្នេះវាមានការលំបាកក្នុងការនិយាយឲ្យច្បាស់ថានៅពេលណាទើប «បទដ្ឋានមួយមានលក្ខណៈច្បាស់លាស់» ។

អាស្រ័យហេតុនេះ យុត្តិសាស្ត្រនិងលិខិតុបករណ៍អន្តរជាតិ

ដែលកើតឡើងបន្ទាប់ពីយុត្តាធិការបណ្តោះអាសន្នរបស់តុលាការ នៅតែមានភាពជាប់ពាក់ព័ន្ធនឹងគ្នាសម្រាប់យកមកការបង្កើត «រយៈពេលដែលច្បាប់ទំនៀមទម្លាប់ចាប់ផ្តើមវិវត្តន៍» ។

### ២) ភាពជាក់លាក់និងភាពដែលអាចរំពឹងទុកបាន

ភាពជាក់លាក់និងភាពដែលអាចរំពឹងទុកបានមានជាប់ពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធ ។ ច្បាប់ឬលក្ខន្តិកៈដែលបង្ហាញពីបទល្មើសត្រូវតែជាក់លាក់ដើម្បីធានាថាបុគ្គលអាចនឹងដឹងពីការទទួលខុសត្រូវលើបទល្មើសនៃសកម្មភាពរបស់ខ្លួន ។ ប៉ុន្តែ «ការសង្កត់ធ្ងន់ទៅលើការអនុវត្តជាជាងទៅលើការបកស្រាយជាក់លាក់នៃបទល្មើសនៅក្នុងច្បាប់មានជាប់ពាក់ព័ន្ធសំខាន់ជាងគេ» ។ ទោះបីជាយ៉ាងណាក៏ដោយ ភាពគ្មានបទល្មើសគ្មានច្បាប់ចែងមិនអាចត្រូវបានរំលោភបំពានទេ ពីព្រោះការប្រព្រឹត្តរបស់បុគ្គលអាចមានសីលធម៌ឬអាក្រក់ ។ ភាពអាក្រក់ឬភាពមានសីលធម៌គ្រាន់តែអាចរារាំងបញ្ហាដែលអាចរំពឹងឃើញទេពីព្រោះ «ប្រសិនបើបទល្មើសមានភាពធ្ងន់ធ្ងរ ជនដៃដល់ទំនងជាអាចដឹងថាអ្វីដែលខ្លួនបានធ្វើនឹងបង្កឲ្យមានការទទួលខុសត្រូវ» ។

ភាពជាក់លាក់ និងភាពដែលអាចរំពឹងទុកបានមិនអាចរាំងដល់ «ការកែលម្អនិងការសហការទៅលើវិធានដែលមានស្រាប់ទេ» ។ នៅក្នុងករណី ស៊ី.អ និងប្រទេសអង់គ្លេស *(C.R v. The United Kingdom)* តុលាការសិទ្ធិមនុស្សនៅអឺរ៉ុបបានរកឃើញថាបុរសម្នាក់មានទោសពីបទរំលោភផ្លូវភេទទោះបីជានៅពេលនោះមិនទាន់មានការដាក់ឲ្យទទួលខុសត្រូវលើបទល្មើសរំលោភផ្លូវភេទក៏ដោយ ។ តុលាការបានធ្វើសេចក្តីសន្និដ្ឋានថាទោះបីជាសេចក្តីសម្រេចនោះអាចផ្លាស់ប្តូរច្បាប់ដែលមានស្រាប់ក៏ដោយ ក៏ភាពគ្មានបទល្មើសគ្មានច្បាប់ចែងមិនបានហាមឃាត់ដល់ «ការអះអាងជាបន្ត បន្ទាប់នៃវិធានទទួលខុសត្រូវលើបទល្មើសតាមរយៈការបកស្រាយពីករណីមួយទៅករណីមួយដែលបញ្ជាក់ថា ការវិវឌ្ឍន៍ដែលបង្កឡើងមានលក្ខណៈស្របនឹងសារសំខាន់នៃបទល្មើសហើយអាចរំពឹងមើលឃើញបាន» ។ ស៊ី.អ បានបង្ហាញថា ការវិវឌ្ឍន៍នៃច្បាប់មិនគួរត្រូវបានរារាំងដោយភាពជាក់លាក់ក្នុងករណីដែល «ច្បាប់ទាក់ទងនឹងសំណុំរឿងត្រូវបានបង្កើតឡើងបន្ទាប់ពីបទល្មើសបានកើតឡើង ប៉ុន្តែនៅមុនពេលដែលបញ្ហានេះត្រូវបានដោះស្រាយនៅតុលាការ ឬនៅពេលដែលឥរិយាបថនេះត្រូវបានបញ្ជាក់ថាពាក់ព័ន្ធនឹងបទល្មើសនៅពេលនោះ» ។

### ៣) ភាពដែលអាចចោទប្រកាន់បាន

ដើម្បីដាក់ឲ្យបុគ្គលទទួលខុសត្រូវចំពោះបទល្មើសបានចាំបាច់ត្រូវតែមានកំណត់សម្គាល់ដ៏មានប្រសិទ្ធភាពដែលអាចបង្ហាញថាសកម្មភាពរបស់បុគ្គលនោះត្រូវបានគេហាមប្រាមមិនឲ្យប្រព្រឹត្ត ។ ព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់បែបនោះដោយធ្វើការពិនិត្យមើលទៅលើយុត្តិសាស្ត្រជាតិនិងអន្តរជាតិព្រមទាំងលិខិតុបករណ៍អន្តរជាតិដែលបានកើតឡើងនៅពេលដែលពាក់ព័ន្ធណាមួយ ។ ការដែលជនដៃដល់បានដឹងថាការប្រព្រឹត្តរបស់ខ្លួនមានលក្ខណៈខុសច្បាប់មិនមានសារសំខាន់ទេ ប៉ុន្តែអ្វីដែលសំខាន់គឺ ព័ត៌មានដែលអាចបង្ហាញពីភាពខុសច្បាប់របស់បុគ្គល ។

### ៤) អាពាហ៍ពិពាហ៍ដោយបង្ខំនិងភាពគ្មានបទល្មើសគ្មានច្បាប់ចែង

មានតែ «ធាតុផ្សំច្បាប់» នៃបទល្មើសគឺមិនមែនបទល្មើសដែលត្រូវបានគេឲ្យឈ្មោះច្បាស់ថាជា «អាពាហ៍ពិពាហ៍ដោយបង្ខំ» ត្រូវមានវត្តមាននៅពេលដែលសកម្មភាពត្រូវបានប្រព្រឹត្តឡើង ។

អាស្រ័យហេតុនេះព្រះរាជអាជ្ញាត្រូវតែបង្កើតយុត្តាធិការបណ្តោះអាសន្នរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានហាមប្រាមមិនឲ្យមានការបង្ខំដោយកម្លាំងបាយ គំរាមកំហែងដោយប្រើកម្លាំងបាយ ឬបង្ខំឲ្យរៀបការ ។

### ១) ការបង្ខំដោយកម្លាំងបាយ គំរាមកំហែងដោយកម្លាំងបាយ ឬបង្ខំ

គ្រប់បទល្មើសដែលផ្អែកលើយេនឌ័របង្ហាញពីភាពជាប់ពាក់ព័ន្ធស្របច្បាប់នៃការអនុញ្ញាតិនិងភាពខុសច្បាប់ក្នុងការប្រើប្រាស់ការបង្ខំ ការគំរាមកំហែងដោយប្រើកម្លាំងបាយ ឬបង្ខំដើម្បីគ្រប់គ្រងទៅលើឯករាជ្យភាពរបស់បុគ្គល ។ បញ្ញវន្តខ្លះបានអះអាងថាការវិវត្តនៃបទល្មើសដែលផ្អែកលើយេនឌ័របង្ហាញពីការផ្លាស់ប្តូរពីការការពារភាពថ្លៃថ្នូរនិងកិត្តិយសរបស់ស្ត្រីទៅជាគំរូ«ដែលផ្អែកលើគោលការណ៍ទូលាយជាងមុនទាក់ទងនឹងការផ្តល់ឯករាជ្យភាពនិងភាពថ្លៃថ្នូររបស់មនុស្ស» ។ ការប្រៀបធៀបពីអនុសញ្ញាក្រុងហ្សឺណែវនិងលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ

បង្ហាញពី «ការបញ្ជាក់ជាបន្តបន្ទាប់ទៅលើធាតុផ្សំនៃការទទួលខុសត្រូវលើបទល្មើស» រំលោភសេពសន្ថវៈ ។

មានការអះអាងថាសេរីភាពក្នុងការជ្រើសរើសនិងព្រមព្រៀងរបស់បុគ្គលត្រូវបានអំណាចរបស់រដ្ឋដាក់កំហិតទៅលើ ។ ប្រជាពលរដ្ឋមិនមានសេរីភាពក្នុងការធ្វើសេចក្ដីសម្រេច ។ ប៉ុន្តែដោយពិចារណាទៅលើទំនាក់ទំនងរវាងប្ដីប្រពន្ធសារសំខាន់នៃសង្គមដែលមាននៅក្នុងចំណងអាពាហ៍ពិពាហ៍និងសិទ្ធិក្នុងការជ្រើសរើសអាពាហ៍ពិពាហ៍ដែលមាននៅក្នុងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិជាច្រើនបង្ហាញឲ្យឃើញថា ការព្រមព្រៀងគ្នានិងភាពឯករាជ្យមានជាប់ពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំដូចនឹងបទល្មើសដែលផ្អែកលើយេនឌ័រដែលត្រូវបានពិភាក្សានៅពេលមុនដែរ ។ ដោយពិនិត្យទៅលើការវិវត្តនៃបទល្មើសដែលផ្អែកលើយេនឌ័របង្ហាញថាការដាក់កំហិតប្រឆាំងនឹង ការបង្ខំ ការគំរាមកំហែង ដោយកម្លាំងបាយប្កបង្ខំ ដើម្បីគ្រប់គ្រងទៅលើភាពឯករាជ្យរបស់បុគ្គលបានកើតមានមុនយុត្តាធិការបណ្ដោះអាសន្នរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ដូច្នេះវាស័ក្ដិសមនឹងគោលការណ៍គ្មានបទល្មើសគ្មានច្បាប់ចែង ។

ទោះបីជាការរំលោភសេពសន្ថវៈនិងហិង្សាផ្លូវភេទ «ត្រូវបានគេទទួលស្គាល់ថាជាឧក្រិដ្ឋកម្មអន្តរជាតិជាយូរណាស់មកហើយ» ក៏ដោយ ក៏ធម្មនុញ្ញរបស់តុលាការនៅនូរ៉េមប៊ឺគខ្វះខាតនូវការហាមប្រាមប្រឆាំងនឹងរាល់ទម្រង់ហិង្សាផ្លូវភេទ ។ រហូតដល់អំណាចប្រទេសទាំងបួនបានបង្កើតច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ ដើម្បីណែនាំពីការកាត់សេចក្ដីបទល្មើសនៅក្រោយសង្គ្រាមនៅក្នុងតំបន់ដែលត្រូវបានគេកាន់កាប់នៅអាល្លឺម៉ង់ទើបការរំលោភសេពសន្ថវៈត្រូវបានគេដាក់បញ្ចូលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

តុលាការនៅតូក្យូដែលកាត់ទោសជនជាតិជប៉ុនពីសង្គ្រាមលោកលើកទីពីរមិនបានរួមបញ្ចូលការរំលោភសេពសន្ថវៈជាបទល្មើសមួយនៅក្នុងធម្មនុញ្ញរបស់ខ្លួនទេ ។ ប៉ុន្តែតុលាការនោះបានកាត់ទោសការរំលោភស្ត្រីម្នាក់និងជនស៊ីវិលផ្សេងទៀតដែលប្រមាថមើលងាយកិត្តិយសគ្រួសារនិងការប្រព្រឹត្តអំពើអមនុស្សធម៌ ហើយកាត់ទោសបទល្មើសដែលផ្អែកលើយេនឌ័រនៅក្រោមបទបញ្ញត្តិនៃធម្មនុញ្ញទាក់ទងនឹងឧក្រិដ្ឋកម្មសង្គ្រាម ។

បន្ទាប់ពីសង្គ្រាមលោកលើកទីពីរអនុសញ្ញាក្រុងហ្សឺណែវត្រូវបានគេធ្វើវិសោធនកម្មដើម្បីផ្ដល់ការការពារដល់ប្រជាជនស៊ីវិលច្រើនជាងមុន ។ ដូច្នេះអនុសញ្ញាក្រុងហ្សឺណែវនៅឆ្នាំ១៩៤៩បានគ្របដណ្ដប់ទៅលើទំនៀមទម្លាប់អន្តរជាតិដែលត្រូវបានបង្កើតឡើងដោយសារអំពើហិង្សាដែលបានប្រព្រឹត្តទៅលើប្រជាជនស៊ីវិលនៅក្នុងសង្គ្រាមលោកលើកទីពីរ ។ មាត្រា២៧នៃអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ដែលបានរួមបញ្ចូលគ្រប់ប្រទេសទាំងអស់និងត្រូវបានចាត់ទុកថាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិបានហាមប្រាមមិនឲ្យមានការរំលោភសេពសន្ថវៈ ។

នៅឆ្នាំ១៩៧៧ វិធានបន្ថែមត្រូវបានបញ្ចូលទៅក្នុងអនុសញ្ញាក្រុងហ្សឺណែវ ។ វិធានទាំងនោះសុទ្ធតែហាមប្រាមមិនឲ្យមានការរំលោភសេពសន្ថវៈ ។

អនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ យុត្តិសាស្ត្រដែលកើតក្រោយសង្គ្រាមលោកលើកទីពីរនិងយុត្តិសាស្ត្រដែលកើតចេញពីតុលាការអន្តរជាតិបង្ហាញថា ការទទួលខុសត្រូវលើបទល្មើសដែលផ្អែកលើយេនឌ័របានកើតមានមុនពេលយុត្តាធិការបណ្ដោះអាសន្នរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ការរំលោភសេពសន្ថវៈដែលជាបទល្មើសផ្អែកលើយេនឌ័រដែលរួមមានការការពារ ភាពឯករាជ្យ និងការព្រមព្រៀងគ្នាគឺស្របទៅនឹងអ្វីដែលតម្រូវឲ្យមានភាពគ្មានបទល្មើសគ្មានច្បាប់ចែងគឺធាតុផ្សំនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ។

ទោះបីជានិយមន័យច្បាប់ស្ដីពីការរំលោភសេពសន្ថវៈដែលដោះស្រាយពីបញ្ហានៃការព្រមព្រៀងគ្នាមិនមានវត្តមាននៅក្នុងសេចក្ដីសម្រេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាក្នុងករណីអាកាយេសូ ក៏មាន «ការកែលម្អនិងការសហការទៅលើវិធានដែលមានស្រាប់» ដែលធ្វើឲ្យការរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនមែនជាការរំលោភបំពានលើសេចក្ដីថ្លៃថ្នូររបស់ស្ត្រីតែជាសកម្មភាពដែលប្រព្រឹត្តឡើងប្រឆាំងនឹងស្ត្រីនោះក្នុងស្ថានភាពដែលមិនឲ្យស្ត្រីនោះអាចផ្ដល់ការយល់ស្របបាន ។

### ២) ទំនាក់ទំនងអាពាហ៍ពិពាហ៍ និងភាពគ្មានបទល្មើស គ្មានច្បាប់ចែង

សិទ្ធិក្នុងការជ្រើសរើសគូស្រករត្រូវបានរួមបញ្ចូលនៅក្នុងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិជាច្រើនមុនពេលយុត្តាធិការបណ្តោះអាសន្នរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ បញ្ញវន្តខ្លះបានអះអាងថា ការចោទប្រកាន់អាពាហ៍ពិពាហ៍ដោយបង្ខំបានធ្វើឲ្យភាពខុសគ្នាដ៏សំខាន់រវាងអាពាហ៍ពិពាហ៍ដោយបង្ខំដែលត្រូវបានចាត់ទុកថាជាការរំលោភលើសិទ្ធិមនុស្សអន្តរជាតិដែលខុសពីអ្វីដែលអាចបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្លាយជាមិនច្បាស់លាស់» ។ ទោះបីជាយ៉ាងណាក៏ដោយ ករណី អេនថូនីអូខេស៊ីស បានអះអាងថា «ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពឹងផ្អែកទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ» ។ ដោយសារតែច្បាប់សិទ្ធិមនុស្សអន្តរជាតិបានផ្តល់គន្លឹះដល់ការបង្កើតឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការធ្វើការស្ទាបស្ទង់លិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិដែលរួមបញ្ចូលសិទ្ធិក្នុងការជ្រើសរើសគូស្រករបានជួយកំណត់ថាតើភាពគ្មានបទល្មើសគ្មានច្បាប់ចែងស័ក្តិសមនៅក្នុងករណីនោះឬអត់ ។

«អាពាហ៍ពិពាហ៍ដែលមានការព្រមព្រៀងគ្នារវាងភាគីទាំងពីរត្រូវបានគេទទួលស្គាល់ថា ជាការរំលោភលើច្បាប់សិទ្ធិមនុស្សអន្តរជាតិចាប់តាំងពីមានការប្រកាសជាសាកលស្តីអំពីសិទ្ធិមនុស្សឆ្នាំ១៩៤៨» ។ ការប្រកាសជាសាកលស្តីអំពីសិទ្ធិមនុស្សដែលជាយូរណាស់មកហើយត្រូវបានគេចាត់ទុកថាជា «បទដ្ឋាននៃសេចក្តីសម្រេចទូទៅសម្រាប់ប្រជាជាតិនិងប្រជាជនទាំងអស់បានកំណត់នូវព្រំដែននៃសិទ្ធិសេរីភាពក្នុងការជ្រើសរើសគូស្រករនៅក្រោមមាត្រា១៦ ។ ការប្រកាសជាសាកលស្តីអំពីសិទ្ធិមនុស្សបានបង្ហាញពីចំណុចសំខាន់នៃសិទ្ធិមូលដ្ឋាននិងជំរុញឲ្យមានការបង្កើត «លិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិចំនួន៦០ដែលអាចបង្កើតប្រព័ន្ធនៃការរួមបញ្ចូលសន្ធិសញ្ញាសម្រាប់ការជំរុញនិងការការពារសិទ្ធិមនុស្ស» ។ មុនឆ្នាំ១៩៧៥ សន្ធិសញ្ញាមួយក្នុងចំណោមសន្ធិសញ្ញាដែលរួមបញ្ចូលគ្នានោះគឺកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយក៏បានទទួលស្គាល់សិទ្ធិក្នុងការជ្រើសរើសគូស្រករដែរ ។ មាត្រា២៣(៣) ក៏បានចែងថា «មិនមានការរៀបការណាដែលមិនមានការយល់ព្រមពីភាគីទាំងសងខាងដោយសេរីនិងពេញលេញទេ» ។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយត្រូវបានគាំទ្រដោយប្រទេសជាច្រើន ហើយបច្ចុប្បន្នបញ្ញត្តិជាច្រើនរបស់កតិកានេះត្រូវចាត់ទុកថាមានឋានៈច្បាប់ប្រពៃណីអន្តរជាតិ ។ ប៉ុន្តែ ប្រទេសខ្លះបានចាត់ទុកបញ្ញត្តិជាក់លាក់នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយថា បង្កឲ្យមានការមិនយល់ស្របគ្នា ។ បញ្ញត្តិមួយក្នុងចំណោមបញ្ញត្តិនោះគឺមាត្រា២៣ ។ ប្រទេសមួយចំនួនបានបង្ហាញពីការមិនយល់ស្របនឹងមាត្រា២៣ ប៉ុន្តែភាគីសមាជិកបានបដិសេធនឹងការមិនយល់ស្របនោះ ។ នៅក្នុងអនុសញ្ញាស្តីពីការព្រមព្រៀងរៀបអាពាហ៍ពិពាហ៍មាត្រា១(១) ដែលបង្ហាញពីអាយុតិចបំផុតដែលអាចរៀបការបាននិងការចុះលិខិតអាពាហ៍ពិពាហ៍បានចែងថា «មិនមានអាពាហ៍ពិពាហ៍ណាត្រូវបានទទួលស្គាល់ដោយច្បាប់ប្រសិនបើភាគីទាំងពីរមិនបានយល់ព្រមដោយសេរីនិងពេញលេញទេ ។ ការយល់ព្រមបែបនេះគឺត្រូវធ្វើឡើងដោយបុគ្គលបន្ទាប់ពីមានការប្រកាសជាសាធារណៈនិងវត្តមានរបស់អាជ្ញាធរអនុញ្ញាតដើម្បីប្រារព្ធពិធីរៀបការនិងធ្វើជាសាក្សីដូចដែលបានរៀបរាប់នៅក្នុងច្បាប់ទេ» ។

ប្រទេសកម្ពុជាមិនទាន់បានចុះហត្ថលេខាលើអនុសញ្ញាអាពាហ៍ពិពាហ៍នេះទេ ។ ប៉ុន្តែអនុសញ្ញានេះបានចូលជាធរមាននៅក្នុងឆ្នាំ១៩៨៦ ។ បច្ចុប្បន្នមានតែប្រទេសបង់ក្លាដេសមួយគត់ដែលមិនយល់ស្របនឹងឃ្លាដែលថា «ភាគីទាំងពីរត្រូវមានការយល់ស្របដោយសេរីនិងពេញលេញ» ។

អនុសញ្ញាស្តីពីការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីមាត្រា១៦(១)(ខ) ក៏បានធានាពីសិទ្ធិក្នុងការជ្រើសរើស «គូស្រករហើយអាចរៀបអាពាហ៍ពិពាហ៍បាននៅពេលដែលមានការយល់ស្របដោយសេរីនិងពេញលេញ» ។ ទោះបីជាអនុសញ្ញាស្តីពីការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីត្រូវបានបង្កើតឡើងជាពិសេសសម្រាប់ការពារសិទ្ធិស្ត្រីក៏ដោយ ក៏វាបានឆ្លុះបញ្ចាំងពីសិទ្ធិយល់ព្រមរៀបអាពាហ៍ពិពាហ៍ទូទៅ ។ ប្រទេសជាច្រើនជាពិសេសប្រទេសដែលអនុវត្តនូវការជ្រើសរើសអាពាហ៍ពិពាហ៍ឲ្យគូស្រករបានប្រឆាំងនឹងមាត្រា១៦ ។ ទោះបីជាយ៉ាងណាក៏ដោយ ភាគច្រើននៃការមិនយល់ស្របរបស់ប្រទេសមិនបានប្រឆាំងនឹងសិទ្ធិស្តីពីអាពាហ៍ពិពាហ៍ស្ម័គ្រចិត្តគឺ

ប្រឆាំងនឹងសិទ្ធិដែលរៀបរាប់នៅក្នុងមាត្រា១៦ប៉ុណ្ណោះ ។

ការវិភាគលើលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិដែលភាគច្រើននៃលិខិតុបករណ៍នោះបានចូលជាធរមានមុនពេលយុត្តាធិការបណ្តោះអាសន្នរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបង្ហាញថា មានការអះអាងថា ខ្មែរក្រហមដឹងនិងអាចរំពឹងដឹងថាការប្រព្រឹត្តរបស់ខ្លួនគឺត្រូវបានហាមប្រាមណដោយសហគមន៍អន្តរជាតិ ។ ទោះបីជាមិនមានលិខិតុបករណ៍ដែលត្រូវបានពិនិត្យដោយហ្មត់ចត់ណានិយាយពីការទទួលខុសត្រូវលើបទល្មើសក៏ដោយ ក៏ «ការទទួលខុសត្រូវលើបទល្មើសជាបុគ្គលរបស់ជនត្រូវចោទមិនចាំបាច់ត្រូវតែមាននៅក្នុងបទបញ្ញត្តិនៃអនុសញ្ញានៅក្រោមច្បាប់ប្រពៃណីអន្តរជាតិទេ ។ ជាងនេះទៅទៀត ភាពអាក្រក់នៃបទល្មើសបង្ខំឲ្យមនុស្សពីរនាក់ ហើយពេលខ្លះការគំរាមកំហែងដើម្បីមនុស្សពីរនាក់នៅជាមួយគ្នាអស់មួយជីវិតអាចគាំទ្រនូវធាតុផ្សំដែលអាចមើលឃើញ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏នៅតែមានសំណួរថាតើការទទួលខុសត្រូវលើបទល្មើសដែលរំលោភលើសិទ្ធិរបស់បុគ្គលក្នុងការជ្រើសរើសគូស្រករបានកើតមាននៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេ ។

### ក) សេចក្តីសន្និដ្ឋាន

ឧបសគ្គនៃភាពគ្មានបទល្មើសគ្មានច្បាប់ចែងគឺជាបញ្ហាដែលត្រូវដោះស្រាយ ។ ព្រះរាជអាជ្ញាប្រហែលជាមានការលំបាកក្នុងការបង្កើតថាការទទួលខុសត្រូវលើបទល្មើសចំពោះអាពាហ៍ពិពាហ៍បង្ខំបានកើតមាននៅក្នុងនៅអំឡុងយុត្តាធិការបណ្តោះអាសន្នរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ទោះបីជាធាតុផ្សំនៃការប្រើកម្លាំងបាយ ការគំរាមកំហែងដោយប្រើកម្លាំងបាយ និងបង្ខំឲ្យរៀបការអាចឆ្លងកាត់ភាពគ្មានបទល្មើសគ្មានច្បាប់ចែងដោយងាយក៏ដោយ ប៉ុន្តែវាប្រហែលជាមានការលំបាកក្នុងការបង្កើតថាការទទួលខុសត្រូវលើបទល្មើសជាបុគ្គលចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំបានកើតឡើងនៅពេលជាប់ពាក់ព័ន្ធគ្នា ។ ប្រសិនបើព្រះរាជអាជ្ញាអាចបង្កើតថាការទទួលខុសត្រូវលើបទល្មើសបានកើតមាន ការហាមប្រាមប្រឆាំងនឹងអាពាហ៍ពិពាហ៍ដែលមិនមានការយល់ព្រមគួរតែឆ្លងកាត់ធាតុផ្សំនៃភាពគ្មានបទល្មើសគ្មានច្បាប់ចែងដែលជាក់លាក់អាចរំពឹងទុកបាន និងអាចប្រើប្រាស់បាន ។

### ៦) ការចោទប្រកាន់អាពាហ៍ពិពាហ៍បង្ខំថាជាសកម្មភាពអមនុស្សធម៌ផ្សេងទៀត

ទោះបីជាឧបសគ្គនៃភាពគ្មានបទល្មើសគ្មានច្បាប់ចែងអាចត្រូវបានដោះស្រាយក៏ដោយ ក៏ព្រះរាជអាជ្ញាត្រូវអះអាងថាអាពាហ៍ពិពាហ៍បង្ខំនិងទាសកម្មផ្លូវភេទគឺមិនអាចបំបែកបាន ។ នៅឆ្នាំ២០០៨ សវនាការអង្គបុរេនៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានធ្វើសេចក្តីសន្និដ្ឋានថា «ទាសកម្មផ្លូវភេទក៏រួមបញ្ចូលស្ថានភាពដែលស្ត្រីនិងក្មេងស្រីត្រូវបានបង្ខំឲ្យ «រៀបការ ធ្វើការ ឬធ្វើការធ្ងន់ដែលជាប់ពាក់ព័ន្ធនឹងសកម្មភាពផ្លូវភេទដែលរួមមានការរំលោភសេពសន្ថវៈដែលធ្វើឡើងដោយមេបញ្ជាការរបស់ខ្លួន» ។ ប៉ុន្តែព្រះរាជអាជ្ញាអាចដោះស្រាយដោយស្របច្បាប់នូវបញ្ហាទាំងនេះនិងយុត្តិសាស្ត្រផ្សេងគ្នាដែលអាចកើតមានដោយបំបែកចេញនូវភាពផ្សេងគ្នារវាងអាពាហ៍ពិពាហ៍បង្ខំដូចដែលបានកើតឡើងនៅសេរ៉ាឡេអូន រ៉្វាន់ដា និង យូហ្គាន់ដា និងអាពាហ៍ពិពាហ៍បង្ខំដែលកើតមាននៅកម្ពុជា ។

### ៧) សេចក្តីសន្និដ្ឋាន

អ្នកនៅរស់ពីអាពាហ៍ពិពាហ៍បង្ខំដែលត្រូវបានសម្ភាសន៍ដោយអ្នកនិពន្ធបានបង្ហាញថា អ្នកទាំងនោះជឿថាអាពាហ៍ពិពាហ៍បង្ខំអាចជាឧក្រិដ្ឋកម្មមួយ ពីព្រោះការរៀបការមុនរបបខ្មែរក្រហមមានភាពខុសប្លែកគ្នាពីការរៀបការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ អ្នកនៅរស់បានផ្តល់ហេតុផលមួយចំនួនថា ១) នៅក្នុងរបបខ្មែរក្រហមអ្នកមិនអាចប្រឆាំងនឹងបញ្ជាឲ្យរៀបការពីព្រោះវាអាចបណ្តាលឲ្យមានការស្លាប់ ២) ជាទូទៅអ្នកត្រូវបានបង្ខំឲ្យរៀបការជាមួយមនុស្សដែលអ្នកមិនដែលជួប ៣) បន្ទាប់ពីត្រូវបានបង្ខំឲ្យរៀបការ អ្នកត្រូវធ្វើការធ្ងន់ ហើយត្រូវរស់នៅបែកគ្នាដែលធ្វើឲ្យអ្នកកម្របានជួបប្តីឬប្រពន្ធរបស់អ្នក ។ អ្នកនៅរស់ទាំងនេះមិនដឹងពីច្បាប់ព្រហ្មទណ្ឌអន្តរជាតិនិងការពិភាក្សាដែលកំពុងដំណើរការនៅជុំវិញបញ្ហាទាសកម្មផ្លូវភេទនិងអាពាហ៍ពិពាហ៍បង្ខំ ។ អ្នកទាំងនោះបានបង្ហាញបីបទពិសោធន៍ដ៏ឈឺចាប់នៅពេលដែលខ្លួនបានជួបប្រទះ ។ **ណាតាលី អេនជីសុន**

# ការស្វែងរកការពិតតាមរយៈដំណើរការនីតិវិធីមិនលម្អៀង ៖ កាតព្វកិច្ចដែលមានដែនកំណត់របស់សហចៅក្រមស៊ើបអង្កេតក្នុងការស្វែងរកភ័ស្តុតាងដោះបន្ទុក

## ប្រវត្តិ

វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានផ្តល់កាតព្វកិច្ចដល់សហចៅក្រមស៊ើបអង្កេតធ្វើការស៊ើបអង្កេតដោយមិនលម្អៀងនិងស្វែងរកភ័ស្តុតាងដាក់បន្ទុកនិងដោះបន្ទុកនានា ដើម្បីស្វែងរកការពិត ។ ប៉ុន្តែចំពោះតួនាទីរបស់សហចៅក្រមស៊ើបអង្កេតក្នុងការឆ្លើយតបជាពិសេសគឺឆ្លើយតបនឹងការស្នើសុំឲ្យមានការស៊ើបអង្កេតរបស់មេធាវីការពារក្តីគឺសហចៅក្រមស៊ើបអង្កេតត្រូវតែបង្ហាញពីទម្រង់នៃការទទួលខុសត្រូវដែលមានសក្តានុពល ។ យុត្តិសាស្ត្រស៊ើបអង្កេត និងមាគ៌ាទូទៅនៃការស៊ើបអង្កេតគឺមិនមានភាពច្បាស់លាស់នៅឡើយទេ ។

### ១) តួនាទីរបស់សហចៅក្រមស៊ើបអង្កេតក្នុងការស្វែងរកការពិត

ដោយអនុលោមទៅតាមវិធានផ្ទៃក្នុងរបស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញាត្រូវធ្វើការស៊ើបអង្កេតបឋមដើម្បីកំណត់ថាតើភ័ស្តុតាងអាចបង្ហាញថាឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកើតមានដែរឬទេ និងដើម្បីកំណត់ពីជនសង្ស័យ និងសាក្សីដែលមានសក្តានុពល ។ ការងារដំបូងរបស់សហព្រះរាជអាជ្ញាគឺកំណត់នូវចំណុចស៊ើបអង្កេត ។ សហព្រះរាជអាជ្ញាត្រូវតែបញ្ជូនដីកាបញ្ជូនរឿងស៊ើបសួរទៅសហចៅក្រមស៊ើបអង្កេតដែលជាអ្នកចាត់វិធានការស៊ើបអង្កេតដើម្បីស្វែងរកការពិត ។ អំណាចរបស់សហចៅក្រមស៊ើបអង្កេតគឺស្របទៅតាមមាត្រា១២៧នៃក្រមនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ ។

គោលបំណងសំខាន់របស់ការស៊ើបអង្កេតតាមច្បាប់ស៊ីវិលគឺដើម្បីស្វែងរកការពិត ។ បញ្ញវន្ត ហ្វ្រើហ្គរី ហ្គដរី បានពន្យល់ថា «គោលដៅនេះមានលក្ខណៈខុសពីប្រព័ន្ធច្បាប់ខមិនឡដែលចែងថា «ការពិត» គឺត្រូវបានគេចាត់ទុកថាជាលទ្ធផលនៃដំណើរការដែលត្រូវបានគេកំណត់រួចទៅហើយ» ។ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាមប្រព័ន្ធច្បាប់ស៊ីវិលក្នុងស្រុក ច្បាប់បានផ្តល់អំណាចសំខាន់ទាំងអស់ទៅឲ្យចៅក្រមស៊ើបអង្កេតដើម្បីផ្តល់សេរីភាពដល់សហចៅក្រមស៊ើបអង្កេតក្នុងការធ្វើការនិងជួយជំរុញការងាររបស់អ្នកទាំងនោះ ។ ការធ្វើបែបនេះបានផ្តល់ឆន្ទានុសិទ្ធិដ៏ទូលាយដល់សហចៅក្រមស៊ើបអង្កេតក្នុងការសម្រេចថាតើត្រូវប្រមូលភ័ស្តុតាងដាក់បន្ទុកនិងដោះបន្ទុកដើម្បីស្វែងរកការពិតដោយរបៀបណា ។ វាក៏ជាហេតុផលដែលបញ្ជាក់ថាហេតុអ្វីបានជាប្រព័ន្ធដែលដាក់ឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេតដំណើរការប្រតិភាក្សាផ្ទៃក្នុងនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេតមិនមែនជាផ្នែកមួយនៃសំណុំរឿងឬអាចផ្តល់ព័ត៌មានដល់ភាគីណាមួយឡើយ ។ សិទ្ធិរបស់ភាគីក្នុងការទទួលបាន «លទ្ធផល» នៃការស៊ើបអង្កេតគឺសំដៅទៅលើការទទួលបានលទ្ធផលនៃការស៊ើបអង្កេតដូចជា ឯកសារ និងកំណត់ត្រានៅក្នុងសំណុំរឿងគឺមិនមែនព័ត៌មានអំពីនីតិវិធីដែលអាជ្ញាធរស៊ើបអង្កេតប្រើប្រាស់ដើម្បីវិភាគទៅលើភ័ស្តុតាងដែលខ្លួនបានប្រមូលនោះទេ ។

វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានដាក់កំហិតទៅលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតដោយតម្រូវថានៅក្នុងសំណុំរឿងទាំងអស់ សហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបអង្កេតដោយមិនលម្អៀងគឺស្វែងរកទាំងភ័ស្តុតាងដាក់បន្ទុក និងដោះបន្ទុក ។ ទោះបីជាយ៉ាងណាក៏ដោយ វាមានការលំបាកក្នុងការវាយតម្លៃថាតើសហចៅក្រមស៊ើបអង្កេតដែលត្រូវបានគេសន្មតថាមានភាពមិនលម្អៀងដោយបានស្បថនៅការិយាល័យសហចៅក្រមស៊ើបអង្កេតនៅការិយាល័យបានធ្វើបែបនោះនៅពេលអនុវត្តការងារជាក់ស្តែងដែរឬទេ ។ បញ្ហានេះបានធ្វើឲ្យអ្នកដាក់ពាក្យបណ្តឹងមិនជឿទៅលើការសន្មតនោះដូចដែលបញ្ញវន្ត ដេវីឌ អមើរ៉េដ បានលើកឡើងថាតើយើងត្រូវទុកការការពារបន្តិចបន្តួចឲ្យជនត្រូវចោទ ឬក៏ត្រូវធ្វើការ

ស៊ើបអង្កេតដោយយុត្តិធម៌ និងមានប្រសិទ្ធភាព ។

បញ្ហានីតិវិធីទាំងនេះត្រូវតែយកទៅវិភាគនៅក្នុងបរិបទដែលបញ្ហាបានកើតឡើងគឺត្រូវយកទៅវិភាគនៅក្នុងតុលាការកូនកាត់ដែលបង្កើតឡើងដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអំពើប្រល័យពូជសាសន៍ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវ ។ ការសន្មតថាមិនមានទោសហាក់ដូចជាមានការផ្លាស់ប្តូរនៅពេលដែលជនសង្ស័យត្រូវបានចោទប្រកាន់ពីការសម្លាប់រង្គាល ។ វាមានភាពជាក់ស្តែងថាសកម្មភាពពិតជាបានកើតឡើងហើយជនសង្ស័យស្ទើរតែមិនអាចបដិសេធនូវការចូលរួមក្នុងសកម្មភាពនោះទៀតផង ។ អមេរីដ ដែលលើកឡើងពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដែលមានការប្រឆាំងគ្នាថានៅក្រោមកាលៈទេសៈបែបនោះ គោលដៅកាត់ទោសជាមូលដ្ឋានគឺផ្តោតតែទៅលើសំណួរមួយថាតើជនត្រូវចោទមានទោសឬទេ? ការធ្វើបែបនេះអាចបណ្តាលឲ្យដំណើរការកាត់ទោសមានភាព «ជាក់ស្តែងស្រដៀងទៅនឹងការព្យាបាលជំងឺដែលត្រូវបានគេពិនិត្យឃើញរោគសញ្ញាហើយរួចថាយើងត្រូវដោះស្រាយបញ្ហាមិនមែនស៊ើបអង្កេតថាបញ្ហាគឺជាអ្វីទេ» ។

អំណាចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការធ្វើសកម្មភាពដើម្បីស្វែងរកការពិតនិងបដិសេធសំណើដោយផ្អែកទៅលើមូលដ្ឋានច្បាប់ដ៏ទូលាយ បានចោទជាបញ្ហាថាតើអ្នកទាំងនោះមានឆន្ទានុសិទ្ធិទូលំទូលាយដែលអាចកំណត់ទៅលើសិទ្ធិរបស់ភាគីមិនឲ្យចូលរួមក្នុងសំណុំរឿងដែរឬទេ ឬថាតើភាគីមានសិទ្ធិទទួលបានជំនួយពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយយោងទៅតាមវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬយុត្តិសាស្ត្រអន្តរជាតិដែលធ្លាប់មានពីមុននិងច្បាប់ប្រពៃណីដែរឬទេ ។

## ៣) តួនាទីរបស់សហចៅក្រមស៊ើបអង្កេតក្នុងការឆ្លើយតបនឹងសំណើស៊ើបអង្កេត

បញ្ហាមួយចំនួនបានកើតឡើងនៅដំណាក់កាលស៊ើបអង្កេតមុនពេលការកាត់ក្តីសំណុំរឿង០០១ និង០០២ គឺថាតើសិទ្ធិមូលដ្ឋានរបស់ជនត្រូវចោទត្រូវបានគេការពារដែរឬទេ? ជាក់ស្តែង មេធាវីការពារក្តីបានលើកឡើងពីបញ្ហាទាក់ទងនឹងតួនាទីរបស់សហចៅក្រមស៊ើបអង្កេតក្នុងការស្វែងរកភស្តុតាងដោះបន្ទុកអំពីការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតក្នុងការធ្វើបទសម្ភាសជាមួយសាក្សីនិងអំពីលទ្ធភាពរបស់សហចៅក្រមស៊ើបអង្កេតក្នុការស្នើសុំស្វែងរកនិងស៊ើរើភស្តុតាងដោះបន្ទុក ។

បណ្តុំទិន្នន័យដែលអាចស្វែងរកបានគឺជាមូលដ្ឋានទិន្នន័យដែលភាគីទាំងអស់និងតុលាការអាចរកបានតាមរយៈបណ្តាញស្វែងរកព័ត៌មានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ បណ្តុំទិន្នន័យនោះរួមមានឯកសារនិងវីដេអូដែលមិនទាន់ត្រូវបានយកទៅវិភាគ ប៉ុន្តែត្រូវបានគេចាត់ទុកថា មានជាប់ពាក់ព័ន្ធសំខាន់នឹងសំណុំរឿង ។ ឯកសារដែលមាននៅក្នុងបណ្តុំទិន្នន័យនោះរួមមាន ឯកសារផ្សេងៗ កំណត់ត្រា បទសម្ភាសន៍វីដេអូខ្លីៗរបស់កាសែត និងភស្តុតាងនៃរចនាសម្ព័ន្ធនិងការគ្រប់គ្រងរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ មេធាវីការពារក្តីបានអះអាងថាសហចៅក្រមស៊ើបអង្កេតមានតួនាទីស៊ើបអង្កេតទៅលើបណ្តុំទិន្នន័យនោះដើម្បីស្វែងរកភស្តុតាងដោះបន្ទុកដែលមានសក្តានុពល ។ ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតបានបដិសេធមិនពិនិត្យទៅលើឯកសារដែលមាននៅក្នុងបណ្តុំទិន្នន័យនោះទេ ។ អង្គបុរេជំនុំជម្រះបានយល់ស្របទៅលើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងប្រធានបទនោះ ។

មេធាវីការពារក្តីក៏បានបង្ហាញពីការព្រួយបារម្ភដែលថាសិទ្ធិដែលត្រូវទទួលបានការកាត់ក្តីដ៏យុត្តិធម៌របស់កូនក្តីគាត់អាចនឹងត្រូវបានរំលោភបំពានដោយការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតមិនព្រមធ្វើបទសម្ភាសជាមួយសាក្សីតំណាងឲ្យមេធាវីការពារក្តី ។ សហមេធាវីការពារក្តី នួន ជា បានស្នើឲ្យមានការធ្វើបទសម្ភាសដើម្បីដាក់នៅក្នុងឯកសារសំណុំរឿង ប៉ុន្តែសហចៅក្រមស៊ើបអង្កេតតែងតែបដិសេធនឹងសំណើនេះម្តងហើយម្តងទៀតដោយអះអាងថា ភស្តុតាងដែលស្រដៀងគ្នានឹងមានប្រសិទ្ធភាពដូចគ្នាមាននៅក្នុងឯកសារសំណុំរឿងរួចទៅហើយ ។ ការធ្វើបែបនេះអាចដាក់កំហិតទៅលើសិទ្ធិដែលត្រូវទទួលបានភស្តុតាងដោះបន្ទុកនិងសិទ្ធិទទួលបានការកាត់ទោសដ៏មានប្រសិទ្ធភាព ។

មេធាវីការពារក្តីក៏បានអះអាងថាការទទួលបានភស្តុតាង

ពីសាក្សីនិងភស្តុតាងដោះបន្ទុករបស់ខ្លួនគឺមានកំណត់ ដោយសារតែការខ្វះខាតបទដ្ឋានស៊ើបអង្កេតនិងការពិសោធន៍ច្បាស់លាស់ ព្រមទាំងការយល់ឃើញខុសគ្នាទៅលើវិធានផ្ទៃក្នុងថាតើអ្នកណាជាអ្នកមានបន្ទុកស្វែងរក ត្រួតពិនិត្យ និងរួមបញ្ចូលភស្តុតាងដោះបន្ទុកនៅក្នុងឯកសារសំណុំរឿង ។ ទោះបីជាភាគីទាំងអស់មានសិទ្ធិស្នើឲ្យមានការស៊ើបអង្កេតក៏ដោយ ក៏សិទ្ធិនេះអាចផ្តល់ជាជំនួយតែបន្តិចបន្តួចប៉ុណ្ណោះពីព្រោះសហចៅក្រមស៊ើបអង្កេតមានសិទ្ធិមិនធ្វើតាមសំណើនេះបាន ។

### ក) ការកំណត់និយមន័យសំណើស៊ើបអង្កេត

*១) ប្រភេទនៃសំណើ*

វិធានមិនបានកំណត់ច្បាស់លាស់ថាតើអ្វីកំណត់ឲ្យមានសកម្មភាពស៊ើបអង្កេតទេ ហើយក៏មិនបានកំណត់ពីដែនកំណត់ត្រឹមត្រូវទៅលើសំណើស៊ើបអង្កេតដែរ ។

*២) ភាពជាក់លាក់នៃសំណើ*

សំណើរបស់ភាគីដែលស្នើទៅសហចៅក្រមស៊ើបអង្កេតឲ្យចេញដីកាឬចាត់វិធានការស៊ើបអង្កេតត្រូវតែស្របនឹងភាពជាក់លាក់មួយចំនួនដើម្បីធានាថាសហចៅក្រមស៊ើបអង្កេតយល់ពីសំណើ ។ ប៉ុន្តែ វិធានផ្ទៃក្នុងមិនបានចែងពីកម្រិតនៃភាពជាក់លាក់នោះទេ តែបែរជាបន្សល់នូវភាពមិនច្បាស់លាស់ថាតើសហចៅក្រមស៊ើបអង្កេតបានរំលោភលើឆន្ទានុសិទ្ធិដោយបដិសេធនឹងសំណើដោយមិនមានមូលហេតុច្បាស់លាស់ដែរឬទេ ឬថាតើភាគីបានដាក់សំណើមិនត្រឹមត្រូវឬទេ ដូច្នេះវាបានធ្វើឲ្យខាតប្រយោជន៍តុលាការ ។

ទាំងសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះបានអះអាងថាសំណើឲ្យមានការស៊ើបអង្កេតត្រូវតែបង្ហាញពីភាពជាក់លាក់ថាតើហេតុអ្វីបានជាសហចៅក្រមស៊ើបអង្កេតត្រូវតែចាត់វិធានការស៊ើបអង្កេត ។ មេធាវីការពារក្តីមួយចំនួនដែលរួមមានមេធាវីរបស់ អៀង ធីរិទ្ធ, អៀង សារី និង នួន ជា បានបំពេញនូវមូលហេតុច្បាស់លាស់ដូចដែលបានកំណត់នៅពេលដែលស្នើឲ្យសហចៅក្រមស៊ើបអង្កេតដាក់ឯកសារបន្ថែមទៅក្នុងបណ្តុំឯកសារសម្រាប់ស្រាវជ្រាវទៅលើសំណុំរឿង ។ អង្គបុរេជំនុំជម្រះបានអះអាងថានៅពេលដែលបណ្តុំទិន្នន័យមិនមានភស្តុតាងដាក់បន្ទុក សហចៅក្រមស៊ើបអង្កេតមិនតម្រូវឲ្យពិនិត្យទៅលើរាល់ឯកសារដែលមាននៅក្នុងបណ្តុំទិន្នន័យនោះទេ ។

អាស្រ័យហេតុនេះ វិធានផ្ទៃក្នុងមិនបានចែងពីបទដ្ឋានច្បាស់លាស់ដែលថាសហចៅក្រមស៊ើបអង្កេតត្រូវយល់ស្របឬបដិសេធសំណើសុំឲ្យស៊ើបអង្កេត ដោយបន្សល់នូវឆន្ទានុសិទ្ធិឲ្យសហចៅក្រមស៊ើបអង្កេតអាចពិនិត្យលើតាមសំណើនីមួយៗ ។

### ៣) ទស្សនៈដែលមានហេតុផល

វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចែងថាសហចៅក្រមស៊ើបអង្កេតមានឆន្ទានុសិទ្ធិបដិសេធរាល់សំណើដែលខ្វះភាពជាក់លាក់ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតមានតួនាទីផ្តល់ហេតុផលនៅពេលដែលខ្លួនយល់ស្រប ឬបដិសេធនឹងសំណើស្នើឲ្យមានការស៊ើបអង្កេត ។

ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតតែងតែខកខានមិនបានផ្តល់ហេតុផល ឬតែងតែផ្តល់សម្អាងមិនច្បាស់លាស់ពីការបដិសេធសំណើ ឬច្រានចោលនូវសំណើនោះដោយអះអាងថាសំណើមិនមានមូលហេតុច្បាស់លាស់ ។ ការធ្វើបែបនេះបានធ្វើឲ្យភាគីមិនអាចកំណត់នូវមូលដ្ឋានជាក់លាក់របស់សហចៅក្រមស៊ើបអង្កេតចំពោះការយល់ស្រប ឬការបដិសេធនឹងសំណើ ។ ជាងនេះទៅទៀត នៅពេលដែលសហចៅក្រមស៊ើបអង្កេតបដិសេធនឹងសំណើដោយលើកតែពីមូលហេតុថាខ្វះភាពជាក់លាក់ មេធាវីការពារក្តីមិនបានទទួលបានព័ត៌មានគ្រប់គ្រាន់ដើម្បីកែសម្រួលសំណើរបស់ខ្លួនឲ្យមានការស៊ើបអង្កេតទេ ។

ដូច្នេះ ការមិនផ្តល់ហេតុផលច្បាស់លាស់របស់សហចៅក្រមស៊ើបអង្កេតទៅលើសេចក្តីសម្រេចបានកំណត់ទៅលើលទ្ធភាពរបស់អង្គបុរេជំនុំជម្រះក្នុងការធ្វើសេចក្តីសម្រេច ។ បន្ថែមទៅលើភាពតម្រូវដែលថាសហចៅក្រមស៊ើបអង្កេតត្រូវផ្តល់ហេតុផល វិធានផ្ទៃក្នុងដែលបានចែងនូវរាល់សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះត្រូវតែមានមូលហេតុ ។

ទោះបីជាវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតម្រូវថាសហចៅក្រមស៊ើបអង្កេតត្រូវផ្តល់ហេតុផលប្រសិទ្ធភាពនៃការតម្រូវនេះត្រូវបានបាត់បង់នៅពេលដែលវាត្រូវបានជំនួសដោយសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត

ក្នុងការបដិសេធនឹងសំណើដោយអះអាងថា សំណើមានភាពមិនជាក់លាក់ ។ ផ្ទុយទៅវិញ មេធាវីនិងអង្គបុរេជំនុំជម្រះនៅតែមិនដឹងថាត្រូវធ្វើយ៉ាងណាឲ្យសំណើរបស់ខ្លួនមានភាពច្បាស់លាស់ជាងមុន គឺអ្នកទាំងនោះមានការលំបាកក្នុងការបំពេញតួនាទីរបស់ខ្លួន ។

### ក) បទដ្ឋាននៃការពិនិត្យទៅលើសំណើស៊ើបអង្កេត

*១) ការកំណត់និយមន័យនៃភស្តុតាងដោះបន្ទុក*

បញ្ហាសំខាន់ទាក់ទងនឹងការរក្សាគុណភាពនៃសិទ្ធិគឺថាតើសហចៅក្រមស៊ើបអង្កេតមានតួនាទីស្វែងរកភស្តុតាងដោះបន្ទុកដែលមានលក្ខណៈដោះបន្ទុក ឬស្វែងរកភស្តុតាងដោះបន្ទុកដែលមានសក្តានុពលក្នុងការដោះបន្ទុក ។ ភស្តុតាងដោះបន្ទុកត្រូវបានគេឲ្យនិយមន័យថាជាភស្តុតាងដែលមានទំនោរដែលអាចបង្កើតថាចុងចោទគ្មានទោស ។

*២) បទដ្ឋាននៃការរួមបញ្ចូល*

ទោះបីជាវិធានផ្ទៃក្នុងតម្រូវថាសហចៅក្រមស៊ើបអង្កេតត្រូវផ្តល់មូលហេតុជាក់ស្តែងនៅពេលត្រួតពិនិត្យទៅលើសំណើស៊ើបអង្កេតក៏ដោយ ក៏ការអនុវត្តតាមផ្លូវច្បាប់ចំពោះការយល់ស្រប ឬបដិសេធគឺមិនមានភាពច្បាស់លាស់ទេ ។ បទដ្ឋានដែលសហចៅក្រមស៊ើបអង្កេតប្រើប្រាស់ដើម្បីវាយតម្លៃទៅលើសំណើឲ្យមានការស៊ើបអង្កេតគឺអាស្រ័យទៅលើថាតើសំណើនោះអាចនាំទៅរកឃើញការពិតឬទេ ។ ទោះបីជាយ៉ាងណាក៏ដោយ សហចៅក្រមស៊ើបអង្កេតហាក់ដូចជាប្រើប្រាស់ការសាកល្បងប្លែកៗគ្នាមួយចំនួនធ្វើជាមូលដ្ឋានសម្រាប់វាយតម្លៃថាតើសំណើនោះអាចនាំទៅរកការឃើញការពិតឬទេ ។ ការធ្វើបែបនេះបានបង្កឲ្យមានការព្រួយបារម្ភថាតើការស៊ើបអង្កេតគឺជាការងារដែលគេត្រូវផ្តោតទៅលើ ឬវាត្រូវបានគេធ្វើឡើងដោយឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ។

វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនមានបទដ្ឋានត្រួតពិនិត្យការស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតប្រហែលជាធ្វើទៅលើអ្វីដែលបានកើតឡើងជាក់ស្តែងដោយមិនពិចារណាទៅលើបញ្ហាដែលអាចប៉ះពាល់ដល់អំណាចរបស់ខ្លួន ។ ជាឧទាហរណ៍ សហចៅក្រមស៊ើបអង្កេត



នួន ជា

ប្រហែលជាប្រើប្រាស់អំណាចរបស់ខ្លួនច្រើនហួសទៅលើការបដិសេធសំណើនៅពេលដែលខ្លួនកំណត់ថាត្រូវប្រានចោលរាល់ការស៊ើបអង្កេតដែលប្រហែលជាអាចបណ្តាលឲ្យមានការពន្យារពេលដំណើរការ ។

ទោះបីជាការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតថាសិទ្ធិទទួលបានការកាត់ក្តីដោយមិនពន្យារពេលគឺជាមូលហេតុដែលនាំឲ្យមិនមានការរួមបញ្ចូលភ័ស្តុតាងបន្ថែម មាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយមិនបានបែងពីឋានានុក្រមនៃសិទ្ធិរបស់ជនត្រូវចោទទេ ។ តាមការពិត សិទ្ធិទទួលបានការកាត់ទោសដោយមិនពន្យារពេលគឺជាសិទ្ធិតូចមួយដែលស្ថិតនៅក្នុងសិទ្ធិរួមដែលបែងពីការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌ ។ អាស្រ័យហេតុនេះ ប្រសិនបើមានការប្រើប្រាស់ឋានានុក្រមណាមួយ សិទ្ធិទទួលបានការកាត់សេចក្តីដោយមិនមានការពន្យារពេលប្រហែលជាត្រូវគេយកមកថ្លឹងថ្លែងថាតើសិទ្ធិនោះអាចនាំទៅរកប្រប៉ះពាល់ដល់ការកាត់សេចក្តីដោយយុត្តិធម៌ឬទេ ។ សិទ្ធិរបស់ជនត្រូវចោទមិនគួរត្រូវបានគេយកទៅបំបែកដើម្បីប្រឆាំងគ្នាទេ ។ ហើយសហចៅក្រមស៊ើបអង្កេតមិនគួរប្រើប្រាស់វាមកធ្វើជាសម្អាងមកពន្លឿនដំណើរការកាត់សេចក្តីដើម្បីបញ្ចៀសនូវការស៊ើបអង្កេតដ៏ច្បាស់លាស់ដើម្បីស្វែងរកភ័ស្តុតាងដោះបន្ទុកទេ ។ ជនត្រូវចោទមានសិទ្ធិទទួលបានការកាត់សេចក្តីដ៏យុត្តិធម៌ ។

ភាគច្រើន សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះបានឲ្យអត្ថិភាពទៅលើការតម្រូវពីរ ដើម្បីឲ្យសហចៅក្រមស៊ើបអង្កេតឈានទៅដល់ការយល់ស្របនឹងសំណើ ។ សំណើត្រូវតែមានជាប់ពាក់ព័ន្ធនឹងអង្គហេតុដែលនាំឲ្យមានការស៊ើបអង្កេត ហើយសំណើនោះមិនត្រូវដូចនឹងអ្វីដែលមាននៅក្នុងបណ្តុំទិន្នន័យសម្រាប់ស្រាវជ្រាវស្រាប់ ។

ប៉ុន្តែ បទដ្ឋានទាំងពីរសុទ្ធតែមិនមានភាពច្បាស់លាស់នៅពេលយកមកអនុវត្តប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនពន្យល់ពីវិធីសាស្ត្រក្នុងការប្រើប្រាស់បទដ្ឋាននោះ ។ មេធាវីការពារក្តីត្រូវតែយល់ដឹងពីអ្វីដែលចៅក្រមនឹងពិចារណាថាជា «ភ័ស្តុតាង» និងអ្វីដែលត្រូវបញ្ចូលទៅក្នុងសំណុំរឿងដើម្បីធ្វើសំណើដ៏មានប្រសិទ្ធភាពមួយសម្រាប់ស្នើឲ្យមានការស៊ើបអង្កេតបន្ថែម ។

## ៤) បន្ទុក

*ក) បទដ្ឋានដែលគេយកទៅប្រើប្រាស់*

ទំនួលខុសត្រូវរបស់សហចៅក្រមស៊ើបអង្កេតក្នុងការប្រមូលឬត្រួតពិនិត្យទៅលើភ័ស្តុតាងគឺជាបញ្ហាជាក់ស្តែងមួយសម្រាប់មេធាវីការពារក្តី ។ វាជាបញ្ហាដែលមេធាវីការពារក្តីមិនយល់ស្របនឹងសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ ។ យោងទៅតាមរចនាសម្ព័ន្ធ ប្រព័ន្ធច្បាប់ស៊ីវិលបានផ្តល់តួនាទីនាំមុខដល់ព្រះរាជអាជ្ញានិងសហចៅក្រមស៊ើបអង្កេតក្នុងការប្រមូល និងត្រួតពិនិត្យភ័ស្តុតាង និងកំណត់ចំណុចសំខាន់នៃសំណុំរឿង ។ ការធ្វើបែបនេះបានបង្រួមដំណើរការ ស៊ើបអង្កេត និងធ្វើឲ្យមេធាវីការពារក្តីមានតួនាទីមិនសូវជាសកម្មបើប្រៀបធៀបទៅនឹងប្រព័ន្ធច្បាប់ខមិនឡូ ។ មេធាវីការពារក្តីបានចោទប្រកាន់ថាចៅក្រមស៊ើបអង្កេតបានផ្តោតតែទៅលើការផ្តល់សម្អាងទៅលើទោសរបស់ជនត្រូវចោទ ដូច្នេះវាបណ្តាលឲ្យមានការរំលោភទៅលើសិទ្ធិរបស់ជនត្រូវចោទក្នុងការរកភ័ស្តុតាងដោះបន្ទុកនៅក្នុងសំណុំរឿង ។

យុត្តិសាស្ត្រដែលធ្លាប់មានពីមុនដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានស្នើថាមេធាវីការពារក្តីមិនគួរស្វែងរកភ័ស្តុតាងដោះបន្ទុកទេ វាគឺបន្ទុករបស់ចៅក្រមនិងសហព្រះរាជអាជ្ញាក្នុងការស្វែងរកភ័ស្តុតាង បើតាមរចនាសម្ព័ន្ធរបស់តុលាការ ។ ដូច្នេះ សហព្រះរាជអាជ្ញាគួរតែចោទប្រកាន់បន្ទុកដ៏តឹងរ៉ឹងក្នុងការស្រាវជ្រាវ និងបង្ហាញភ័ស្តុតាងពីព្រោះវាជាផ្នែកមួយក្នុងដំណើរការប្រមូលឯកសារបឋមដែលនាំទៅរកការកសាងសំណុំរឿងសម្រាប់ចៅក្រមស៊ើបអង្កេត ។ នៅក្នុងការស៊ើបអង្កេតដោយមិនលម្អៀង សហចៅក្រមស៊ើបអង្កេតគួរតែធានាថាមេធាវីការពារក្តីអាចប្រមូលបានភ័ស្តុតាងដោះបន្ទុកតាមរយៈចៅក្រមផ្ទាល់ ឬតាមរយៈការបង្គាប់បញ្ជាពីសហព្រះរាជអាជ្ញា ។

## ៥) ពេលវេលាសម្រាប់ពិចារណា

*ក) វិធានផ្ទៃក្នុង*

វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចែងថាប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនយល់ស្របនឹងសំណើឲ្យមានការស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតត្រូវតែចេញដីកាបដិសេធឲ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន ហើយនៅគ្រប់ករណីគឺត្រូវចេញដីកាមុនពេលបញ្ចប់ការស៊ើបសួរ ។ ភាពយឺតយ៉ាវក្នុងការឆ្លើយតបរបស់សហចៅក្រមស៊ើបអង្កេតទៅនឹងសំណើឲ្យមានការស៊ើបអង្កេតអាចបណ្តាលឲ្យមានការព្រួយបារម្ភមួយចំនួនដល់ភាគី ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតរង់ចាំរហូតដល់ការបញ្ចប់ការស៊ើបអង្កេតទើបបដិសេធសំណើ មិនត្រឹមតែភាគីទេដែលមិនអាចដំណើរការទៅមុខបានសិទ្ធិរបស់ភាគីក្នុងការស្នើសុំក៏បាត់បង់ដែរ ។

វាហាក់ដូចជាមានការយល់ស្របគ្នារវាងតុលាការអន្តរជាតិនិងតុលាការ ព្រះរាជអាជ្ញាមានតួនាទីបង្ហាញពីភស្តុតាងដោះបន្ទុកទៅកាន់មេធាវីការពារក្តី ។ ការអនុវត្តវិធាននីតិវិធីស្រដៀងគ្នានេះទៅកាន់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងការបង្ហាញភស្តុតាងដោះបន្ទុកប្រហែលជាអាចធានានូវសិទ្ធិរបស់ភាគីការពារក្តីឲ្យទទួលបានភស្តុតាងដែលជាប់ពាក់ព័ន្ធ ។ ជាងនេះទៅទៀត អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចទទួលបានផលប្រយោជន៍ពីការបង្ហាញវិធាននីតិវិធីរបស់តុលាការអន្តរជាតិ ដូចជាវិធាន៨៤របស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែលអនុញ្ញាតឲ្យអង្គជំនុំជម្រះអាចធ្វើដីកាចាំបាច់ណាសម្រាប់ស្នើឲ្យមានការបង្ហាញឯកសារឬព័ត៌មានដែលមិនមែនជាព័ត៌មានដែលធ្លាប់បង្ហាញរួចមកហើយ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រហែលជាអាចប្រើប្រាស់វិធានមួយដើម្បីបង្ហាញនូវពេលវេលានិងតួនាទីរបស់សហចៅក្រមស៊ើបអង្កេតក្នុងការបង្ហាញក្នុងភស្តុតាងដែលជាប់ពាក់ព័ន្ធ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រហែលជាអាចដំណើរការដោយមានប្រសិទ្ធភាពជាងនេះ ប្រសិនបើវិធានបែបនេះឆ្លើយតបនឹងតួនាទីជាក់លាក់ថាតើអ្នកណាត្រូវធានានូវការបង្ហាញព័ត៌មាន ហើយថាតើវាត្រូវស្ថិតនៅក្នុងរយៈពេលណាជាជាងទុកឲ្យភាគីធ្វើសំណើដដែលៗស្នើឲ្យមានការបង្ហាញភស្តុតាង ហើយបន្ទាប់មកទទួលបានការបដិសេធនៅពេលដែលដាក់សំណើនោះទៅ ។ វិធាននីតិវិធីដែលផ្តល់តួនាទីសកម្មជាងមុនដល់សហចៅក្រមស៊ើបអង្កេតក៏អាចជួយសម្របសម្រួលដល់ការបង្ហាញភស្តុតាងនៅពេលកាត់សេចក្តីគឺថាវាអាចជួយធានាថាភស្តុតាងត្រូវបានបង្ហាញយ៉ាងឆាប់រហ័សនិងធានាឲ្យមានការកាត់សេចក្តីដ៏មានប្រសិទ្ធភាពជាងមុន ។ ការធ្វើបែបនេះអាចជួយបង្កើនផលប្រយោជន៍តុលាការគឺថាចៅក្រមនិងព្រះរាជអាជ្ញាត្រូវបង្ហាញនិងស្វែងរកភស្តុតាងនៅដំណាក់កាលស៊ើបអង្កេតដំបូងដែលផ្ទុយពីការមិនបង្ហាញឬបង្ហាញដ៏តិចតួចដែលអាចបណ្តាលឲ្យមានការពន្យារពេល ។

### ១) ដីកាបដិសេធ

អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានយល់ស្របនឹងសិទ្ធិរបស់ភាគីក្នុងការធ្វើបណ្តឹងឧទ្ធរណ៍នឹងដីកាបដិសេធ ។ អង្គបុរេជំនុំជម្រះបានរកឃើញថាការខកខានរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញសេចក្តីសម្រេចឲ្យឆាប់តាមដែលអាចធ្វើទៅបាននៅក្នុងកាលៈទេសៈដែលអាចបណ្តាលឲ្យខាតប្រយោជន៍ជនត្រូវចោទដោយការពន្យារពេលអាចបណ្តាលឲ្យមានការប្តឹងឧទ្ធរណ៍ដោយយោងទៅតាមវិធានផ្ទៃក្នុង៧៤ ។

អង្គបុរេជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់ថាវាមិនមានលក្ខណៈត្រឹមត្រូវក្នុងការប្រើប្រាស់ដីកាបដិសេធមកទាញយកសិទ្ធិប្តឹងឧទ្ធរណ៍ដែលមិនមានចែងនោះទេ ។ អង្គបុរេជំនុំជម្រះបានអះអាងថា សំណើឲ្យដាក់ឯកសារនៅក្នុងសំណុំរឿងមួយចំនួនដូចជាសំណើឲ្យបកប្រែឯកសារ គឺស័ក្តិសមជាសំណើឲ្យសហចៅក្រមស៊ើបអង្កេតចេញដីកា គឺមិនមែនជាសំណើឲ្យចាត់វិធានការស៊ើបអង្កេតទេ ។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា ភាពខុសគ្នានេះគឺមានសារសំខាន់ណាស់ ពីព្រោះមានតែសំណើឲ្យចាត់វិធានការស៊ើបអង្កេតទើបធ្វើឲ្យមានការស្វែងរកការពិត ។ វិធានផ្ទៃក្នុង៧៤(៣)(ខ) ចែងថា សិទ្ធិរបស់ជនត្រូវចោទក្នុងការប្តឹងឧទ្ធរណ៍គឺមានកំណត់ត្រឹមសេចក្តីសម្រេចស្នើឲ្យស៊ើបអង្កេត មិនមែនត្រឹមសំណើឲ្យចេញដីកាទេ ។ ចំណុចនេះបានដាក់កំហិតទៅលើអ្វីដែលជនត្រូវចោទអាចនឹងប្តឹងឧទ្ធរណ៍ និងអ្វីដែលត្រូវបានចាត់ទុកជាការបដិសេធដោយសារតែសំណើត្រូវតែស្របតាមវិធាន៥៥(១០) និង៧៤(៣)(ខ) ដែលបញ្ជាក់ថាសំណើសម្រាប់ការស៊ើបអង្កេត មិនមែនត្រឹមតែឲ្យចៅក្រមស៊ើបអង្កេតធ្វើសកម្មភាព

ប៉ុណ្ណោះទេ ។ អាស្រ័យហេតុនេះ សិទ្ធិរបស់ជនត្រូវចោទក្នុងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតត្រូវបានគេដាក់កំហិតដោយផ្អែកលើថាតើចៅក្រមនិងអង្គជំនុំជម្រះបែងចែកសំណើដោយរបៀបណា ។

## សេចក្តីបញ្ចប់

ចំណុចដែលខ្វះខាតនៅក្នុងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាក់ទិននឹងភ័ស្តុតាងដោះបន្ទុកគឺវិធានដែលទាក់ទងនឹងដែនកំណត់នៃភ័ស្តុតាងដោះបន្ទុកដែលជាភ័ស្តុតាងដែលត្រូវរួមបញ្ចូលទៅក្នុងសំណុំរឿង និងវិធានដែលបញ្ជាក់ថាតើវាជាបន្ទុករបស់សហចៅក្រមស៊ើបអង្កេតឬមេធាវីការពារក្តីជាអ្នកស្វែងរកស៊ើបអង្កេត និងពិនិត្យលើភ័ស្តុតាងដោះបន្ទុកដែរឬទេ ។ មានការអះអាងថានៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលចៅក្រមស៊ើបអង្កេតមានឆន្ទានុសិទ្ធិដ៏ទូលាយក្នុងការអនុវត្តការស៊ើបអង្កេតនិងឆ្លើយតបទៅនឹងសំណើ ។ ទោះបីជាយ៉ាងណាក៏ដោយ ភាពខ្វះខាតវិធាននីតិវិធីព្រាងដ៏ច្បាស់និងត្រឹមត្រូវបណ្តាលឲ្យមានភាពខ្វះខាតក្នុងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ ។ ការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់តុលាការដោយមិនយកចិត្តទុកដាក់ ឬអសមត្ថភាពអាចប៉ះពាល់ដល់ភាពជឿជាក់នៃដំណើរការកាត់សេចក្តីទាំងមូល ។ ការដែលអង្គបុរេជំនុំជម្រះកែលម្អសហចៅក្រមស៊ើបអង្កេតអំពីបទដ្ឋាននៃការឆ្លើយតបនឹងសំណើស៊ើបអង្កេតអាចបង្ហាញថាភាពខ្វះខាតនៃសេចក្តីណែនាំអំពីកាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេតបានបន្សល់នូវឆន្ទានុសិទ្ធិច្រើនពេកដល់ចៅក្រមក្នុងដំណើរការស៊ើបអង្កេតដើម្បីធានានូវភាពយុត្តិធម៌ ។ ទោះបីជាអង្គបុរេជំនុំជម្រះអាចប្រព្រឹត្តកំហុសខ្លះ វានៅតែមានចម្ងល់ថាតើសិទ្ធិរបស់ភាគីការពារក្តីត្រូវបានគេគោរពឬទេនៅពេលដែលអង្គបុរេជំនុំជម្រះបញ្ជូនសំណើត្រឡប់ទៅសហចៅក្រមស៊ើបអង្កេតវិញ ។ ដោយមិនគិតពីយន្តការនីតិវិធី ឬការគំរាមកំហែងដាក់ទណ្ឌកម្មដែលអាចធានាថាសហចៅក្រមស៊ើបអង្កេតអាចពិនិត្យមើលសំណើដោយមានពេលវេលានិងបទដ្ឋានត្រឹមត្រូវ គោលបំណងតែមួយនៃការត្រួតពិនិត្យរបស់តុលាការគឺពន្យារពេលដំណើរការតុលាការ ។

ការប្រើប្រាស់ទស្សនៈនីតិវិធីនៃប្រព័ន្ធច្បាប់ស៊ីវិលនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាបញ្ហាមួយប្រសិនបើយើងគិតទៅដល់លក្ខណៈពិសេសរបស់តុលាការ ។ ករណីរបស់តុលាការមានជាប់ពាក់ព័ន្ធនឹងច្បាប់ជាតិនិងអន្តរជាតិ មេធាវីអន្តរជាតិដែលមានបទពិសោធន៍នៅក្នុងប្រព័ន្ធច្បាប់ផ្សេងៗគ្នា មេធាវីនិងបុគ្គលិកតុលាការចម្រុះជាតិនិងអន្តរជាតិ និងការចោទប្រកាន់ដែលកើតចេញពីរឿងរ៉ាវដ៏ព្រៃផ្សៃ ។ ការប្រើប្រាស់វិធាននីតិវិធីនៃប្រព័ន្ធច្បាប់ស៊ីវិលដោយមិនពិចារណាថាតើវាស័ក្តិសមនឹងបរិបទនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយរបៀបណាគឺជាការមិនគិតទៅដល់ភាពស្មុគស្មាញនៃតុលាការនិងបញ្ហាដែលត្រូវជួបប្រទះក្នុងនាមជាតុលាការថ្មីដែលមិនមានពេលវេលាគ្រប់គ្រាន់សម្រាប់ធ្វើឲ្យដំណើរការប្រព្រឹត្តទៅយ៉ាងល្អ ។

ជាងនេះទៅទៀត ប្រសិនបើកម្ពុជាអាចកាត់ទោសមេដឹកនាំខ្មែរក្រហមដោយយុត្តិធម៌ពីឧក្រិដ្ឋកម្មសង្គ្រាម ភាពជោគជ័យបែបនេះប្រហែលជាធាតុផ្សំសំខាន់ជាងគេសម្រាប់ដំណើរការផ្សះផ្សានិងអនាគត ។ ម្យ៉ាងវិញទៀត ការកាត់សេចក្តីដោយយុត្តិធម៌និងមិនលម្អៀងនឹងមិនត្រឹមតែបង្ហាញនូវប្រសិទ្ធភាពនៃការកាត់សេចក្តីទេ តែថែមទាំងអាចបង្ហាញដល់អន្តរជាតិពីសមត្ថភាពរបស់កម្ពុជា គឺការរក្សាប្រទេសកម្ពុជាឲ្យស្ថិតនៅក្នុងស្ថានភាពដូចគ្នានឹងមុនពេលបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ ។

**ឌីណា ខតះថេស**

### កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរនឹងធ្វើការចាក់ផ្សាយកម្មវិធីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយ ឌី ខាំបូលី ដែលអ្នកទាំងអស់គ្នាអាចស្តាប់ថតចម្លងនិងអានសាច់រឿងដែលមាននៅក្នុងសៀវភៅនេះតាមរយៈគេហទំព័រ http://www.voanews.com/ khmer/democratic-kampuchea.cfm របស់វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ។ **មជ្ឈមណ្ឌលឯកសារកម្ពុជា**

# សាលក្រម ឌុច មានលក្ខណៈស្រាលពេក

ទាក់ទងនិងករណី ឌុច ខ្ញុំមានអារម្មណ៍ដូចគ្នាទៅនឹងអ្នករស់រានមានជីវិតផ្សេងទៀតពីរបបខ្មែរក្រហមដែរត្រង់ថា សាលក្រមមានលក្ខណៈស្រាលពេក ។ ទោះបីជាខ្ញុំដឹងថាគោលបំណងចម្បងបំផុតនៃការបង្កើតសាលាក្តីនេះគឺដើម្បីពង្រឹងឡើងវិញនូវបទដ្ឋានដែលថាជនដែលល្មើសខុសក្រិដ្ឋជនត្រូវតែនាំយកមកផ្តន្ទាទោសក៏ដោយ ក៏ខ្ញុំមានអារម្មណ៍ថា ការកាត់ទោសដែលមានលក្ខណៈស្រាលបែបនេះបានបង្រៀនមេរៀនដ៏ល្អមួយដល់ឧក្រិដ្ឋជនឬជនដែលល្មើសទៅវិញថាការកាត់ទោសនេះមិនមានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់សម្រាប់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនោះទេ ។ ខ្ញុំគិតថាការកាត់ទោសនេះគឺមិនធ្ងន់ស្មើនឹងទោសដែលដាក់មកលើឧក្រិដ្ឋជនធម្មតាម្នាក់ផង ។

ខ្ញុំក៏ដឹងដែរថាគោលដៅចម្បងមួយទៀតនៃការបង្កើតសាលាក្តីនេះគឺដើម្បីបង្កើតនូវប្រព័ន្ធច្បាប់មួយដែលត្រូវបានសង្ឃឹមថានឹងអនុវត្តនៅក្នុងប្រទេសកម្ពុជាក្រោយពេលដែលសាលាក្តីនេះត្រូវបានបញ្ចប់ ។ តែទោះជាយ៉ាងណា ចំណុចនេះនៅតែត្រូវ


ព្រះសង្ឃកំពុងទស្សនាការប្រកាសសាលក្រម ឌុច

ទន្ទឹងរង់ចាំមើលជាក់ស្តែងដដែលក្រោយពេលដែលសាលាក្តីនេះត្រូវបានបញ្ចប់ ។ ហើយខ្ញុំផ្ទាល់មានចម្ងល់ថា តើចំណុចនេះអាចកើតឡើងបានដែរឬទេនៅក្នុងប្រទេសកម្ពុជាដោយសារតែភាពស្រពេចស្រពិលនៅក្នុងផ្លូវនីតិប្រតិបត្តិ នីតិបញ្ញត្តិ និងតុលាការសព្វថ្ងៃនេះ ។ កង្វះខាតនៃភាពដាច់ស្រឡះរវាងផ្នែកឯកជន (បក្សនយោបាយ) និងផ្នែកសាធារណៈ (រដ្ឋាភិបាល) គឺជាឧបសគ្គចម្បងមួយទៀត ។ ដូចអ្វីដែលយើងបានមើលឃើញ ទោះបីជាមានវត្តមានពីសំណាក់អន្តរជាតិនៅក្នុងសាលាក្តីនេះនិងការឃ្លាំមើលពីខាងសហគមន៍អន្តរជាតិក៏ដោយ ក៏នៅតែមានលេចឮនូវភាពមិនប្រក្រតីជាច្រើនកើតឡើងនៅក្នុងអំឡុងប៉ុន្មានឆ្នាំមុននៃការដំណើរការរបស់សាលាក្តីខ្មែរក្រហម ។ ខ្ញុំនៅមានចម្ងល់ថាវប្បធម៌នៃការកាត់ទោសឧក្រិដ្ឋកម្មដែលបានកើតឡើងនេះនឹងមិនអាចស្ថិតស្ថេរនោះទេនៅក្នុងស្ថានភាពនៃប្រទេសកម្ពុជាបែបនេះនោះ ។

អ្វីដែលថាសាលក្រមនេះអាចរួមចំណែកនៅក្នុងការព្យាបាលរបួសផ្លូវចិត្តរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមគឺជារឿងមួយដែលយើងត្រូវទន្ទឹងរង់ចាំមើលបន្តទៀត ។ នេះគឺបានបង្កើតនូវមន្ទិលសង្ស័យកាន់តែខ្លាំងឡើងនៅពេលដែលអ្នករស់រានមានជីវិតជាច្រើននាក់បានរំពឹងទុកជាមុនថានឹងមានការកាត់ទោសឲ្យបានធ្ងន់ធ្ងរប៉ុន្តែអ្នកទាំងនោះមិនបានឈានដល់ការរំពឹងទុកនោះទេ ។ ផ្ទុយមកវិញ ខ្ញុំមានអារម្មណ៍ថាកម្រិតនៃរបួសផ្លូវចិត្តកាន់តែកើនឡើងនៅក្នុងចំណោមអ្នករស់រានមានជីវិតទៅវិញ ។ នេះគឺជារឿងធម្មតាទេនៅពេលដែលជនរងគ្រោះទាំងនោះមិនអាចឈានដល់ការរំពឹងទុករបស់ខ្លួននោះ ដែលអាចបង្កឲ្យមានការឈឺចាប់និងរបួសផ្លូវចិត្តកាន់តែខ្លាំងពេលដែលគាត់ធ្វើការប្រៀបធៀបទៅនឹងកម្រិតនៃភាពឃោរឃៅនិងទណ្ឌកម្មដែលជនរងគ្រោះបានទទួលរងកាលពីរបបខ្មែរក្រហម ។

មានពេលខ្លះឆ្ងល់ខ្ញុំថា តើថវិកាដ៏ច្រើនសន្ធឹកសន្ធាប់ទាំងនោះត្រូវបានចំណាយដោយរបៀបណាមកលើដំណើរការទាំងមូលនេះ ។ **សែន ទិចិត្រ**

# ការចងក្រងប្រវត្តិសាស្ត្រកម្ពុជា ៖

## ករណីមជ្ឈមណ្ឌលឯកសារកម្ពុជា

### ១) សេចក្តីផ្តើម

នៅឆ្នាំ១៨៧៦ ហ្សាន់ណូ ជាបញ្ញវន្តជនជាតិបារាំងម្នាក់ ដែលមានមូលដ្ឋាននៅទីក្រុងសាយហ្គន បានបោះពុម្ពរឿងព្រះគោ ព្រះកែវរៀបរាប់ពីដំណើររឿងនិទាននៃរូបចម្លាក់ពីរនៅក្រុងលង្វែក ដែលជាក្រុងដ៏ធំមួយដែលមិនមានសេះណាអាចរត់យ៉ាងលឿន ជុំវិញទីក្រុងនោះបានឡើយ ។ នៅក្នុង «ពោះ» របស់ព្រះគោនិង ព្រះកែវមានសៀវភៅមាសពិសិដ្ឋមួយដែលផ្ទុកព័ត៌មានដែល អាចឲ្យខ្មែរសិក្សាពីក្បួនតម្រា ឬ «សិក្សាអំពីអ្វីគ្រប់បែបយ៉ាងនៅ លើពិភពលោក» ។ យោងទៅតាមរឿងព្រះគោព្រះកែវនោះ ស្តេចសៀមចង់បានរូបចម្លាក់របស់ខ្មែរ ដូច្នេះក៏លើកទ័ពមកវាយ ខ្មែរដើម្បីយកសៀវភៅនោះនៅឆ្នាំ១៥៩៤ ។ បន្ទាប់ពីមាន ចម្បាំងមិនឈប់ឈររវាងសៀមនិងខ្មែរ មេទ័ពសៀមបានបញ្ជា ឲ្យទាហានដាក់ប្រាក់ខួងទៅក្នុងកាំភ្លើង ហើយបាញ់ទៅរនាំងព្រៃ ឫស្សីដ៏ក្រាស់ដែលព័ទ្ធជុំវិញទីក្រុងខ្មែរ ។ ដូចទៅនឹងអ្វីដែលបាន រំពឹងទុក ប្រជាជនលង្វែកបានចូលទៅព្រៃរើសប្រាក់ខួងនោះយ៉ាង លោភលន់ដោយកាប់ឫស្សីទាំងអស់និងបំផ្លាញរបាំងការពារក្រុង ។ នៅពេលដែលកងទ័ពសៀមត្រឡប់មកវិញម្តងទៀត អ្នកទាំងនោះ បានដណ្តើមយកក្រុងលង្វែកនិងសៀវភៅដ៏ពិសិដ្ឋនោះបាន ។ យោងទៅតាមការរៀបរាប់របស់ ហ្សាន់ណូ បានឲ្យដឹងថាសៀម «បានយកសៀវភៅដែលលាក់នៅទីនោះទៅសិក្សា ។ ដោយហេតុ ផលនេះហើយទើបសៀមបានក្លាយទៅជាមានចំណេះដឹងជាងខ្មែរ ហើយដោយហេតុផលនេះទើបប្រជាជនខ្មែរល្ងង់ខ្លៅហើយប្រទេស ខ្មែរខ្វះមនុស្សសំខាន់ខុសពីប្រទេសផ្សេង» ។ ទោះបីជាព្រះគោព្រះ កែវគ្រាន់តែជារឿងមួយ ប៉ុន្តែ វាបានប្រែក្លាយទៅជារឿងព្រេងនៅ ក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ។ ខណៈពេលដែលមិនមាន នរណាម្នាក់ដឹងច្បាស់ថាតើរឿងព្រេងនោះបានកើតមាននៅក្នុង ស្មារតីរបស់ប្រជាជនកម្ពុជាមុនពេល មានការបោះពុម្ពរឿងរបស់ ហ្សាន់ណូ ដែរឬទេ បារាំងបានប្រើប្រាស់រឿងនេះធ្វើជាផ្នែកមួយ នៃការដាក់អាណានិគមនិងមើលទៅប្រជាជនកម្ពុជាថាជាមនុស្ស «ទន់ខ្សោយ សាហាវ និងឃោរឃៅ» ដែលត្រូវការ «ជួយសង្គ្រោះ» ។ បារាំងបានប្រាប់ប្រជាជនកម្ពុជាម្តងហើយម្តងទៀតថាខ្លួនគឺជា «អ្នកឈ្នះ» និងប្រើប្រាស់រឿងព្រេងនោះដើម្បីទាមទារនូវអ្វីដែល បានបាត់បង់និងបង្កើននូវអ្វីដែលចាំបាច់សម្រាប់ខ្មែរ ។ រឿងព្រះ គោព្រះកែវនៅតែដក់នៅក្នុងចិត្តប្រជាជនជារួម ទោះបីជាបារាំង បានចាកចេញពីកម្ពុជាតាំងពីឆ្នាំ១៩៥៣ក៏ដោយ ។ នៅឆ្នាំ១៩៧១ នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជាក៏បានប្រើប្រាស់រឿងព្រេងនេះ ដើម្បីបកស្រាយពីការគ្រប់គ្រងតំបន់ដែលបានបាត់បង់របស់កម្ពុជា ទៅកាន់ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ។ ដូចដែល ខាធឺរីន ដាយអាមិន បានរៀបរាប់នៅក្នុងអត្ថបទ «ធ្វើឲ្យសមុទ្រទទេស្អាត» គាត់បានបង្ហាញពី «ការយល់ឃើញរបស់គាត់ទៅលើការបាត់បង់ របស់កម្ពុជាទៅឲ្យថៃនិងទស្សនៈដែលថាថៃបានលួចមរតករបស់ បុព្វបុរសកម្ពុជា ភាពលោភលន់របស់មនុស្សដែលក្បត់នឹងអ្នកមាន គុណនិងនាំមកនូវភាពវិនាសមកដាក់លើខ្លួនឯង ភាពទន់ខ្សោយ របស់ស្តេចនិងអ្នកជួយសង្គ្រោះដែលជាគោមានទំនាក់ទំនងជាមួយ នឹងគោនន្ទិនៃព្រហ្មញ្ញសាសនាដែលត្រូវបានឆ្លាក់នៅប្រាសាទអង្គរ វត្ត ។

ខណៈពេលដែល ដាយអាមិន បានរៀបរាប់ប្រហែលជា ត្រឹមត្រូវ រឿងរ៉ាវនោះក៏បានបកស្រាយថាតើការប្រើប្រាស់ពាក្យ សម្តីរបស់ជនអាណានិគមបានបន្តជះឥទ្ធិពលដល់ការសន្ទនា របស់កម្ពុជា ចំណេះដឹងទស្សនៈផ្ទាល់ខ្លួន ជារួមដែលជាការបន្ត របបអាណានិគម ទោះបីជានៅក្នុងទម្រង់ផ្សេងគ្នាដោយរបៀប ណាក៏ដោយ ។ នៅពេលជាមួយគ្នានេះ រឿងព្រេងក៏បានឆ្លុះ បញ្ចាំងពីបាតុភូតនៃការលុបបំបាត់ការយល់ដឹងពីប្រវត្តិសាស្ត្រ កម្ពុជា ។ ខណៈពេលដែលរឿងព្រេងបានលើកឡើងពី «សៀវភៅ

ដ៏ពិសិដ្ឋ» ដែលបានចាកចេញពីទឹកដី ហើយមិនដែលត្រឡប់មកវិញក៏មិនមានអ្នកណាដឹងច្បាស់ពីប្រភពដើមនៃរឿងនេះក៏ដូចជាប្រវត្តិសាស្ត្រកម្ពុជាដូចនឹងរឿងនេះដែរ។ ៤០០ឆ្នាំនៃ «សម័យកាលដ៏ខ្មៅងងឹតគឺស្ថិតនៅចន្លោះសម័យអង្គរនិងសម័យ ប៉ុលពត»។ ប្រវត្តិវិទូអាស៊ីអាគ្នេយ៍ ប៊ែន ឃៀរនិន បានអះអាងនៅក្នុងសៀវភៅ «ការកត់ត្រាប្រវត្តិសាស្ត្រនិងយុត្តិធម៌នៅកម្ពុជា **(Recovering History and Justice in Cambodia)**» ដែលបោះពុម្ពនៅឆ្នាំ២០០៤ថា «ជាថ្មីម្តងទៀតហើយដែលមនុស្សបានបោះបង់បណ្ណសារដ្ឋានរបស់ខ្លួន។ អ្នកដឹកនាំបានលុបបំបាត់គូបដិបក្ខចេញពីកំណត់ត្រា។ មេដឹកនាំអន្តរជាតិបានបដិសេធមិនទទួលស្គាល់ប្រវត្តិសាស្ត្រកម្ពុជានិងបិទបាំងឯកសារទាំងឡាយ»។ បន្ទាប់ពីរយៈពេលកន្លះសហសវត្សរ៍នៃសង្គ្រាមស៊ីវិលដែលរួមមានការធ្វើឲ្យខ្ទេចខ្ទាំដោយការគ្រប់គ្រងរបស់បរទេសចំនួនបីប្រទេស ការផ្លាស់ប្តូរប្រាំពីររបប ការគាបសង្កត់ និងអំពើប្រល័យពូជសាសន៍ បច្ចុប្បន្នកម្ពុជាកំពុងព្យាយាម «ចងក្រងប្រវត្តិសាស្ត្រ» និងរំឭកពីអតីតកាលរបស់ខ្លួន។

អត្ថបទនេះនឹងបង្ហាញពីកិច្ចខិតខំប្រឹងប្រែងនៃការចងក្រងឯកសារនោះនៅប្រទេសកម្ពុជាតាមរយៈការវិភាគទីតាំងបណ្ណសារដ្ឋានមួយ គឺមជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានទីតាំងនៅទីក្រុងភ្នំពេញនៃប្រទេសកម្ពុជា។ ក្នុងនាមជាកន្លែងផ្ទុកសម្ភារៈនិងឯកសារខ្មែរក្រហមច្រើនជាងគេ មជ្ឈមណ្ឌលឯកសារកម្ពុជាបានខិតខំប្រឹងប្រែងចងក្រង រក្សា និងចែករំលែកចំណេះដឹងអំពីរបបខ្មែរក្រហមដើម្បីជំរុញឲ្យមានការចងចាំនិងយុត្តិធម៌។ ថ្មីៗនេះដោយបានផ្ទុកនូវឯកសារជាងមួយលាន រូបថត៦០០០សន្លឹក និងសក្ខីកម្មជាសំឡេងនិងវីដេអូជាច្រើននៅក្នុងបណ្ណសារដ្ឋានរបស់ខ្លួន មជ្ឈមណ្ឌលឯកសារកម្ពុជាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់នូវការចងចាំជាបុគ្គលនិងជារួមទាក់ទងនឹងរបបខ្មែរក្រហម។ អត្ថបទនេះនឹងចាប់ផ្តើមបកស្រាយពីទស្សនៈដែលថាមជ្ឈមណ្ឌលឯកសារកម្ពុជាក៏ដូចជាបណ្ណសារដ្ឋានផ្សេងទៀតដែរគឺជាកន្លែងដែល «តែងតែមាន» អំណាចនិងឥទ្ធិពល ព្រមទាំងជា «កន្លែងបកប្រែ» មួយដែលធ្វើឲ្យ «អ្នកបន្ទាប់» អាចនិយាយប្រាប់អ្នកដទៃបាន។ ចំណុចទីពីរ គឺមានសារសំខាន់នៅក្នុងបរិបទមជ្ឈមណ្ឌលឯកសារកម្ពុជា ពីព្រោះការពិភាក្សាស្តីពីអំណាចនិងចំណេះដឹងនឹងអាចឲ្យយើងពិភាក្សាពីទីតាំងបណ្ណសារដ្ឋានដែលបង្កើតឡើងដោយសារស្ថានភាពដែលប៉ះពាល់យ៉ាងខ្លាំងដល់សតិអារម្មណ៍។

## ៧) ប្រវត្តិខ្មែរក្រហម

មុននឹងពិនិត្យទៅលើប្រវត្តិបណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា ចាំបាច់ត្រូវតែមានការបកស្រាយពន្យល់ពីប្រវត្តិទាំងឡាយដែលមាននៅមជ្ឈមណ្ឌលនេះ។ អំពើប្រល័យពូជសាសន៍របស់ខ្មែរក្រហមស្ថិតនៅចន្លោះនៃសង្គ្រាមស៊ីវិលរ៉ាំរ៉ៃ ការប្រើអំពើហិង្សាទៅលើជនជាតិភាគតិចការឈ្លានពានរបស់បរទេស ការដាក់អាណានិគម យុទ្ធនាការទម្លាក់គ្រាប់បែកសន្ធឹកសន្ធាប់ និងចក្រពត្តិនិយម។ ប្រវត្តិសាស្ត្រដ៏ច្របូកច្របល់ទាំងនេះបង្កឲ្យមានអំពើពុករលួយ ភាពក្រីក្រ ជំងឺអេដស៍ ពេស្យាចារ ការដណ្តើមដីធ្លី ការជួញដូរមនុស្ស និងអំពើហិង្សាក្នុងស្រុក ផ្លូវភេទ និងផ្លូវកាយ បានបន្តជំរុញឲ្យមានវដ្តនៃអំពើហិង្សាទៅលើវប្បធម៌ដែលបានចាក់ឫសគល់ «រួចទៅហើយ» នៅក្នុងស្ថានភាពដែលប៉ះពាល់យ៉ាងខ្លាំងដល់សតិអារម្មណ៍។

ខ្មែរក្រហមគឺជារបបកុម្មុយនីស្តដែលកើតចេញពីរបបម៉ាកស៊ីស និងរបបលេនីន និងបានបង្កឲ្យមានសង្គ្រាមស៊ីវិលជាមួយនឹងរដ្ឋាភិបាលកម្ពុជានៅដើមទសវត្សរ៍៧០។ ខ្មែរក្រហមក៏មានទំនាក់ទំនងជាមួយបក្សកុម្មុយនីស្តនៅឥណ្ឌូចិនដែរ។ នៅឆ្នាំ១៩៧៣ខ្មែរក្រហមបានគ្រប់គ្រងប្រទេសកម្ពុជាបាន៨៥ភាគរយ ហើយនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានគ្រប់គ្រងទីក្រុងភ្នំពេញ។ ប្រជាជនកម្ពុជាភាគច្រើនបានប្រមូលផ្តុំគ្នានៅលើផ្លូវនិងស្វាគមន៍ខ្មែរក្រហមដោយគិតថាជោគជ័យនេះគឺជាការបញ្ចប់សង្គ្រាមស៊ីវិលរបស់កម្ពុជានិងចក្រពត្តិអាមេរិក។ ប៉ុន្តែក្នុងពេលខ្មែរក្រហមបានបញ្ជានិងបង្ខំឲ្យប្រជាពលរដ្ឋទាំងអស់ចាកចេញពីផ្ទះរបស់ខ្លួនដើម្បីធ្វើដំណើរទៅជនបទ ប្រជាជនរាប់ពាន់នាក់បានស្លាប់នៅពេលជម្លៀសដោយសារការអស់កម្លាំង ហើយប្រជាជនជាច្រើនផ្សេងទៀតត្រូវបានយកទៅសម្លាប់។

បីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃ នៅពេលដែលខ្មែរក្រហមបាន

ប្រែក្លាយកម្ពុជាទៅជាសង្គមកសិកម្មដែលជាផ្នែកមួយនៃ «ផែនការបួនឆ្នាំ» ប្រជាជនទាំងអស់ត្រូវបានបញ្ជូនទៅធ្វើការដោយកម្លាំង ផ្តល់អាហារមិនគ្រប់គ្រាន់ និងបង្ខំឲ្យធ្វើការ១២ទៅ១៤ម៉ោងរាល់ថ្ងៃនៅក្រោមកម្តៅថ្ងៃដ៏ក្តៅ ។ ជាមួយគ្នានោះដែរ ខ្មែរក្រហមក៏បានលុបបំបាត់រូបិយប័ណ្ណ សាសនា ការអប់រំ រចនាសម្ព័ន្ធចាស់និងសម្លាប់អ្នកដែលត្រូវបានគិតថាជាសត្រូវរបស់ប្រទេសដោយមិនរើសមុខ ដូចជា វេជ្ជបណ្ឌិត គ្រូបង្រៀន មេធាវី ព្រះសង្ឃ និងអ្នកដែលមានទំនាក់ទំនងជាមួយរដ្ឋាភិបាល លន់ នល់ ។ ខណៈពេលដែលខ្មែរក្រហមបានអនុវត្តយុទ្ធនាការប្រល័យពូជសាសន៍នៅកម្ពុជា ខ្មែរក្រហមក៏បានធ្វើសង្គ្រាមនៅតាមព្រំដែនជាមួយវៀតណាម ហើយសង្គ្រាមនោះបានកើនឡើងយ៉ាងខ្លាំងនៅឆ្នាំ១៩៧៧ ។ ខ្មែរក្រហមបានចាប់ទាហាន និងប្រជាពលរដ្ឋវៀតណាមប្រុសស្រីដែលរស់នៅព្រំដែនវៀតណាម និងព្រំដែនកម្ពុជា បន្ទាប់មកបញ្ជូនទៅសម្លាប់នៅទួលស្លែងជាមួយនឹងកម្មាភិបាលខ្មែរក្រហមរាប់ម៉ឺននាក់ផ្សេងទៀត ដែលត្រូវបានសង្ស័យថាក្បត់បក្ស ។ ទីបញ្ចប់ នៅខែមករា ឆ្នាំ១៩៧៩ ទាហានវៀតណាមប្រមាណ១សែន៥ម៉ឺននាក់បានវាយលុកចូលកម្ពុជាដើម្បីបណ្តេញខ្មែរក្រហមចេញពីអំណាចនិងគ្រប់គ្រងប្រទេសរហូតដល់ឆ្នាំ១៩៨៩ដោយជោគជ័យ ។ នៅពេលដែលខ្មែរក្រហមធ្លាក់ពីអំណាចនៅដើមឆ្នាំ១៩៧៩ ប្រជាជនប្រមាណ១លាន៧សែននាក់ ដែលស្មើនឹងមួយភាគបួននៃប្រជាជនសរុបត្រូវបានស្លាប់ដោយសារជំងឺ ការអត់កម្លាំង ភាពអត់ឃ្លាន និងការសម្លាប់ ។ មិនមាននរណាម្នាក់នៅកម្ពុជាដែលមិនរងការប៉ះពាល់ដោយអំពើប្រល័យពូជសាសន៍ដែលបានសម្លាប់ប្រជាជនស្មើរតែមួយភាគបួននៃប្រជាជនសរុបទាំងអស់នោះទេ ។

ពីឆ្នាំ១៩៩២ រហូតដល់ឆ្នាំ១៩៩៥ អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជាបានរៀបចំការបោះឆ្នោតនៅកម្ពុជាលើកដំបូងឆ្នាំ១៩៩៣ ។ ចាប់តាំងពីឆ្នាំ១៩៩៣មក កម្ពុជាបានបន្តធ្វើការបោះឆ្នោតនិងខិតខំធ្វើការស្តារឡើងវិញនូវស្ថាប័នរដ្ឋាភិបាល សេដ្ឋកិច្ច ប្រព័ន្ធអប់រំនិងវិស័យទេសចរណ៍ ។

ទោះបីជាខ្មែរក្រហមត្រូវបានបណ្តេញពីអំណាចជាផ្លូវការនៅឆ្នាំ១៩៧៩ក៏ដោយ ក៏ខ្មែរក្រហមនៅតែបន្តគំរាមកំហែងប្រជាជនកម្ពុជាទាំងផ្លូវកាយនិងផ្លូវចិត្តដដែល ។ នៅតាមជនបទនៃប្រទេសកម្ពុជា ខ្មែរក្រហមបានបន្តយុទ្ធនាការរបស់ខ្លួនដោយវាយជាមួយទាហាននៅតាមព្រំដែន វាយចូលផ្ទះរបស់ប្រជាជន គប់គ្រាប់បែកចូលក្នុងផ្សារនិងសម្លាប់ប្រជាជនកម្ពុជាជាច្រើននាក់ ។ ទីបញ្ចប់ ចុងទសវត្សរ៍៩០ មេដឹកនាំខ្មែរក្រហមបានចុះចូលជាមួយគណបក្សប្រជាជនកម្ពុជាដែលនៅគ្រប់គ្រងអំណាចមកដល់បច្ចុប្បន្ន ។

## ៣) ការត្រួតពិនិត្យទៅលើបណ្ណសារដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

ធាតុផ្សំសំខាន់មួយនៅក្នុងការកសាងប្រទេសក្រោយសង្គ្រាមដែលយើងមិនទាន់ឃើញមានគឺការខ្វះខាតការទទួលខុសត្រូវរបស់មេដឹកនាំខ្មែរក្រហម ។ អ្នកដែលត្រូវទទួលខុសត្រូវចំពោះការស្លាប់របស់ប្រជាជនពី១,៤ទៅ២,២លាននាក់បានរស់នៅជាមួយអ្នកដែលនៅរស់ពីរបបខ្មែរក្រហម ។ មេដឹកនាំជាច្រើន ដូចជា ប៉ុល ពត បានស្លាប់ដោយស្ងៀមស្ងាត់ នៅផ្ទះរបស់គាត់ដោយមិនទទួលបានការកាត់ទោសទេ ។ ប៉ុន្តែមានក្តីសង្ឃឹមខ្លះថានឹងមានការផ្លាស់ប្តូរ ។ នៅខែកុម្ភៈ ឆ្នាំ២០០៦ នៅក្រោមការត្រួតពិនិត្យពីអង្គការសហប្រជាជាតិតុលាការអន្តរជាតិចម្រុះមួយត្រូវបានបង្កើតឡើងដើម្បីនាំយកមេដឹកនាំដែលនៅរស់ទាំងនោះទៅកាត់ទោស ។ តុលាការកាត់ទោសអំពើប្រល័យពូជសាសន៍ នៅពេលថ្មីៗនេះមានលក្ខណៈពិសេសនៅក្នុងប្រវត្តសាស្ត្រ ពីព្រោះតុលាការនេះមិនត្រឹមតែជាតុលាការកូនកាត់ដំបូងទេ តែថែមទាំងមានសក្តានុពលក្នុងការនាំយកមេដឹកនាំខ្មែរក្រហមទៅកាត់ទោសចំពោះឧក្រិដ្ឋកម្មដែលអ្នកទាំងនោះបានប្រព្រឹត្តទៀត ។

ដូចដែលអត្ថបទស្រាវជ្រាវជាច្រើនបានបកស្រាយច្បាស់លាស់បណ្ណសារដ្ឋានបានបង្ហាញពីអំណាចនយោបាយប្រវត្តិសាស្ត្រនិងការចងចាំ ។ ចំនួនពិតប្រាកដរបស់ភ្ញៀវមក មជ្ឈមណ្ឌលឯកសារកម្ពុជាអាចបង្ហាញពីសារសំខាន់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាចំពោះជីវិតប្រជាជនកម្ពុជាបច្ចុប្បន្ននិងតួនាទីរបស់មជ្ឈមណ្ឌលក្នុងការជួយសិក្សានិងកំណត់អត្តសញ្ញាណរបស់ខ្លួន ។

នៅឆ្នាំ២០០៩មានភ្ញៀវជាង១៨០០នាក់បានមកដល់

មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីធ្វើការស្រាវជ្រាវសិក្សាបន្ថែមពីរបបខ្មែរក្រហម និងស្វែងរកគ្រួសារដែលបានបាត់បង់នៅក្នុងរបបនោះ ។ នៅពេលជាមួយគ្នាដែរ មជ្ឈមណ្ឌលឯកសារកម្ពុជាបានអនុវត្តគម្រោងចុះទៅតាមមូលដ្ឋាន រៀបចំការតាំងពិព័រណ៍មួយចំនួននៅភ្នំពេញ និងនៅតាមខេត្ត អនុវត្តគម្រោងប្រវត្តិសាស្ត្រផ្ទាល់មាត់ ផលិតខ្សែភាពយន្តជាច្រើន ដឹកនាំសិស្សទស្សនកិច្ចទួលស្លែង និងជើងឯក សិក្សានិងចងក្រងពីលទ្ធផលនៃឥទ្ធិពលនៃរបបខ្មែរក្រហម ។ ដោយមានរោងពុម្ពខ្លួនឯងផ្ទាល់ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពនិងចែកចាយទស្សនាវដ្ដីស្វែងរកការពិតដែលរួមមានប្រវត្តិរបស់អ្នកនៅរស់ អត្ថបទជំនាញ ព័ត៌មានទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងព័ត៌មានផ្សេងទៀតទាក់ទងនឹងយុត្តិធម៌ ។ ជាងនេះទៅទៀត មជ្ឈមណ្ឌលឯកសារកម្ពុជាបានសរសេរ និងបោះពុម្ពសៀវភៅជាង២០ក្បាលទាក់ទងនឹងសក្ខីកម្មរបស់អ្នក យាមនិងអ្នកទោសនៅស-២១ការធ្វើទុក្ខបុកម្នេញ និងការបះបោររបស់ចាមមូស្លីម និងជីវិតរបស់ជនរងគ្រោះខ្មែរក្រហម ។ ជាសរុប មជ្ឈមណ្ឌលឯកសារកម្ពុជាមិនបានរំពឹងថាប្រជាជនកម្ពុជាទាំងអស់នឹងមកស្វែងរកព័ត៌មាននៅបណ្ណសារដ្ឋានរបស់ខ្លួន (ដោយសារប្រជាជនកម្ពុជាជាច្រើនមិនមានមធ្យោបាយធ្វើដំណើរមកភ្នំពេញ) ដូច្នេះមជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានខិតខំប្រឹងប្រែងយ៉ាងសកម្មចុះទៅតាមមូលដ្ឋានដោយឲ្យបុគ្គលិកទៅដល់ភូមិស្រុកនៃប្រទេសកម្ពុជាចែកចាយសម្ភារៈនឹងនិយាយជាមួយអ្នកនៅរស់ពីរបបខ្មែរក្រហម ។

អ្វីដែលប្រហែលជាសំខាន់ជាងគេនោះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានដើរតួនាទីមួយនៅក្នុងការបង្កើតតុលាការអន្តរជាតិមួយដែលមានការចូលរួមពីតុលាការកម្ពុជានិងអង្គការសហប្រជាជាតិដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលនៅរស់ ។ អនុស្សរណៈអង្គការសហប្រជាជាតិលេខ ក/៥៩/៤៣២ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៤ បានទទួលស្គាល់សារសំខាន់របស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងតុលាការដែលកំពុងដំណើរការ ។ អនុស្សរណៈបានរៀបរាប់ថា ៖

> មានការរំពឹងថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងពឹងផ្អែកយ៉ាងខ្លាំងទៅលើភស្តុតាងឯកសារជាច្រើន ។ ភស្តុតាងឯកសារចំនួនពីរសែនសន្លឹកត្រូវបានគេរំពឹងថានឹងយកទៅត្រួតពិនិត្យ ។ ឯកសារជាច្រើនត្រូវបានរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែលជាអង្គការក្រៅរដ្ឋាភិបាលមួយដែលធ្វើការស្រាវជ្រាវនិងរក្សាឯកសារស្ដីពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (យោបល់បន្ថែមពីអ្នកនិពន្ធ) ។

ស្រដៀងគ្នានេះដែរ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏ដើរតួនាទីក្នុងការណែនាំពន្យល់អំពីតុលាការនិងសាលក្រមទៅកាន់ប្រជាជន «ដោយជួយសម្រាយ» ពាក្យបច្ចេកទេសច្បាប់ ។

ការទទួលស្គាល់ថាមជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាវេទិកាពិភាក្សាមួយដែលជួយសម្រួលដល់ការពិភាក្សាវវាង «ប្រជាជន» គឺមានសារសំខាន់នៅក្នុងប្រទេសកម្ពុជា ។ ទោះបីជាមានការជះឥទ្ធិពលដល់បណ្ណសារដ្ឋានចំណេះដឹងនិងការចងចាំក៏ដោយ ក៏ប្រទេសកម្ពុជានិងប្រជាពលរដ្ឋនៅតែបន្តដោះស្រាយនឹងបញ្ហាដែលបណ្ដាលមកដាក់អាណានិគម ជម្លោះនិងអំពើប្រល័យពូជសាសន៍ដែរ ។

## ៤) ភាពស្ងៀមស្ងាត់

មុនពេលបង្កើតបណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជាអ្នកនៅរស់ជាច្រើននិយាយអំពីរបបខ្មែរក្រហមណាស់ ។ ដូច្នេះផ្នែកនៃអត្ថបទនេះនឹងបកស្រាយជាសង្ខេបទៅលើភាពស្ងៀមស្ងាត់របស់រដ្ឋាភិបាល សហគមន៍អន្តរជាតិ និងអ្នកនៅរស់ក្នុងទសវត្សរ៍ ៨០ និង៩០ និងភាពស្ងៀមស្ងាត់ដែលត្រូវបានទម្លាយដោយកិច្ចខិតប្រឹងប្រែងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

នៅឆ្នាំ១៩៩១គឺនៅពេលដែលកម្ពុជាទើបទទួលបានអធិបតេយ្យភាពពីវៀតណាមនិងមុនពេលមានមជ្ឈមណ្ឌលឯកសារកម្ពុជា រដ្ឋាភិបាលកម្ពុជាទើបតែបានប្រើប្រាស់នយោបាយជាតិមួយគឺ «បំភ្លេច» ចោលទាំងអស់នូវអ្វីដែលពាក់ព័ន្ធនឹងខ្មែរក្រហម ។ នៅក្នុងសន្និសីទកាសែតមួយនៅឆ្នាំ១៩៩៨ នាយករដ្ឋមន្ត្រី ហ៊ុន សែន បាននិយាយនិងជំរុញឲ្យប្រជាជនកម្ពុជាទាំងអស់ឲ្យ «ជីករណ្ដៅមួយហើយកប់អតីតកាលទៅក្នុងនោះ» ។ ចំពោះនាយករដ្ឋ

មន្ត្រីដែលជាអតីតកម្មាភិបាលខ្មែរក្រហមថ្នាក់ទាប ការបំភ្លេចគឺជាមធ្យោបាយដ៏ល្អបំផុតសម្រាប់ឆ្ពោះទៅមុខនិងផ្សះផ្សាអតីតកាលដ៏ «ខ្មៅងងឹត» របស់កម្ពុជា ។ វាគឺជាអ្វីដែលកម្ពុជាបានធ្វើមុនពេលមានមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយ ទូរទស្សន៍ កាសែតនិងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗក៏កម្រនិយាយអំពីរបបខ្មែរក្រហមដែរ ។

រដ្ឋាភិបាលរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន មិនមែនជារដ្ឋាភិបាលតែមួយដែលគាំទ្រគោលនយោបាយបំភ្លេចទេ សហគមន៍អន្តរជាតិក៏បានរក្សាភាពស្ងៀមស្ងាត់មិននិយាយអំពីរបបខ្មែរក្រហមអស់រយៈពេលម្ភៃឆ្នាំដែរ ។ មិនត្រឹមតែមហាសន្និបាតអង្គការសហប្រជាជាតិនៅឆ្នាំ១៩៨៩ទេដែលបដិសេធមិនទទួលស្គាល់ជនដៃដល់នៃរបបខ្មែរក្រហម អ្នកទាំងនោះក៏មិនដែលនិយាយពី «គោលនយោបាយកាត់ទោសនិងការដោះស្រាយនូវអតីតកាលដែលទើបតែកើតឡើងដែរ» ។ សូម្បីតែនៅក្នុងអំឡុងពេលបោះឆ្នោតរក្សាសន្តិភាពដែលរៀបចំដោយអង្គការសហប្រជាជាតិនៅឆ្នាំ១៩៩១-១៩៩៣ អង្គការសហប្រជាជាតិបានប្រកាសថា ប៉ុល ពត «មានសិទ្ធិសេរីភាពនិងឱកាសចូលរួមក្នុងដំណើរការបោះឆ្នោត» ដូចជាអ្នកដទៃដែរ ។

នយោបាយរបស់រដ្ឋាភិបាលដែលផ្តោតទៅលើ «ការបង្ខំឲ្យស្ងៀមស្ងាត់» មិនមែនជាហេតុផលតែមួយដែលជំរុញឲ្យប្រជាជនកម្ពុជាមិននិយាយពីអតីតកាលទេ វាក៏ដោយសារតែ «ការរក្សាភាពស្ងៀមស្ងាត់» បានចាក់ឫសគល់នៅក្នុងចិត្តគំនិតរបស់ប្រជាជនកម្ពុជា ។ នៅក្នុងប្រទេសដែលបានចាក់ឫសគល់យ៉ាងជ្រៅនៅក្នុងទស្សនៈនៃព្រះពុទ្ធសាសនា ប្រជាជនកម្ពុជាជាច្រើនជឿថាការឈឺចាប់គឺបណ្តាលមកពីកម្មពៀរ ហើយត្រូវតែទទួលស្គាល់ការឈឺចាប់ដើម្បីសម្រេចបានការត្រាស់ដឹង ។ ជាលទ្ធផលអ្នកនៅរស់ពីរបបខ្មែរក្រហមជាច្រើនបានលាក់ការស្តីបន្ទោសនៅក្នុងចិត្ត ហើយជ្រើសរើសការនៅស្ងៀមមិននិយាយស្តីជាជាង «ការបាក់មុខ» ។ លោក ឌីវ៉ុន ហ៊ីនតុន អ្នកចិត្តសាស្ត្រនៅសាកលវិទ្យាល័យហាវើដដែលមានជំនាញខាងជំងឺបាក់ស្បាតរបស់អ្នកភៀសខ្លួនកម្ពុជាបានរកឃើញនូវពាក្យមួយចំនួនដែលប្រជាជនកម្ពុជាប្រើប្រាស់ដើម្បីបង្ហាញពីការចង់ «បំភ្លេច» នូវអ្វីដែលមិនសប្បាយចិត្តឬកំហឹង ។ យោងទៅតាមលោក ហ៊ីនតុន ប្រជាជនកម្ពុជា «ពេលខ្លះបាននិយាយថាមនុស្សម្នាក់ៗមានកំហឹងបែបនេះ ហើយក៏លាក់ទុកវានៅក្នុងខ្លួន ទុកក្នុងខួរក្បាល ឬលាក់បង្កប់ក្នុងចិត្ត ។ យោងទៅតាមការបកស្រាយរបស់ ហ៊ីនតុន ប្រជាជនជាច្រើនបានព្យាយាមលាក់កំហឹងរបស់ខ្លួនប៉ុន្តែមិនដែលបំភ្លេចទេ ។

ជាងនេះទៅទៀត បណ្ឌិត ឈឹម សុធារ៉ា នាយកអង្គការចិត្តសង្គមអន្តរវប្បធម៌នៅទីក្រុងភ្នំពេញបានធ្វើកំណត់សម្គាល់ថា យន្តការដើម្បីរស់ដែលប្រជាជនកម្ពុជាបានរៀនពីរបបខ្មែរក្រហមបានសាយភាយនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ។ ដោយចង្អុលបង្ហាញពីទស្សនៈដាំដើមគរ ឬ «បិទមាត់ឲ្យជិត» បណ្ឌិត ឈឹម សុធារ៉ា បាននិយាយថាប្រជាជនកម្ពុជាបានជ្រើសរើសការ «មិននិយាយស្តី» ដើម្បីរស់ ។ ខណៈពេលដែលភាពស្ងៀមស្ងាត់បានសាយភាយនៅក្នុងរបបខ្មែរក្រហម វាក៏បានជះឥទ្ធិពលដល់វប្បធម៌របស់កម្ពុជាបន្ទាប់របបខ្មែរក្រហមដួលរលំ ។ ផ្ទុយទៅវិញខ្មែរក្រហមបានសម្លាប់គ្នាឯងជាច្រើនដូចជា សម្លាប់ឪពុកម្តាយ សាច់ញាតិប្រុសស្រី កូន ប្រពន្ធ និង បងប្អូនបង្កើត ។ អ៊ី ខាថារីយ៉ា សាស្ត្រាចារ្យផ្នែកវិទ្យាសាស្ត្រនយោបាយនៅសាកលវិទ្យាល័យកាលីហ្វ័រញ៉ានៅបឺឃ្លីបាននិយាយថា «ការសម្លាប់គ្នាឯងគឺជាការវង្វេងស្មារតីពីព្រោះជនដៃដល់ «មានរូបរាងដូចជាអ្នកដែរ ។ ជនដៃដល់នោះគឺជាអ្នក» ។

ចាត ភៀសាត់ អ្នកសិល្បៈអាមេរិកដើមកំណើតកម្ពុជាដែលបានវិលត្រឡប់មកកម្ពុជាវិញបានបង្ហាញពីបញ្ហានៃភាពស្ងៀមស្ងាត់និងការខ្វះខាតការជឿទុកចិត្តគ្នានៅក្នុងសង្គមកម្ពុជាតាមរយៈរូបភាពដែលបង្ហាញពីប្រព័ន្ធដ៏ស្មុគស្មាញនៃខ្សែបណ្តាញដែលភ្ជាប់ទំនាក់ទំនងប្រជាជនកម្ពុជាពីមាត់មួយ ទៅមាត់មួយ ។ ចាត ភៀសាត់ បានបកស្រាយថា ខ្សែជីវិតនេះតំណាងឲ្យបំណងរបស់គាត់និងភាពអសមត្ថភាពរបស់គាត់ដែលមិនអាចធ្វើជនរងគ្រោះនិងជនដៃដល់ «មានអារម្មណ៍សុវត្ថិភាពក្នុងការនិយាយពីរឿងរ៉ាវរបស់ខ្លួន» ។ ចាត ភៀសាត់ ដែលជាក្មេងម្នាក់ដែលបានឆ្លងកាត់របបខ្មែរក្រហមបានធ្វើសន្និដ្ឋានថា «ខ្ញុំចង់បង្កើតក្តីសង្ឃឹម ។ ខ្ញុំមិនចង់ឲ្យប្រជាជនកម្ពុជាមានភាពភ័យខ្លាចមិនហ៊ាននិយាយស្តីទេ» ។ ទស្សនៈនៃការរក្សាការស្ងៀមស្ងាត់ទាំងនេះនិងភាពភ័យខ្លាចបានក្លាយទៅជារឿងរ៉ាវមួយពីព្រោះជនដៃដល់និងជនរងគ្រោះ

រស់នៅជិតគ្នានៅក្នុងភូមិ ដូច្នេះប្រជាជនកម្ពុជាច្រើនមានភាពភ័យខ្លាចមិនហ៊ាននិយាយពីខ្មែរក្រហមទៅប្រាប់មនុស្សដែលខ្លួនមិនស្គាល់ និងសូម្បីតែក្នុងគ្រួសាររបស់ខ្លួនផ្ទាល់ ។

គោលនយោបាយបន្តឲ្យរក្សាភាពស្ងៀមស្ងាត់របស់រដ្ឋាភិបាលរួមជាមួយនឹងវប្បធម៌ដែលបានចាក់ឫស "រួចទៅហើយ" នៅក្នុងការរក្សាការស្ងៀមស្ងាត់កាន់តែជំរុញឲ្យ "អ្នកក្រោមបង្គាប់" មិនចង់និយាយ និងមានអារម្មណ៍ថានៅពេលនិយាយហើយនិងមិនមានអ្នកស្តាប់ ។ ស៊ុំ ឫទ្ធី អតីតអ្នកទោសនៅ "គុកធំ" នៅខេត្តសៀមរាបនៃប្រទេសកម្ពុជា គឺជាឧទាហរណ៍ស្រាប់ ។ នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៧៩ ស៊ុំ ឫទ្ធី បានដាក់ពាក្យបណ្តឹងរៀបរាប់ពីបទពិសោធន៍របស់គាត់នៅក្នុងរបបខ្មែរក្រហមទៅ "តុលាការបដិវត្តន៍ប្រជាជន" ឆ្នាំ១៩៧៩ ដែលជាតុលាការបង្កើតឡើងដោយរដ្ឋាភិបាលដែលគាំទ្រដោយវៀតណាមដើម្បីកាត់ទោស ប៉ុល ពត និង អៀង សារី ចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ តុលាការបដិវត្តនប្រជាជន៍នេះបានដំណើរការមួយសប្តាហ៍ដើម្បីកាត់ទោស ប៉ុល ពត និង អៀង សារី ដោយកំបាំងមុខ ។ ស៊ុំ ឫទ្ធី ក៏ទទួលស្គាល់ថា តុលាការមិនបានពិនិត្យលើពាក្យបណ្តឹងរបស់គាត់ទេដែលធ្វើឲ្យគាត់យល់ថា "សូម្បីតែតុលាការឆ្នាំ១៩៧៩ ក៏មិនស្តាប់បណ្តឹងដែលបានផ្ញើទៅដែរ" (យោបល់បន្ថែមពីអ្នកនិពន្ធ) ។ ម្ភៃប្រាំឆ្នាំក្រោយមក ស៊ុំ ឫទ្ធី កម្រនិយាយពីបទពិសោធន៍របស់គាត់ណាស់រហូតដល់ឆ្នាំ ២០០៣នៅពេលដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាឈ្មោះ ដួង សុភារិទ្ធ បានទៅជួបគាត់ដើម្បីប្រមូលទិន្នន័យសម្រាប់សិក្សាទៅលើជំងឺប៉ះទង្គិចផ្លូវចិត្តនៅកម្ពុជា ។ បន្ទាប់ពីនោះមក ទើប ស៊ុំ ឫទ្ធី ចាប់ផ្តើមបង្ហាញនិយាយពីគុកគំនូរនិងសរសេរពីបទពិសោធន៍របស់គាត់ម្តងទៀត ។ ប៉ុន្តែលើកនេះមានគេស្តាប់គាត់ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាដើរតួនាទីក្នុងការជំរុញឲ្យប្រជាជនកម្ពុជាកត់ត្រាប្រវត្តិសាស្ត្រនិងស្វែងយល់ពីអតីតកាលរបស់ខ្លួន ។ ឯកសារដែលមាននៅបណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជាអាចបង្ហាញពីព្រឹត្តិការណ៍ដ៏គួរឲ្យរន្ធត់ដែលបានកើតឡើងនៅប្រទេសកម្ពុជា ដោយអនុញ្ញាតឲ្យប្រជាជនអាចស្វែងរកការផ្សះផ្សា និងនិយាយអំពីអតីតកាលរបស់ខ្លួន ។ ខណៈពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកទ្វារចំហសម្រាប់ឲ្យមានការនិយាយស្តី ឯកសារប្រាំមួយសែនច្បាប់ដែលមានជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក៏អាច "បញ្ជាក់" ថាអំពើប្រល័យពូជសាសន៍ពិតជាបានកើតឡើងមែន ។ នេះគឺជាការងារសំខាន់មួយសម្រាប់សង្គមដែលធ្លាប់ជួបប្រទះការប៉ះទង្គិចផ្លូវចិត្តគឺវាអាចជំរុញឲ្យមានការទទួលស្គាល់និងយល់ដឹងពីរឿងរ៉ាវយ៉ាងច្បាស់លាស់ពីព្រោះជនរងគ្រោះមិនអាចនិយាយពីព្រឹត្តិការណ៍ទាំងស្រុងទេ នេះគឺដោយសារតែការប៉ះទង្គិចផ្លូវចិត្តគឺជាបញ្ហាមួយដែលរារាំងដល់លទ្ធភាពនៃការបកស្រាយបញ្ជាក់ការចងចាំការដឹង និងការគិត ។ ដូចដែលអ្នកជំនាញចិត្តសាស្ត្រ ខូហិន និង ឃីនស្តុន បានអះអាងនៅក្នុងសៀវភៅ "ការប៉ះទង្គិចផ្លូវចិត្ត និងការធ្លាក់ទឹកចិត្តដែលបោះពុម្ពឆ្នាំ១៩៨៥ថា "បញ្ហាបែបនេះបានកើតឡើង ប៉ុន្តែ អ្នកដែលធ្លាប់បានឆ្លងកាត់មិនបានចាំអ្វីទាំងអស់ ។ ការប៉ះទង្គិច ផ្លូវចិត្តបានបណ្តាលឲ្យអ្នកដែលធ្លាប់បានឆ្លងកាត់មិនថាជាទារកក្មេង ឬមនុស្សវ័យជំទង់មិនអាចចាំនូវអ្វីដែលបានកើតឡើងចំពោះខ្លួន ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតរចនាសម្ព័ន្ធនេះសម្រាប់ជំរុញឲ្យមានការចងចាំ ។

លោក ម៉ៃឃើល វ័ត្ត បាននិយាយថា "ប្រវត្តិសាស្ត្រអាចជំរុញឲ្យមានការបន្តដំណើរទៅមុខស្ថិរភាពនិងលទ្ធភាពនៃការដំណើរការសកម្មភាពដ៏មានន័យដែលមិនមែនជាមធ្យោបាយដែលផ្អែកទៅលើឱកាស ។ ដោយមិនមានធម្មជាតិ ឬព្រះមកណែនាំយើងអត្ថន័យប្រវត្តិសាស្ត្រអាចបញ្ជាក់ពីអត្តសញ្ញាណមួយនិងកម្មវិធីសម្រាប់ផ្លាស់ប្តូរ ។ វាគឺជាចំណុចសំខាន់មួយដែលត្រូវចងចាំនៅក្នុងសង្គមដែលធ្លាប់ឆ្លងកាត់បទពិសោធន៍ប៉ះទង្គិចផ្លូវចិត្ត ។ សម្រាប់ប្រទេសកម្ពុជាដែលមិនស្គាល់ច្បាស់ពីកេរដំណែលប្រវត្តិសាស្ត្ររបស់ខ្លួនការកត់ត្រាប្រវត្តិសាស្ត្រគឺជាការចាំបាច់ ។

ផ្នែកបន្ទាប់នៃអត្ថបទនេះនឹងបកស្រាយពីគម្រោងអប់រំស្តីពីអំពើប្រល័យពូជសាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាដោយមិនពិនិត្យទៅលើរចនាសម្ព័ន្ធអំណាចដែលជាប់ពាក់ព័ន្ធ គឺពិនិត្យតែទៅលើមធ្យោបាយដែលថាការបង្កើតប្រវត្តិសាស្ត្រអាចជំរុញឲ្យមានការប្រាប់ពីរឿងរ៉ាវដែលបានកើតឡើង ។

**ការអប់រំពីប្រល័យពូជសាសន៍ ៈ ករណីសិក្សាមួយ**

នៅខែមេសា ឆ្នាំ២០០៩ មជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាជាមួយនឹងក្រសួងអប់រំ ។ អនុស្សរណៈនោះបានផ្តល់ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា នូវសិទ្ធិបណ្តុះបណ្តាលគ្រូបង្រៀនប្រវត្តិសាស្ត្រ សីលធម៌ពលរដ្ឋ និងអក្សរសាស្ត្រនិងសាស្ត្រាចារ្យនៅមហាវិទ្យាល័យនានាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ បង្កើនជំនាញបង្រៀននិងចំណេះដឹងមូលដ្ឋានទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ធានានូវប្រសិទ្ធភាពនៃដំណើរការបណ្តុះបណ្តាល និងសំខាន់ជាងគេនោះគឺដាក់បញ្ចូលសៀវភៅមេរៀនដែលនិពន្ធដោយ ឌី ខាំបូលី និងសៀវភៅណែនាំគ្រូបង្រៀនចូលក្នុងកម្មវិធីសិក្សានៅកម្ពុជាពីថ្នាក់ទី៩ដល់ទី១២ និងកម្មវិធីសិក្សានៅមហាវិទ្យាល័យ ។ មកត្រឹមឆ្នាំ២០១៣ មហាវិទ្យាល័យនិងសាលារៀននៅកម្ពុជាទាំងអស់នឹងបង្រៀនពីប្រវត្តិសាស្ត្រខ្មែរក្រហមដោយប្រើប្រាស់សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដែលនិពន្ធដោយ ឌី ខាំបូលី ដែលជាបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ក៏ដូចជាបណ្ណសារដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរ សៀវភៅមេរៀននេះនឹងមានឥទ្ធិពលក្នុងការសម្រួចការចងចាំជាបុគ្គលនិងជារួមទាក់ទងនឹងសម័យនោះ ហើយវាក៏កំពុងតែដំណើរការដូច្នោះដែរ ។ នៅប្រទេសកម្ពុជាដែលប្រជាជនមិនដឹងឬមិនជឿប្រវត្តិសាស្ត្រនេះ វានឹងផ្តល់ផលប្រយោជន៍សំខាន់មួយចំនួនដល់គម្រោងអប់រំទោះបីជាមានរចនាសម្ព័ន្ធអំណាចការប្រើប្រាស់អំណាចគ្របដណ្តប់លើការចងចាំរបស់អ្នកដទៃនិងឥទ្ធិពលនៃប្រវត្តិសាស្ត្របែបនេះដែលមាននៅក្នុងគម្រោងក៏ដោយ ។

ខណៈពេលមិនមានការចងក្រងភ័ស្តុតាង ឬបាយការណ៍សន្និដ្ឋានបញ្ចប់វា ទំនងជាថាការអប់រំនៅកម្ពុជានឹងទទួលស្គាល់ការប៉ះទង្គិចផ្លូវចិត្តរបស់អ្នកនៅរស់ដោយស្របច្បាប់ ។ ថ្មីៗនេះនៅក្នុងសៀវភៅមេរៀន មានតែអត្ថបទតែពីរបន្ទាត់ដែលនិយាយពីខ្មែរក្រហម ។ ជាលទ្ធផល សិស្សកម្ពុជាបច្ចុប្បន្នជាច្រើនជឿថាការអះអាងប្រឆាំងនឹងខ្មែរក្រហមគឺជាការនិយាយបន្ថែមឲ្យធ្ងន់ធ្ងរឬមិនពិត ។

អ្នកគ្រូ សំ បូរ័ត្ន គ្រូបង្រៀនប្រវត្តិសាស្ត្រនៅខេត្តបន្ទាយមានជ័យបាននិយាយនៅឆ្នាំ២០១០ថា «អតីតសិស្សរបស់ខ្ញុំដែលកើតនៅឆ្នាំ១៩៧៩មិនជឿថា មានរបបខ្មែរក្រហមទេ» ។ ក្មេងៗមិនត្រឹមតែមានការនិយាយបែបនេះនៅក្នុងសាលារៀនទេ ថែមទាំងមានការបដិសេធមិនជឿលើការប៉ះទង្គិចផ្លូវចិត្តរបស់ឪពុកម្តាយរបស់ខ្លួនដែលបណ្តាលឲ្យមានបញ្ហានៅក្នុងប្រទេស


សិស្សានុសិស្សទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង

កម្ពុជាបច្ចុប្បន្នទៀត ។ យោងទៅតាមបណ្ឌិត ឈឹម សុធារ៉ា បានឲ្យដឹងថា លទ្ធផលនៃការមិនជឿបានធ្វើឲ្យក្មេងៗរឹតតែមិនជឿទៅលើបទពិសោធន៍ដែលឪពុកម្តាយរបស់ខ្លួនធ្លាប់ឆ្លងកាត់ដោយបន្តអនុវត្តបែបនេះនៅក្នុងវិធីផ្សេង ។

ប្រវត្តិសាស្ត្រដែលបានចងក្រងមិនត្រឹមតែអាចឲ្យមានការទទួលស្គាល់អតីតកាលរបស់អ្នកនៅរស់ទេ ថែមទាំងផ្តល់ឱកាសឲ្យអ្នកនៅរស់អាចនិយាយពីរឿងរ៉ាវរបស់ខ្លួន ។ នៅក្នុងអត្ថបទការចងចាំរួម ម៉ូរីស ហលបាវ៉ាច បានសង្កត់ធ្ងន់ទៅលើសារសំខាន់នៃការចងចាំជារួមដើម្បីរក្សាការចងចាំរបស់បុគ្គលជានិរន្តរភាព ។ លោកបានអះអាងថា «ដើម្បីបកស្រាយឲ្យច្បាស់ និងគ្រប់ដណ្តប់គ្រប់ចន្លោះនៅក្នុងការចងចាំ ការចងចាំរបស់បុគ្គល ត្រូវពឹងផ្អែកប្រួមបញ្ចូលជាមួយការចងចាំជារួម ។ គម្រោងអប់រំស្តីពីអំពើប្រល័យពូជសាសន៍បានជំរុញឲ្យមាន «ការចងចាំជារួម» តាមរយៈសៀវភៅមេរៀន ។ ជាឧទាហរណ៍ នៅក្នុងដំណើរការបណ្តុះបណ្តាលគ្រូបង្រៀននៅខែវិច្ឆិកានិងខែធ្នូ ឆ្នាំ២០០៩ គ្រូបង្រៀនបានចែករំលែកនូវអតីតកាលរបស់ខ្លួនទៅឲ្យគ្រូបង្រៀនផ្សេងទៀតនៅពេលឡើងបង្រៀន ដើម្បីបន្ថែមទៅលើកិច្ចតែងការបង្រៀន ។ ជាងនេះទៅទៀត គម្រោងអប់រំស្តីពីអំពើប្រល័យពូជសាសន៍បានអនុញ្ញាតឲ្យអ្នកនៅរស់អាចនិយាយពីរឿងរបស់ខ្លួននៅទីកន្លែងដែលមានសុវត្ថិភាព និងអាចប្រាប់គ្នាទៅវិញទៅមកបាន ។ ការធ្វើបែបនេះពិតជាមានសារសំខាន់ណាស់ប្រសិនបើយើងគិតទៅដល់ការរក្សាការស្ងៀមស្ងាត់ និងភាពភ័យខ្លាចដែលមាននៅក្នុងសង្គមកម្ពុជា ។ ជាទូទៅ អ្នកនៅរស់តែងតែនិយាយពីរឿងខ្លួនឯងទៅអ្នកដទៃនៅក្នុងក្រុមដោយស្ម័គ្រចិត្ត ។ ដូរី ឡូប បានសរសេរថា «ជនរងគ្រោះនៃការគាបសង្កត់ ទាសភាព និងទារុណកម្មមិនមែនគ្រាន់តែស្វែងរកការទទួលស្គាល់ដោយមើលឃើញទេ អ្នកទាំងនោះក៏ស្វែងរកសាក្សីដែលធ្លាប់ឃើញរឿងរ៉ាវដ៏ព្រៃផ្សៃនោះដែរ» ។ គម្រោងនេះបានឲ្យអ្នកនៅរស់មានការចងចាំជារួមដែលជាធាតុផ្សំដ៏សំខាន់សម្រាប់ព្យាបាលបុគ្គលឲ្យជាសះស្បើយនិងផ្សះផ្សា ។

នៅពេលជាមួយគ្នា គម្រោងអប់រំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមិនត្រឹមតែផ្តល់វេទិកាមួយសម្រាប់ឲ្យអ្នកនៅរស់និយាយគ្នាទេ តែថែមទាំងឲ្យអ្នកទាំងនោះយល់ដឹងពីអតីតកាលរបស់ខ្លួន ។ អ្នកនៅរស់ពីរបបខ្មែរក្រហមជាច្រើនមិនចាំនូវបទពិសោធន៍របស់ខ្លួនទាំងស្រុងទេ ហើយដឹងអំពីខ្មែរក្រហមតែតាមរយៈបទពិសោធន៍ផ្ទាល់ខ្លួននិងសាច់ញាតិប៉ុណ្ណោះ ។ ការបង្ហាញពីបទពិសោធន៍របស់គ្រូបង្រៀនបានបង្ហាញពីសារសំខាន់នៃវគ្គបណ្តុះបណ្តាលនេះ ។ អ្នកគ្រូម្នាក់បាននិយាយថា នៅក្នុងរបបខ្មែរក្រហម គាត់មានអាយុប្រហែល២០ឆ្នាំ ប៉ុន្តែរហូតមកដល់សព្វថ្ងៃគាត់មិនដែលដឹងពីបទពិសោធន៍របស់អ្នកដទៃនៅក្នុងតំបន់ផ្សេងទេ ។ បន្ទាប់ពីអានសៀវភៅមេរៀន និងទទួលការបណ្តុះបណ្តាល គាត់យល់ថាបទពិសោធន៍នៃភាពអត់ឃ្លាន និងការសម្លាប់សមាជិកគ្រួសារដែលគាត់ធ្លាប់ជួបប្រទះក៏មានកើតឡើងជារៀងរាល់ថ្ងៃនៅគ្រប់កន្លែងដែរ ។ នៅក្នុងការសន្ទនាជាមួយខ្ញុំ គាត់បាននិយាយថាការបណ្តុះបណ្តាលនេះមានសារសំខាន់ដែលធ្វើឲ្យគាត់ពិចារណាទៅដល់ប្រវត្តិរបស់គាត់ និងធ្វើឲ្យគាត់ដឹងថាគាត់មិនទទួលការឈឺចាប់តែម្នាក់ឯងទេ ។ គាត់បាននិយាយថា «ផ្នែកមួយនៅក្នុងសៀវភៅមាននិយាយពីទារុណកម្មនិងភាពអត់ឃ្លានដែលខ្ញុំធ្លាប់ជួបប្រទះ ។ ការចាប់ខ្លួនឪពុក និងបងប្អូនស្រីរបស់ខ្ញុំទៅសម្លាប់ក៏មាននិយាយដែរ ។ វាគឺជាផ្នែកមួយនៃបទពិសោធន៍របស់ខ្ញុំ ។ វាគឺជាការបង្អត់អាហារដែលពាក់ព័ន្ធនឹងកូនពីរនាក់របស់ខ្ញុំ ។ ខ្ញុំអាចភ្ជាប់វាមករឿងរ៉ាវរបស់ខ្ញុំ» ។ ខ្ញុំយល់ថាគ្រូបង្រៀនថ្នាក់ខេត្តជាច្រើនក៏មានបទពិសោធន៍ស្រដៀងគ្នាទៅនឹងអ្នកគ្រូម្នាក់នៅខេត្តបាត់ដំបងនេះដែរ ។

ចំណុចចុងក្រោយលើកឡើងពីសារសំខាន់នៃប្រវត្តិសាស្ត្រនៅក្នុងសង្គមដែលធ្លាប់ទទួលរងនូវការប៉ះទង្គិចផ្លូវចិត្ត ។ នៅក្នុង «ប្រវត្តិពង្សាវតាររបស់ នៀតឆា *(Netzsche, la genealogie, l'historie)* ហ្វូកូល *(Foucault)* ជឿថា ប្រវត្តិសាស្ត្រដែលមាន «ប្រសិទ្ធភាព» ត្រូវតែជាប្រវត្តិសាស្ត្រដែលមិនមានភាពជាក់លាក់ មិនមានស្ថិរភាព និង «មិនមានទំនាក់ទំនងគ្នានៅក្នុងជីវិត» ។ យោងទៅតាម ហ្វូកូល «ប្រវត្តិសាស្ត្រដ៏មានប្រសិទ្ធភាពនេះ» គឺជាប្រវត្តិដែល «មិនជាប់ពាក់ព័ន្ធនឹងអត្តសញ្ញាណរបស់យើង» ដូច្នេះយើង «ត្រូវកំណត់ពីដើមកំណើតរបស់យើងដើម្បីស្វែងយល់ពីខ្លួនយើង» ។មានហេតុផលមួយចំនួនដែលធ្វើឲ្យ ហ្វូកូល ជឿថា

ចំណុចនេះមានសារសំខាន់ ។ ហេតុផលមួយក្នុងចំណោមនោះគឺ «ដើម្បីលុបបំបាត់ប្រធានបទដែលមានគេដឹងស្រាប់ហើយលាតត្រដាងនូវរឿងរ៉ាវដែលបានលាក់ទុក» ។ ប៉ុន្តែ នៅក្នុង «វប្បធម៌នៃការប៉ះទង្គិចផ្លូវចិត្ត» ឬនៅកន្លែងដែលមានការប៉ះទង្គិចផ្លូវចិត្ត ដូចជាប្រទេសកម្ពុជា ប្រភេទនៃប្រវត្តិសាស្ត្រដែល ហ្វោខុល បាននិយាយប្រហែលជា «មិនមានប្រសិទ្ធភាព» និងអាចបង្កគ្រោះថ្នាក់ដល់អ្នកនៅរស់ទៀតផង ។ ដោយការប៉ះទង្គិចផ្លូវចិត្តគឺជាព្រឹត្តិការណ៍ «ដែលមិនមានគេដឹងឮ» ដូច្នេះវាគឺជារឿងរ៉ាវមួយដែលតម្រូវឲ្យមានការបញ្ជាក់ម្តងទៀតឬការកត់ត្រា «ភាពជាក់ស្តែងនៃប្រវត្តិសាស្ត្រ» ឡើងវិញ ។

**សេចក្តីសន្និដ្ឋាន**

ក្នុងសតវត្សរ៍ទី៩ ព្រះបាទយសោវរ្ម័ន បានកសាងប្រាសាទព្រះវិហារដែលបច្ចុប្បន្នមានទីតាំងស្ថិតនៅភាគខាងឧត្តរនៃប្រទេសកម្ពុជាដែលជាប់ព្រំដែនប្រទេសថៃ ។ ដោយមានទីតាំងស្ថិតនៅកំពូលភ្នំដងរែកនិងមានកម្ពស់១៨០០ហ្វីត (៥៥០ម៉ែត្រ) ប្រាសាទព្រះវិហារបច្ចុប្បន្នធ្លាប់មានទីតាំងស្ថិតនៅចំកណ្តាលនៃព្រះរាជាណាចក្រខ្មែរដើម្បីវិព្ភកដល់ព្រះនៃព្រហ្មញ្ញសាសនា ។ ប៉ុន្តែ យោងទៅតាមសៀវភៅដ៏ពិសិដ្ឋនៅលផ្នែកដែលបានរៀបរាប់ខាងលើ កងទ័ពបរទេសបានលួចប្រាសាទព្រះវិហាររបស់ខ្មែរបន្ទាប់ពីអធិរាជអង្គរបានបញ្ចប់គឺនៅពេលដែលកងទ័ពសៀមបានឈ្លានពាននិងលួចប្រាសាទខ្មែរ ។

ខណៈពេលដែលកម្ពុជាមិនអាចកែប្រែ «រឿងព្រេង» និងយកសៀវភៅដែលស្រោបមាសនិងផ្ទុកនូវចំណេះដឹងទាំងអស់អំពីពិភពលោកត្រឡប់មកវិញ ប្រជាជនកម្ពុជាក៏បានទាមទារប្រាសាទរបស់យើងមកវិញដែរ ។ ប៉ុន្តែការធ្វើបែបនេះមិនមែនជាការងាយស្រួលទេ ។ នៅដើមទសវត្សរ៍៦០ បន្ទាប់ពីទទួលបានឯករាជ្យពីបារាំង ប្រជាជនកម្ពុជាបានព្យាយាមទាមទារប្រាសាទពីថៃវិញ ។ ដំណើរការទាមទារនោះត្រូវបានបញ្ចប់បន្ទាប់ពីមានជម្លោះដ៏ស្មុគស្មាញតាមផ្លូវច្បាប់នៅទីក្រុងឡាអេ គឺប្រាសាទព្រះវិហារត្រូវប្រគល់ឲ្យប្រជាជនខ្មែរវិញ ។ នៅឆ្នាំ១៩៧៩ បន្ទាប់ពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមបានដួលរលំ អ្នកភៀសខ្លួនកម្ពុជារាប់ពាន់នាក់បានរត់ទៅប្រទេសថៃ ។ ប្អូនខែក្រោយមក ប្រទេសថៃដែលលែងចង់ទទួលប្រជាជន «គ្មានសីលធម៌» និង «ព្រៃផ្សៃ» បានប្រាប់សហរដ្ឋអាមេរិក បារាំង និងអូស្ត្រាលីឲ្យមកជ្រើសរើសយក «អ្នកដែលខ្លួនចង់បាន» ។ បន្ទាប់ពីប្រជាជនចំនួនប្រមាណ១២០០នាក់ត្រូវបានជ្រើសរើសអ្នកភៀសខ្លួនដែលនៅសល់ត្រូវបានដឹកបញ្ជូនតាមឡានក្រុងត្រឡប់ទៅព្រះវិហារវិញ ។ នៅក្នុងការទាញយកប្រយោជន៍ទាហានថៃបានបង្ខំឲ្យប្រជាជនប្រមាណ៤២០០០នាក់ចុះពីចំណោទភ្នំដែលមានកម្ពស់ ១៨០០ហ្វីត (៥៥០ម៉ែត្រ) ត្រឡប់ទៅ «ឋាននរក» ដែលខ្លួនបានរស់នៅអស់រយៈពេលជិតបួនឆ្នាំនិងទើបតែរួចរស់ជីវិត ។ បន្ទាប់ពីនោះមក ប្រទេសថៃបានសាងសង់ផ្លូវធ្វើដំណើរទៅប្រាសាទព្រះវិហារដោយអះអាងថាវាគឺជាប្រាសាទរបស់ខ្លួន ។

នៅទសវត្សរ៍ឆ្នាំ២០០០រដ្ឋាភិបាលកម្ពុជាចាប់ផ្តើមធ្វើផ្លូវឡើងទៅភ្នំព្រះវិហារ ហើយនៅឆ្នាំ២០០៨ អង្គការយូណេស្កូបានដាក់ប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ។ ប្រជាជនកម្ពុជា ក៏ចាប់ផ្តើមលក់វត្ថុអនុស្សាវរីយ៍អំពីប្រាសាទព្រះវិហារនៅតាមផ្លូវ ។ មោទកភាពជាតិសន្ធុះកាន់តែខ្លាំងមាននៅពេលដែលកម្ពុជាបានព្យាយាមទាមទារអ្វីដែលខ្លួនបានបាត់បង់ ។ នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១០ គ្រូជាង២០០នាក់ដែលទទួលបានការបណ្តុះបណ្តាល «ដំបូង» នៅឆ្នាំ២០០៩ បានជួបប្រជុំគ្នានៅភ្នំព្រះវិហារដែលជាផ្នែកមួយនៃកិច្ចសហការរបស់ក្រសួងអប់រំនិងមជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានចំណងជើងថា «ការបង្រៀនប្រវត្តិសាស្ត្រខ្មែរ» ។

ជាការពិតណាស់ដែលថាអំណាចនិងនយោបាយសុទ្ធតែមានជាប់ពាក់ព័ន្ធនឹងបណ្ណសារដ្ឋាននោះ ប៉ុន្តែកិច្ចពិភាក្សានោះអាចពង្រីកហួសពីការពិភាក្សាទៅលើការបង្រៀនពីព្រោះប្រវត្តិសាស្ត្រដែលកើតចេញពីអំណាចក៏អាចជំរុញឲ្យមនុស្សនិយាយបញ្ជាក់និងប្រឈមមុខនឹងអតីតកាល ។ ជាក់ស្តែងនៅពេលគ្រូ២០០នាក់ធ្វើដំណើរនៅលើផ្លូវដែលទើបតែសាងសង់តម្រង់ទៅទស្សនាប្រាសាទដែលប្រជាជនខ្មែរបានទាមទារមកវិញ អ្នកទាំងនោះនឹងបោះទង់ជាតិចំណាំនូវប្រវត្តិសាស្ត្ររបស់ខ្លួន និងចាប់ផ្តើមដឹកនាំប្រទេសតាមរយៈការកត់ត្រានិងការយល់ដឹងពីអតីតកាល ។ **សារ៉ា ចូនឌីកឃិន**

# ដំណើរស្វែងយល់ពីអំពើប្រល័យពូជសាសន៍

ជាលទ្ធផលនៃការស្រាវជ្រាវ និងកិច្ចការងាររបស់ខ្ញុំទាក់ទិននឹងអំពើប្រល័យពូជសាសន៍ ខ្ញុំត្រូវបានក្រុមការងារនៅទីក្រុងញូវខាសលស្នើឲ្យតាក់តែងមេរៀនសម្រាប់បង្ហាញនៅក្នុងកម្មវិធីឆ្នាំ២០០៩ ។ នៅពេលនោះ ខ្ញុំបានប្រើប្រាស់ការស្រាវជ្រាវនិងការសម្ភែងនៅកម្ពុជាជាមូលដ្ឋានដើម្បីឆ្លុះបញ្ចាំងពីអ្នកនៅរស់និងព្រលឹងរបស់មនុស្សទាំងអស់គ្នា ។ នៅឆ្នាំបន្ទាប់ ខ្ញុំបានក្លាយទៅជានាយកគ្រប់គ្រងកម្មវិធីរំឭកពីហូឡូខសត៍ដែលប្រព្រឹត្តទៅនៅទន្លេ ថាន នៅទីក្រុងញូវខាសល ។

យើងបានរៀបចំឲ្យលោកស្រី ហ្សុីនកា ហេុនឡូវ៉ា ធ្វើជាវាគ្មិនសំខាន់នៅក្នុងព្រឹត្តិការណ៍រំឭកពីហូឡូខសត៍ ។ កាសែតណសឹមព្រា បានយល់ព្រមចុះផ្សាយពីជីវប្រវត្តិរបស់លោកស្រីហ្សុីនកា ជាភាសាអង់គ្លេសដែលមានចំណងជើងថា «ឌី ធីន វីង» ហើយបច្ចុប្បន្នយើងអាចរកទិញបានតាមរយៈគេហទំព័រអាម៉ាហ្សូន ។ លោកស្រី ហ្សុីនកា គឺជាអ្នកនៅរស់រានមានជីវិតម្នាក់ក្នុងចំណោមអ្នកនៅរស់ដ៏តិចតួចដែលបានរួចជីវិតពី «ដំណើរការសម្លាប់ផុតពូជ» ។ លោកស្រី ហ្សុីនកា បានឲ្យផ្តល់សិទ្ធិឲ្យខ្ញុំប្រើប្រាស់សក្ខីកម្មរបស់គាត់ជាប្រភពធនធានសម្រាប់ផលិតភាពយន្តទីបីរបស់ខ្ញុំ ។ ចំណុចសំខាន់នៅក្នុងសៀវភៅនោះបានផ្តល់ឱកាសឲ្យខ្ញុំស្វែងយល់ពីសំណួរដែលបានលើកឡើងនៅក្នុងការបង្កើតរឿង «ជីជីមណាស» នៅប្រទេសកម្ពុជា ។ ជាលទ្ធផលនៃឱកាសទាំងអស់នេះ ខ្ញុំអាចចូលរួមក្នុងមូលនិធិអប់រំ និងរំឭកនូវការចងចាំហូឡូខសត៍ស្តីពីមេរៀនរបស់កម្មវិធី អូសឈ្វីច ។

នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០ ខ្ញុំបានទៅដល់ប្រទេសប៉ូឡូញ ។ មគ្គុទេសក៍និងគ្រូរបស់ខ្ញុំគឺលោក ថម ដេកសុន ដែលអនុញ្ញាតឲ្យខ្ញុំធ្វើបទសម្ភាសជាមួយគាត់សម្រាប់សរសេរអត្ថបទនេះ ។ សម្រាប់ខ្ញុំ ការធ្វើទស្សនកិច្ចទៅជំរំប្រមូលផ្តុំអូសឈ្វីច១ និង អូសឈ្វីច ប៊ីខេណូ គឺជារឿងចម្លែកមួយ ។ ខ្ញុំស្ទើរតែ «វង្វេង» នៅក្នុងបន្ទប់មួយដែលមានប្រអប់តាំងពិព័រណ៍ធ្វើពីកញ្ចក់វែងមួយដែលមានសក់របស់មនុស្សស្លាប់ ។ ខ្ញុំបានដើរយ៉ាងលឿនទៅកាន់បន្ទប់ផ្សេងដែលពោរពេញទៅដោយឆ្នាំង ខ្ទះ ស្បែកជើង និងតុក្កតា ។ នៅពេលដែលខ្ញុំក្រឡេកមើលទៅជុំវិញម្តងហើយម្តងទៀត ខ្ញុំឃើញរបស់របររាប់រយរាប់ពាន់របស់អ្នកស្លាប់ ។ ខ្ញុំបានដើរចេញពីក្រុមនិងមគ្គុទេសក៍របស់ខ្ញុំដើម្បីចាកចេញពីបន្ទប់តាំងពិព័រណ៍ដែលមានវ៉ាលីរបស់អ្នកដែលត្រូវបានបញ្ជូនទៅ អូសឈ្វីច ។ ខ្ញុំដឹងថារបស់របររបស់លោកស្រី ហ្សុីនកា ក៏នៅក្នុងការតាំងពិព័រណ៍នោះដែរ ប៉ុន្តែខ្ញុំមិនគិតថាខ្ញុំអាចរកឃើញរបស់របរនោះទេ ។ ប៉ុន្តែនៅពេលដែលខ្ញុំចូលទៅក្នុងបន្ទប់ប្រអប់ដំបូងគេនៅកាច់ជ្រុងកញ្ចក់គឺជាគម្របវ៉ាលីរបស់លោកស្រីហ្សុីនកា ដែលមានឈ្មោះ ហ្សុីនកា និងលេខសរសេរនៅពីលើនោះ ។ ខ្ញុំនិយាយមិនចេញគឺបានត្រឹមតែចង្អុលទៅវ៉ាលីនោះ បន្ទាប់មកអ្នកទស្សនាមកពីកូរ៉េខាងត្បូងជាច្រើនបានមកព័ទ្ធខ្ញុំជិត មួយសន្ទុះក្រោយមក អ្នកទាំងនោះក៏សម្លឹងមើលទៅឥវ៉ាន់របស់លោកស្រីហ្សុីនកា ជាមួយខ្ញុំដោយចង្អុលទៅឥវ៉ាន់ទាំងអស់នោះ ។ នៅថ្ងៃបន្ទាប់ ខ្ញុំបានប្រាប់លោកស្រី ហ្សុីនកា តាមទូរស័ព្ទពីរឿងនេះ ។ លោកស្រី ក៏និយាយថា ខ្ញុំគួរតែស្រែកចេញមក ក្រៅឲ្យខ្លាំងថា «ខ្ញុំដឹងថាស្ត្រីម្នាក់នោះនៅរស់នៅទីក្រុងឡុងដ៏ប្រទេសអង់គ្លេស ។ លោកស្រីនៅរស់រានមានជីវិត» ។

ដំណើរទស្សនកិច្ចនៅ អូសឈ្វីច ក៏ដូចជាការទស្សនានៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងនិងវាលពិឃាដជើងឯកនៅប្រទេសកម្ពុជាដែរ ។ ដំណើរទស្សនកិច្ចទាំងពីរកន្លែងនេះបានផ្តល់ចំណេះដឹងដ៏មានសារសំខាន់ក្នុងការយល់ដឹងពីអំពើប្រល័យពូជសាសន៍ ។ ខ្ញុំសំដៅទៅលើវត្តមាននៃអ្នកស្លាប់ ។ កូនចៅ ឪពុកម្តាយ គ្រួសារ មិត្តភក្តិ ត្រូវបានធ្វើបាប ធ្វើឲ្យបាត់ខ្លួន និងបាញ់សម្លាប់ ។ ដើម្បីសម្តែងការគោរពដល់អ្នកស្លាប់ នៅថ្ងៃបញ្ចប់នៅ សារមន្ទីរអូសឈ្វីច ប៊ីខេណូ យើងបាននៅស្ងៀមស្ងាត់មួយសន្ទុះដើម្បីបង្ហាញពីការរំលែកទុក្ខរបស់យើង ។ ភាពស្ងៀមស្ងាត់បានធ្វើឲ្យខ្ញុំយល់ពីភាពអវត្តមាននៃសំឡេងដែលបានបាត់បង់ ។ ក្រោយមកភាពស្ងៀមស្ងាត់ដ៏ពិសេសនោះបានធ្វើឲ្យសំឡេងដែលបាត់បង់នោះ

កាន់តែពុះឡើង ។ បន្តទៅនេះគឺជាបទសម្ភាសរបស់ខ្ញុំជាមួយលោក ថម ដេកសុន ដែលជាមគ្គុទេសក៍នៅជំរំប្រមូលផ្តុំ អូសឈ្វីច ។

***សូមលោករៀបរាប់ពីការងារនិងតួនាទីរបស់លោក ។ តើអ្វីដែលជំរុញឲ្យលោកចូលរួមក្នុងការងារសម្រាប់មូលនិធិអប់រំពីហូឡូខសត៍?***

បច្ចុប្បន្ន ខ្ញុំគឺជាមន្ត្រីអប់រំនៅមូលនិធិអប់រំពីហូឡូខសត៍ ។ ខ្ញុំបានបម្រើការងារនេះអស់រយៈពេល១៥ខែមកហើយ ។ ពីមុនខ្ញុំគឺជាមន្ត្រីផ្សព្វផ្សាយតាមមូលដ្ឋានអំពីដំណើរទស្សនកិច្ចរបស់សិស្ស-និស្សិតតាមមហាវិទ្យាល័យដើម្បីជួបជាមួយនឹងអ្នកនៅរស់ពីហូឡូខសត៍ ។

តួនាទីរបស់ខ្ញុំបច្ចុប្បន្នគឺជួយរៀបចំដំណើរទស្សនកិច្ចនិងតាមដានការគ្រប់គ្រងលើមេរៀនរបស់គម្រោង អូសឈ្វីច នៃមូលនិធិអប់រំពីហូឡូខសត៍ និងអភិវឌ្ឍន៍ផ្នែកនីមួយៗនៃគម្រោងនេះ ។ ខ្ញុំរៀបចំនិងសម្របសម្រួលសិក្ខាសាលាក្នុងតំបន់ដែលមានអ្នកចូលរួមប្រមាណជា២០០នាក់និងរក្សាទំនាក់ទំនងជាមួយអ្នកដែលធ្លាប់បានទទួលការបណ្តុះបណ្តាលពីមុនរួចហើយប្រមាណជា១០០នាក់ ។ ខ្ញុំគឺជាអ្នករៀបចំឯកសារជាក្រដាសនិងចុះផ្សាយតាមប្រព័ន្ធអ៊ីនធឺណែត ។

មេរៀនរបស់គម្រោង អូសឈ្វីច គឺជាមេរៀនពិសេសដែលមានបួនផ្នែក ហើយផ្តោតទៅលើទស្សនកិច្ចមួយថ្ងៃនៅអូសឈ្វីច បឺខេណូ សម្រាប់អ្នកតំណាងសិស្ស១៦នាក់ពីគ្រប់សាលា និងមហាវិទ្យាល័យ ។ គម្រោងនេះគឺផ្អែកទៅលើទ្រឹស្តីដែលថាការឃើញទីតាំងប្រល័យពូជសាសន៍គឺខុសពីការអាននៅក្នុងសៀវភៅ ។ មកដល់បច្ចុប្បន្ន មានអ្នកទស្សនាប្រមាណជា១២០០០នាក់បានមកដល់ អូសឈ្វីច បឺខេណូ ។

គម្រោងនីមួយៗរួមមានសិក្ខាសាលាដែលផ្តល់ឱកាសឲ្យអ្នកចូលរួមអាចស្តាប់សក្ខីកម្មដំបូងរបស់អ្នកនៅរស់ពី អូសឈ្វីច បឺខេណូ នឹងពិភាក្សាពីបញ្ហាជុំវិញការធ្វើទស្សនកិច្ចទៅអតីតជំរំកាប់សម្លាប់ ។ មុនពេលដំណើរទស្សនកិច្ចទៅ អូសឈ្វីច១ និងអូសឈ្វីច២ បឺខេណូ បញ្ចប់នៅពិធីរំឭកនៅ បឺខេណូ ទស្សនកិច្ចចំនួនមួយថ្ងៃត្រូវចាប់ផ្តើមពីការទស្សនានៅទីតាំងរស់នៅរបស់ជនជាតិជ្វីហ្វនៅមុនពេលមានសង្គ្រាមនៅទីប្រជុំជនអូសវីសស៊ីមនៃប្រទេសប៉ូឡូញ ដែលក្រោយមកត្រូវបានប្តូរឈ្មោះទៅជាអូសឈ្វីច ដោយរបបណាហ្ស៊ី ។ បន្ទាប់ពី៩-១០ថ្ងៃនៃដំណើរទស្សនកិច្ច យើងបានរៀបចំសិក្ខាសាលាមួយដែលឲ្យអ្នកចូលរួមអាចផ្តល់មតិនៃការយល់ឃើញរបស់អ្នកចូលរួមនិងពិភាក្សាទៅលើដំណើរទស្សនកិច្ច ព្រមទាំងចាប់ផ្តើមរៀបចំ «ជំហានទីពីរ» នៃគម្រោង ។ «ជំហានទីពីរ» គឺអ្នកចូលរួមនាំយកមេរៀនដែលខ្លួនបានរៀនទៅសាលារៀនទៅប្រាប់អ្នកនៅសហគមន៍របស់ខ្លួនវិញ ។

បទពិសោធន៍រយៈពេល១៦ឆ្នាំ ជាគ្រូបង្រៀនផ្នែកមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម មុនពេលធ្វើការនៅកន្លែងថ្មីនេះ បានជំរុញឲ្យខ្ញុំអាចបង្កើតនិងផ្តល់នូវគំនិតអប់រំឲ្យចេះអត់ឱនគ្នា ដោយផ្តល់នូវការយល់ដឹងពីភាពស្មុគស្មាញនៃឥរិយាបថនយោបាយ ចិត្តវិទ្យា និងសង្គមមនុស្ស ។ មកដល់ពេលនេះ ខ្ញុំបានធ្វើជាសមាជិកអង្គការលើកលែងទោសអន្តរជាតិអស់រយៈពេល៣០ឆ្នាំមកហើយ ។

***សូមលោកមេត្តាបកស្រាយពន្យល់ថាតើប្រទេសកម្ពុជា និងអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសនោះបានជះឥទ្ធិពល (ទោះបីជាលោកមិនដែលធ្វើទស្សនកិច្ចទៅកន្លែងនោះក៏ដោយ) ដល់ជីវិតឬរឿងរ៉ាវផ្ទាល់ខ្លួនរបស់អ្នកដែរឬទេ?***

ខ្ញុំមិនដែលទៅប្រទេសកម្ពុជាទេ ប៉ុន្តែនៅពេលដែលខ្ញុំនៅក្មេង អំពើប្រល័យពូជសាសន៍នៅទីនោះបានកើតឡើង ។ ខ្ញុំចាំបានថានៅពេលនោះខ្ញុំក៏មានការខឹងសម្បាចំពោះអ្វីដែលបានកើតឡើង ហើយក៏ខឹងនឹងសកម្មភាពរបស់ពិភពលោកដែរ ។ ជាការពិតណាស់ មូលនិធិនេះគឺផ្តោតទៅលើអំពើហូឡូខសត៍ ប៉ុន្តែរឿងរ៉ាវនៃអំពើប្រល័យពូជសាសន៍ដែលកើតក្រោយអំពើហូឡូខសត៍ក៏ជាការជំរុញដល់ការងារយើងដែរ ។ មេរៀនអប់រំក៏តែងតែមានការនិយាយពីកម្ពុជាក៏ដូចជាអំពើប្រល័យពូជសាសន៍នៅរ៉្វាន់ដា កូសូវ៉ូ និងដាហ្វួរដែរ ។

***សូមអ្នកជួយពិភាក្សាពីសារសំខាន់និងទំនាក់ទំនងនៃពាក្យ «ការពិត» ក្នុងនាមអ្នកដែលជាបុគ្គលម្នាក់ក៏ដូចជាអ្នកអប់រំម្នាក់នៅមូលនិធិអប់រំនិងរំឭកនូវការចងចាំអំពើហូឡូខសត៍ស្តីពីមេរៀនរបស់កម្មវិធីអូសឈ្វីច?***

ការពិតគឺជាទស្សនៈដ៏ស្មុគស្មាញនិងប្រែប្រួលរហូត ។

មានការពិតនិយាយអំពីហូឡូខសត៍ ប៉ុន្តែនៅក្នុងនោះក៏មាន «ការពិត» ជាច្រើនផ្សេងទៀតដែរ ។ ហូឡូខសត៍គឺជាព្រឹត្តិការណ៍ដ៏ស្មុគស្មាញមួយ (ឬស៊េរីនៃព្រឹត្តិការណ៍ច្រើន) ដូច្នេះវាមិនមែនជារឿងងាយស្រួលក្នុងការស្វែងរករឿងរ៉ាវ «ពិត» មួយពីអំពើហូឡូខសត៍ទេ ។ តាមរយៈនេះ ខ្ញុំមានន័យថា ខណៈពេលដែលរឿងរ៉ាវទូទៅពីហូឡូខសត៍បានបង្កើតឡើងហើយ នោះគួរតែមានការសម្រេចថាតើត្រូវរួមបញ្ចូលឬលុបបំបាត់អ្វីខ្លះផងដែរ ។ ជាឧទាហរណ៍ នៅពេលប្រាប់ពីរឿងរ៉ាវហូឡូខសត៍តើគួរតែរួមបញ្ចូលប្រវត្តិសាស្ត្រនៃការប្រកាន់ពូជសាសន៍ជ្វីហច្រើនប៉ុនណា? នៅពេលផ្តល់ការបកស្រាយពីបញ្ហាតើគេត្រូវពិភាក្សាពីសកម្មភាពរបស់ប្រទេស សហគមន៍ ក្រុម ឬបុគ្គលដែរឬទេ? ការមើលទៅនិយមន័យផ្សេងគ្នារបស់ហូឡូខសត៍អាចផ្តល់នូវការបង្ហាញពីបញ្ហាដែលត្រូវប្រឈមមុខប្រសិនបើយើងចង់និយាយពីរឿងរ៉ាវ «ពិត» នៃហូឡូខសត៍ ។

ប្រទេសនីមួយៗគ្រប់គ្រង ឬមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងហូឡូខសត៍ ដូចជាសហគមន៍ផ្សេងៗនៅក្នុងប្រទេសទាំងនេះដែរ ។ ជាលទ្ធផល វាបណ្តាលឲ្យមាន «រឿងរ៉ាវ» ពិតជាច្រើនទាក់ទងនឹងហូសឡូខសត៍ ហើយដែលភាគច្រើននៃរឿងទាំងនោះសុទ្ធតែពិត ប៉ុន្តែក្នុងករណីខ្លះរឿងរ៉ាវនោះមានលក្ខណៈផ្ទុយរឿងរ៉ាវរបស់អ្នកដទៃ ។ ការអភិវឌ្ឍន៍ការស្រាវជ្រាវពីហូឡូខសត៍និងទីតាំងប្រវត្តិសាស្ត្រ រួមជាមួយនឹងការអនុញ្ញាតឲ្យស្វែងរកឯកសារ ភ័ស្តុតាងពីមនុស្សនិងជារូបវន្ត មានន័យថារឿងរ៉ាវ «ពិត» នៃហូឡូខសត៍បានផ្លាស់ប្តូរ កែប្រែ និងពង្រីកតាំងពីឆ្នាំ១៩៨៥ និងបន្តរហូត ។

ជាឧទាហរណ៍ ខណៈពេលដែលមានការពិតដែលថានៅប្រទេសប៉ូឡូញអំពើជួយជនជាតិជ្វីហ្វនឹងទទួលបានទណ្ឌកម្មដោយសម្លាប់ ជាបុគ្គលហើយអាចត្រូវសម្លាប់ជាគ្រួសារ ប៉ុន្តែវាមិនមានករណីបែបនេះនៅបារាំងទេ ។ ការពិតទាំងពីរនេះមិនអាចជះឥទ្ធិពលដល់គ្នាទេ ប៉ុន្តែវាបានផ្តល់ការលំបាកក្នុងការកំណត់រឿងរ៉ាវហូឡូខសត៍ជាក់លាក់មួយ ។ ឧទាហរណ៍មួយទៀតគឺទាហានដែលជាប់ពាក់ព័ន្ធនឹងដំណើរការសម្លាប់រង្គាលដែលបានជួយសង្គ្រោះជីវិតជនជាតិជ្វីហ្វម្នាក់ឬច្រើននាក់ ។ តើយើងអាចថា អូស្កា ឈីនដ្លឺ គឺជាជនដៃដល់ឬជាអ្នកដែលជួយសង្គ្រោះជីវិតមនុស្ស? តើគាត់គឺជាសមាជិកដែលសំខាន់និងមានសិទ្ធិរបស់បក្សណាហ្ស៊ី ដែលបានបង្កើនទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈការប្រើប្រាស់កម្លាំងទាសករ ឬជាអ្នកជួយសង្គ្រោះជនជាតិជ្វីហ្វដែលហ៊ានប្រថុយនឹងគ្រោះថ្នាក់?

ការយល់ឃើញមិនច្បាស់លាស់ទៅលើភាពខ្សោយនៃសក្ខីកម្មរបស់សាក្សីនៅក្នុងហេតុការណ៍បង្ហាញពីបញ្ហានៃការបែងចែកក្រុមនៃ «ការពិត» ហើយដើម្បីបញ្ជាក់ពីការពិត វាមិនតម្រូវឲ្យមានភាពជាក់លាក់នៃប្រវត្តិសាស្ត្រទាំងអស់ទេ ។ ដូរី ឡូប អ្នកវិភាគចិត្តសាស្ត្រនិងអ្នកសម្ភាសន៍អ្នកនៅរស់ពីហូឡូខសត៍នៅក្នុងវីដេអូ នៅក្នុងបណ្ណសារដ្ឋាន ហ្វរឈូនអហ្វរបស់សាកលវិទ្យាល័យយេលបាននិយាយពីការសម្ភាសន៍ជាមួយអ្នកនៅរស់ពី អូសឈ្វីច ដែលនិយាយពីការឃើញបំពង់ផ្សែងបួននៅ បឺខេណូ មានភ្លើងឆេះសន្ធោសន្ធៅ ។ បើតាមប្រវត្តិសាស្ត្រ សក្ខីកម្មនោះគឺមិនត្រឹមត្រូវទេគឺមានតែបំពង់ផ្សែងមួយប៉ុណ្ណោះឆេះ ។ ឡូប បានអះអាងថា ការខូចខាតនៃបំពង់ផ្សែងមួយនៅ បឺខេណូ គឺប្រៀបដូចជាការខូចខាតនៃបំពង់ផ្សែងបួន ។ អ្នកនៅរស់បានរៀបរាប់ពីព្រឹត្តិការណ៍ដែលស្មានមិនដល់គឺការបះបោរប្រដាប់អាវុធរបស់ជនជាតិ ជ្វីហ្វ នៅ អូសឈ្វីច-បឺខេណូ ដែលប៉ះពាល់ដល់រឿងរ៉ាវនៅ អូសឈ្វីច ។ ការពិតជាប្រវត្តិសាស្ត្រនៅក្នុងករណីនេះគឺប៉ះពាល់ដល់រឿងរ៉ាវផ្សេងទៀត ។

**នៅពេលបង្រៀនពីហូឡូខូសត៍ យើងត្រូវតែគិតពីអាយុនិងចំណេះដឹងរបស់អ្នករៀន ។ នៅក្នុងគម្រោងមេរៀនពី អូសឈ្វីច អ្នកចូលរួមមានអាយុលើសពី១៦ឆ្នាំ ប៉ុន្តែភាគច្រើននៃអ្នកទាំងនោះមិនដែលសិក្សាពីហូឡូខសត៍នៅពេលគេមានអាយុ១៣ឬ១៤ឆ្នាំទេ ។ ជាលទ្ធផល ការយល់ដឹងរបស់គេអំពីហូឡូខសត៍ប្រហែលជាសាមញ្ញនិងអាស្រ័យទៅតាមរឿងរ៉ាវនិងការយល់ឃើញខុសៗគ្នា ។**

«ការពិត» អំពីហូឡូខសត៍មិនអាចយកមកបង្ហាញដោយងាយៗបានទេ ហើយនៅក្នុងពេលវេលាមានកំណត់ជាមួយអ្នកចូលរួមក្នុងគម្រោង យើងមិនអាចបកស្រាយឲ្យលម្អិតពីភាពខុសគ្នាដើម្បីបកស្រាយពីរឿងរ៉ាវដ៏ស្មុគស្មាញនៃអំពើប្រល័យពូជសាសន៍ហូឡូខសត៍បានទេ ។ ទោះបីជាយ៉ាងណាក៏ដោយ យើងចាំបាច់ត្រូវតែដឹងពីការពិតទោះបីជាវាតម្រូវឲ្យមានការយល់ដឹងទូទៅនិង

មិនស្មុគស្មាញក៏ដោយ ។ ជាក់ស្តែង គឺនៅពេលបង្ហាញអ្នកចូលរួមនូវភាពខុសគ្នានៃជីវិតរបស់ជនជាតិជ្វីហ្វនៅអឺរ៉ុបមុនពេលមានសង្រ្គាម ។

***តើលោកអាចពិភាក្សាពីសារសំខាន់និងទំនាក់ទំនងនៃពាក្យ «ការចងចាំ» ក្នុងនាមអ្នកជាអ្នកអប់រំនិងជាបុគ្គល?***

ខ្ញុំចាត់ទុក «ការចងចាំ» និង «ការរំឭក» មានទំនាក់ទំនងគ្នា ។ យើងអាចភ្ជាប់ការពិតទៅនឹងការចងចាំពីហូឡូខសត៍ ឬអំពើប្រល័យពូជសាសន៍ផ្សេងទៀត ប៉ុន្តែប្រសិនបើយើងភ្ជាប់ការពិតទៅនឹងការរំឭកនោះការចងចាំនឹងមិនមានតួនាទីអ្វីទេ ។ ការចងចាំគឺជាការមើលទៅក្រោយ និងការសិក្សាពីហូឡូខសត៍ដើម្បីប្រើប្រាស់យុត្តាសាស្ត្រមើលទៅមុខ ។ ការរំឭកមានសារសំខាន់ក្នុងការទទួលស្គាល់បុគ្គល និងសហគមន៍ជាជាងព្រឹត្តិការណ៍ ដូច្នេះអនុញ្ញាតឲ្យយើងសិក្សាពីមេរៀនគឺការសម្លឹងមើលទៅមុខនិងការបត់បែនដើម្បីដោះស្រាយនឹងការមិនអធ្យាស្រ័យគ្នានិង ទស្សនៈមិនសមហេតុផល ។

នៅក្នុងមធ្យោបាយជាច្រើន គម្រោងមេរៀនពីអូសឈ្វីចគឺជាផ្នែកមួយនៃដំណើរការដែលមានជាប់ពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធរវាងការរំឭកនិងការចងចាំ ។ នៅពេលដែលអ្នកចូលរួមអាចចងចាំឈ្មោះជនរងគ្រោះនៅអូសឈ្វីច បឺខេណូ នោះគឺជាសកម្មភាពរំឭក ។ សកម្មភាពបែបនេះអាចត្រូវបានយកមកបង្កើតនិងប្រើប្រាស់ដើម្បីបង្រៀនមេរៀនពីអូសឈ្វីច ។

កុមារី លីបា ដូសថេលនីក កើតនៅឆ្នាំ១៩៣៦ នៅលីបខានី នៃប្រទេសរ៉ូម៉ានី ។ ម្តាយរបស់កុមារីនោះឈ្មោះ ម៉ានា ចំណែកឪពុកឈ្មោះ អូស៊ីហ្វ ។ ទោះបីជាកុមារី លីបា ត្រូវបានសម្លាប់នៅពេលនាងមានអាយុប្រាំឆ្នាំនៅប្រទេសអ៊ុយក្រែនក៏ដោយ ក៏នាងនិងឪពុកម្តាយរបស់នាងគឺជាជនរងគ្រោះដែលត្រូវបានគេបំភ្លេចចោល ។ ក្នុងនាមខ្ញុំជាបុគ្គលម្នាក់ ខ្ញុំចងចាំឈ្មោះកុមារី លីបា នៅក្នុងចិត្តខ្ញុំជានិច្ច ។ ក្នុងនាមខ្ញុំជាអ្នកអប់រំម្នាក់ កុមារី លីបា (ឬបុគ្គលផ្សេងទៀត) អាចជួយឲ្យខ្ញុំបង្ហាញអ្នកដទៃថាលទ្ធផលនៃការមិនអធ្យាស្រ័យគ្នាគឺមិនមែនជារឿងអរូបិយទេ វាបានកើតមានចំពោះមនុស្សពិតដោយមិនគិតពីអាយុ ភេទ ជាតិពន្ធុឬក្រុមផ្សេងទៀត ហើយវាគឺជាអ្វីមួយដែលយើងត្រូវតែផ្លាស់ប្តូរ ។

***តើលោកអាចផ្តល់ឃ្លាមួយ ឬច្រើន ដែលអាចឆ្លុះបញ្ចាំងពីសារសំខាន់នៃការពិតនិងការចងចាំនៅក្នុងសង្គមយើងបច្ចុប្បន្នដែរឬទេ?***

«ការគោរពអាជ្ញាធរដោយមិនបានគិតច្បាស់លាស់គឺជាសត្រូវដ៏ធំបំផុតនៃការពិត» ។ នេះគឺជាពាក្យសម្តីរបស់ អាប៊ឺត អេនស្តេន ។

**វ៉ៃន អានហ្វៀល**

## ដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ទោសមេដឹកនាំខ្មែរក្រហម

មកទល់នឹងពេលបច្ចុប្បន្ន គម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញប្រជាជនមកចូលរួមស្វែងយល់ក្នុងដំណើរការស្វែងរកយុត្តិធម៌នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចំនួនប្រមាណ៦.៩០០នាក់រួចមកហើយ ។ នៅដើមឆ្នាំ២០០៩ គម្រោងឯកសាររស់បានឈានមួយជំហានទៀតក្នុងការផ្តល់ឱកាសឲ្យប្រជាជនចូលរួមដោយផ្ទាល់នៅក្នុងដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហម ។ នៅរៀងរាល់ការបើកសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជានឹងអញ្ជើញអ្នកតំណាងមកពីស្រុកភូមិនានាទូទាំងប្រទេសមកឃ្លាំមើលដំណើរការនេះ ។ បន្ថែមពីលើការចូលរួមស្តាប់សវនាការ អ្នកតំណាងទាំងនោះនឹងបានចូលរួមក្នុងវគ្គបំពាក់បំប៉នដើម្បីទទួលចំណេះដឹងផ្សេងៗទាក់ទងទៅនឹងទ្រង់ទ្រាយនៃតុលាការច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម តួនាទីនៃសហព្រះរាជអាជ្ញាចៅក្រម និងចៅក្រមស៊ើបអង្កេត ភាពខុសគ្នានៃទម្រង់សវនាការព្រមទាំងទស្សនាខ្សែភាពយន្តឯកសារទាក់ទងទៅនឹងរបបខ្មែរក្រហម ។ អាស្រ័យហេតុនេះ ប្រសិនបើអស់លោកអ្នកមានបំណងចូលរួមក្នុងកម្មវិធីសង្កេតមើលសវនាការឬដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ក្តីមេដឹកនាំខ្មែរក្រហម សូមទាក់ទង ស៊ីវ សាវីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០១២ ៦៨៨ ០៤៦ ។ **សូមអរគុណ**

# ក្រដែណោលនៃសង្គ្រាម : នៅតែទន្ទឹងរង់ចាំប្អូនស្រី និងម្ដាយមីង



សឿ សុម៉ាលី ឆ្នាំ២០១១

អ៊ំស្រី សឿ សុម៉ាលី អាយុ៦៤ឆ្នាំ សព្វថ្ងៃរស់នៅភូមិកំពង់ត្របែក ឃុំសណ្ដាន់ ស្រុកសណ្ដាន់ ខេត្តកំពង់ធំបានស្នើសុំមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈក្រុមការងារដែលបានចុះទៅធ្វើវេទិកាសាធារណៈមួយស្ដីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅវត្តទឹកម្លាង ឃុំសណ្ដាន់ ឲ្យជួយស្រាវជ្រាវរកប្អូនស្រី និងម្ដាយមីងដែលបានបែកគ្នាអស់រយៈពេលជិត៤០ឆ្នាំកន្លងមកហើយ ។ អ៊ំស្រី សុម៉ាលី ពុំដែលបានទទួលដំណឹងពីប្អូនស្រី និងម្ដាយមីងរបស់គាត់ទាល់តែសោះ ។ អ៊ំស្រី សុម៉ាលី បានបែកគ្នាជាមួយប្អូនស្រីនិងម្ដាយនិងតាំងពីដើមឆ្នាំ១៩៧០មកម្ល៉េះ ។

ក្នុងពេលផ្ដល់បទសម្ភាសន៍ អ៊ំស្រីបានប្រែទឹកមុខទៅជាស្រពាប់ស្រពោន និងស្រងូតស្រងាត់នៅពេលដែលអ៊ំស្រីរំឭកពីបទពិសោធន៍ជូរចត់ ភាពលំបាកវេទនា និងការបាត់បង់ក្រុមគ្រួសារសាច់ញាតិក្នុងសម័យខ្មែរក្រហម ជាពិសេសម្ដាយមីងនិងប្អូនស្រីដែលបានបែកគ្នាអស់រយៈពេលជាយូរយារណាស់មកហើយដោយសារតែការកែប្រែរបបនយោបាយពីសង្គមមួយទៅសង្គមមួយ ។ លើសពីនេះទៀត អ៊ំស្រីបានរៀបរាប់ទាំងទឹកមុខក្រៀមក្រំពីការដែលខ្មែរក្រហមសម្លាប់បងស្រីជីដូនមួយឈ្មោះសុន្ទរី ក្រោយពេលសម្រាលកូនរួច និងឪពុកមាឈ្មោះ យៀប យុន ជាអតីតចៅហ្វាយស្រុកក្នុងខេត្តស្ទឹងត្រែង ។ អ៊ំស្រីកាន់តែមានអារម្មណ៍ក្តុកក្ដួលថែមទៀត នៅពេលដែលគាត់រំឭកពីប្អូនស្រីតែមួយរបស់គាត់ដែលបានបែកគ្នាតាំងពីនៅវ័យជំទង់ ។

ម្ដាយរបស់អ៊ំស្រីឈ្មោះ យៀប ចាន់ថេប និងឪពុកឈ្មោះ តាន់ ឆេងអ៊ី ហៅ សឿ អ៊ី ជាជាងមាស និងពេទ្យធ្មេញ ។ អ៊ំស្រី សុម៉ាលី ជាកូនច្បងក្នុងគ្រួសារក្នុងចំណោមបងប្អូនស្រីពីរនាក់ ។ អ៊ំស្រី សុម៉ាលី មានស្រុកកំណើតនៅឃុំនិងស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ។ នៅពេលអ៊ំស្រីមានអាយុប្រាំឆ្នាំគ្រួសាររបស់គាត់បានផ្លាស់ទីលំនៅមករស់នៅក្នុងស្រុកសណ្ដាន់ខេត្តកំពង់ធំវិញ ដោយសារតែឪពុករបស់គាត់ជាជាងមាសស្រាប់ហើយដោយឮដំណឹងតៗគ្នាថានៅស្រុកសណ្ដាន់មានរ៉ែមាសមួយកន្លែងនៅភ្នំជីដោយរំពឹងថា មានជីវភាពប្រសើរជាងមុន ។

អ៊ំស្រី សុម៉ាលី បានចូលរៀនថ្នាក់កុមារដ្ឋាននៅឆ្នាំ១៩៥៦ ហើយឈប់រៀនវិញនៅឆ្នាំ១៩៦១ ដើម្បីទៅរៀនអ៊ុតសក់នៅខេត្តកំពង់ចាម ។ បន្ទាប់ពីរៀនចេះចាំរួចមក អ៊ំស្រី បានបើកហាងអ៊ុតសក់មួយនៅទីនោះ ។

នៅឆ្នាំ១៩៦៨ ប្អូនស្រីរបស់គាត់ឈ្មោះ សឿ ណារី មានអាយុ១២ឆ្នាំ ។ នៅពេលនោះ ណារី រៀនថ្នាក់ទី៦នៅសាលាអៀបឃុត នេតយ៉ង់ ខេត្តបាត់ដំបង ។ ណារី បានស្នាក់នៅផ្ទះម្ដាយមីងឈ្មោះ យៀប ម៉ៅ ហៅ ហ៊ុន ដែលមានប្ដីឈ្មោះ នួន សេង ជាមេការសាធារណការខេត្តបាត់ដំបង ។ ហ៊ុន និង សេង មានកូនស្រីម្នាក់ឈ្មោះ នួន ស៊ីថា ។ អ៊ំស្រី សុម៉ាលី និងឪពុកបានទៅលេង ណារី នៅឯខេត្តបាត់ដំបងជាច្រើនដង ។ ក្នុងពេលដែលកំពុងស្នាក់នៅខេត្តបាត់ដំបងជាមួយ ណារី និងក្រុមគ្រួសាររបស់ម្ដាយមីង ស្រាប់តែមានភាពច្របូកច្របល់មួយបានកើតឡើង ។ ឃើញសភាពមិនប្រក្រតី អ៊ំស្រី និងឪពុកបានសម្រេចចិត្តវិលត្រឡប់មកកាន់ស្រុកសណ្ដាន់វិញ ។ ណារី

ស្នាក់ស្មើរក្នុងចិត្ត និងសម្រេចថាមិនវិលត្រឡប់មកជាមួយបងស្រី និងឪពុកក្មេកៗ ទេព្រោះគាត់ត្រូវនៅចាំការប្រឡងបញ្ចប់ថ្នាក់ឌីប្លូមសិន ។



សឿ សុម៉ាលី និង សឿ ណារី ថតក្នុងសម័យសង្គមរាស្ត្រនិយម



សំបុត្រដែល សឿ សុម៉ាលី បម្រុងផ្ញើទៅបងស្រីជីដូនមួយឈ្មោះ សុន្ទរី តែមិនបានផ្ញើ ដោយសារស្រុកកើតសង្គ្រាម

ក្រោយថ្ងៃរដ្ឋប្រហារទម្លាក់សម្តេចសីហនុ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដំណើរការលើវិស័យផ្សេងៗត្រូវបានផ្អាកជាបណ្តោះអាសន្នក្នុងនោះរាប់បញ្ចូលទាំងវិស័យអប់រំផង ។ ណារី ក៏មិនអាចទៅរៀនបានទៀតដែរ ហើយពេលនោះ ណារី ទូរស័ព្ទទៅឪពុកដើម្បីឲ្យគាត់មកទទួលត្រឡប់មកស្រុកសណ្តាន់វិញ ប៉ុន្តែ ឪពុករបស់ ណារី មិនអាចមកទទួលបានឡើយ ព្រោះផ្លូវនានាត្រូវកាត់ផ្តាច់ និងបិទរាល់ការធ្វើដំណើរផ្សេងៗ ។ ពេញមួយរបបសាធារណរដ្ឋខ្មែរពីថ្ងៃទី១៨ មិនា ឆ្នាំ១៩៧០ ដល់ថ្ងៃទី១៦ មេសា ឆ្នាំ១៩៧៥ អ៊ំស្រី សុម៉ាលី និងក្រុមគ្រួសារមិនដែលបានទទួលដំណឹងពី ណារី ទាល់តែសោះ ។ លើសពីនេះទៀត គាត់ក៏ពុំដែលបានឮដំណឹងថាប្អូនស្រីរបស់គាត់រស់នៅទីណាដែរក្នុងរបបខ្មែរក្រហម ។

ក្រោយឆ្នាំ១៩៧៩ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំទៅ អ៊ំស្រីបានបន្តការរស់នៅក្នុងភូមិកំពង់ត្របែក ឃុំសណ្តាន់តទៅទៀត ដោយមិនទៅរស់នៅឯស្រុកកំណើតឯខេត្តស្ទឹងត្រែងវិញឡើយ ។ ប៉ុន្តែ អ៊ំស្រីធ្លាប់បានទៅលេងសាច់ញាតិរបស់គាត់ដែលរស់នៅឯខេត្តស្ទឹងត្រែង កំពង់ចាម និងភ្នំពេញ ដើម្បីសួរពីដំណឹងរបស់ប្អូនស្រី ម្តាយមីង យៀប ម៉ៅ និង យៀប ឡៃ ដែរ ។ រហូតមកដល់ថ្ងៃនេះ ការខិតខំព្យាយាមស៊ើបសួររបស់អ៊ំស្រីនៅតែពុំបានទទួលដំណឹងអ្វីទាល់តែសោះ ។ ទោះជាយ៉ាងនេះក៏ដោយ អ៊ំស្រីនៅតែមានសង្ឃឹមថា គាត់នឹងបានទទួលដំណឹងពីប្អូនស្រី និងម្តាយមីងរបស់គាត់នៅថ្ងៃណាមួយមិនខាន ។

ពេលនេះអ៊ំស្រីកំពុងស្វែងរកប្អូនស្រីនិងម្តាយមីងរបស់អ៊ំស្រី សុម៉ាលី ឈ្មោះ សឿ ណារី, យៀប ឡៃ និង យៀប ម៉ៅ ហៅ ហ៊ុន ។ ប្រសិនបើបងប្អូន ឬមិត្តអ្នកអានបានជួប ឬដឹងឮពីដំណើរជីវិតរបស់អ្នកទាំងបីខាងលើនិងសូមមេត្តាទំនាក់ទំនងផ្ទាល់មកអ៊ំស្រី សុម៉ាលី នៅភូមិកំពង់ត្របែក ឃុំសណ្តាន់ ស្រុកសណ្តាន់ ខេត្តកំពង់ធំ ឬ តាមរយៈឈ្មោះ ម៉ី ជុំចាន់ដារ៉ា ជាកូនប្រុស សព្វថ្ងៃជាគ្រូបង្រៀននៅវិទ្យាល័យហ៊ុនសែនសណ្តាន់ ស្រុកសណ្តាន់ តាមរយៈទូរស័ព្ទលេខ ០៩២ ៧៦១ ៧៩៦ ឬ តាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា០២៣ ២១១ ៨៧៥ ។

**សើ សាយ្យាណា**

# ការជ្រើសរើសពេទ្យនៅក្នុងសម័យខ្មែរក្រហម

នៅរយៈពេលជាងបីឆ្នាំ ខ្មែរក្រហមបានសម្លាប់អ្នកបច្ចេកទេស គ្រូពេទ្យ និងបំផ្លាញថ្នាំ និងបរិក្ខាពេទ្យទំនើបចោល ដោយលើកឡើងថាជារបស់ចក្រពត្តិ ហើយបែរមកជ្រើសរើសការពិសោធន៍ថ្នាំបុរាណ និងក្មេងៗនៅជនបទដែលគ្មានបទពិសោធន៍ និងមានចំណេះដឹងតិចតួច ឬមិនចេះអក្សរមកធ្វើជាគ្រូពេទ្យ អ្នកផលិតថ្នាំពេទ្យ ឬពិសោធន៍ថ្នាំពេទ្យសម្រាប់អ្នកជំងឺទៅវិញ ។ អ៊ុច នៀត និង សោ ហឹយ គឺជាពេទ្យក្នុងរបបខ្មែរក្រហម ។

**អ៊ុច នៀត**

អ៊ុច នៀត អាយុ៦០ឆ្នាំ មានស្រុកកំណើតនៅភូមិកាត់ដៃ ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ ។ នៀត ឈប់រៀនថ្នាក់ ទី៦ (សង្គមចាស់) រួចហើយស្ម័គ្រចិត្តចូលបម្រើជាមួយបដិវត្តន៍ខ្មែរក្រហមតាមរយៈបងប្រុសរបស់គាត់ និងការអំពាវនាវរបស់សម្តេច សីហនុ ឲ្យចូលព្រៃម៉ាគី ទោះបីមានការជំទាស់ពីឪពុកម្តាយក៏ដោយ ។ ដំបូង នៀត ទៅនៅជាមួយកងទ័ពវៀតកុងរយៈពេលមួយខែ ក្រោយមកទើបបងប្រុសរបស់គាត់ដែលធ្វើជាគណៈស្រុកស្នួលទៅយកមកនៅជាមួយចលនាបដិវត្តន៍ខ្មែរក្រហមវិញ ។

នៅឆ្នាំ១៩៧២ នៀត ត្រូវបានអង្គការជ្រើសរើសឲ្យចូលធ្វើពេទ្យនៅឃុំកន្ទួត ។ នៀត រៀនពេទ្យនៅកន្ទួត រហូតដល់ខ្មែរក្រហមវាយយកបានខេត្តក្រចេះឆ្នាំ១៩៧៤ ទើបអង្គការបញ្ជូនគាត់ឲ្យមកនៅខាងផ្នែកស្លថ្នាំនៅមន្ទីរពេទ្យតំបន់ក្នុងក្រុងក្រចេះវិញ ។ នៅទីនោះ នៀត រៀនពីវិធីផលិតថ្នាំពេទ្យពីទ្រូង អណ្តើកថ្លើមជ្រូក និងសុករបស់ស្ត្រីដែលទើបសម្រាលកូនធ្វើជាថ្នាំប៉ូវកម្លាំង និងថ្នាំចាក់ និងរៀនពីរបៀបធ្វើសឺរ៉ូមចេញពីទឹក អំបិល ដោយមានគ្រូពេទ្យជនជាតិចិនម្នាក់ជាអ្នកគ្រប់គ្រងខាងបច្ចេកទេស ។ ក្រោយពីផលិតរួច កងផលិតថ្នាំត្រូវយកថ្នាំទាំងនោះទៅចាក់ពិសោធន៍សាកល្បងលើសត្វជាមុនសិន ។ ប៉ុន្តែថ្ងៃមួយពេលចាក់ថ្នាំឲ្យអ្នកជំងឺរួចក៏បណ្តាលឲ្យអ្នកជំងឺនោះប្រតិកម្មភ្លាមៗ ។ ទោះបីឃើញថ្នាំមិនមានប្រសិទ្ធភាពក៏ដោយ ក៏ខ្មែរក្រហមនៅតែអនុញ្ញាតឲ្យយកថ្នាំទាំងនេះទៅប្រើប្រាស់នៅតាមអង្គភាព និងមន្ទីរក្នុងតំបន់ ។

រៀងរាល់ថ្ងៃ នៀត ត្រូវភ្ញាក់នៅម៉ោងបួនព្រឹកដើម្បីផលិតថ្នាំឲ្យទាន់ផែនការ ដោយមេថ្នាំភាគច្រើនខ្មែរក្រហមយកមកពីប្រទេសចិន ។ ចំណែកចិនបានដឹកយកវត្ថុធាតុដើម និងទ្រូងអណ្តើកជាច្រើនត្រឡប់ទៅប្រទេសគេវិញ ។ ប៉ុន្តែទោះបីជា នៀត ធ្វើការហត់នឿយទៀត មានអាហារហូបគ្រប់គ្រាន់ដែរ ថែមទាំងសល់មួយចំនួនបែងចែកទៅឲ្យមន្ទីរផ្សេងទៀតផង ។ នៅទីនោះ នៀត ឃើញមានមេដឹកនាំខ្មែរក្រហម គណៈប្រតិភូចិន និងបរទេសទៅទស្សនាជាញឹកញាប់ ប៉ុន្តែក៏មិនដឹងថាមកធ្វើអ្វីដែរទេ ។

រហូតដល់កងទ័ពវៀតណាមវាយចូលក្នុងខេត្តក្រចេះនៅចុងខែធ្នូ ឆ្នាំ១៩៧៨ នៀត បានរត់ភៀសខ្លួនទៅនៅ ជាមួយ អ៊ី ឈាន នៅតាមបណ្តោយព្រំដែនខ្មែរថៃ ហើយគាត់ក៏បានចូលបម្រើក្នុងកងដឹកជញ្ជូន ។ នៅឆ្នាំ១៩៨០ អង្គការក៏បានរៀបចំឲ្យ នៀត យកគ្រួសារដែលធ្វើជាយុទ្ធជនមានស្រុកកំណើតនៅខេត្តព្រៃវែង ។ ក្រោយពីរៀបការរួច នៀត និងប្តីក៏ផ្លាស់ទៅរស់នៅសំឡូតក្រោមការគ្រប់គ្រងរបស់ មាស មុត មេបញ្ជាការកងពល ។ នៅទីនោះបានមួយរយៈ ប្តីរបស់ នៀត ក៏ត្រូវគ្រាប់កាំភ្លើងចំស្មាធ្វើឲ្យគាត់ពិការរហូតដល់សព្វថ្ងៃ ។

នៅឆ្នាំ១៩៩៦ មាស មុត បានបញ្ជូនក្រុមគ្រួសារគាត់ឲ្យមករស់នៅឃុំប្រមោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់វិញ ។ ប៉ុន្តែ ដោយសារពេលនោះ មាស មុត ទៅចរចាជាមួយរដ្ឋាភិបាលភ្នំពេញ ទើបខ្មែរក្រហមមួយក្រុមទៀតចូលមកកៀរគ្រួសារ នៀត ទៅរស់នៅជាំក្នុងប្រទេសថៃវិញ ។ នៀត រស់នៅជាំរហូតដល់ខ្មែរក្រហមធ្វើសមាហរណកម្មជាមួយរដ្ឋាភិបាលទើបគាត់មករស់នៅឃុំប្រមោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ។ សព្វថ្ងៃនេះ នៀត បានយកចំណេះដឹងផ្នែកពេទ្យរបស់គាត់សម្រាប់តែព្យាបាល

ក្រុមគ្រួសារគាត់ប៉ុណ្ណោះ ព្រោះគាត់មិនមានសញ្ញាប័ត្រ និងមិនបានរៀននៅសាលាដែលមានការរៀបចំត្រឹមត្រូវទេ ។

នៀត បញ្ជាក់ថា «គាត់ដឹងថាជនរងគ្រោះតែងតែមានអារម្មណ៍ស្មុគស្មាញ និងមិនពេញចិត្តជាមួយខ្មែរក្រហម ប៉ុន្តែចំពោះគាត់ដែលជាអ្នកបដិវត្តន៍ខ្មែរក្រហមត្រូវតែបម្រើឲ្យបដិវត្តន៍» ដោយគាត់លើកឧទាហរណ៍ថា យើងកើតនៅក្នុងគ្រួសារណា យើងត្រូវតែការពារសមាជិកគ្រួសារនោះ និងឪពុកម្តាយ ។ នៀត បន្តថា រហូតមកដល់ពេលនេះគាត់នៅតែនិយាយរឿងរ៉ាវរបស់គាត់ជួបប្រទះ និងឆ្លងកាត់ប្រាប់ដល់កូនរបស់គាត់ និងអ្នកជិតខាងដើម្បីបញ្ជាក់ថារបបខ្មែរក្រហមពិតជាកើតឡើងនៅក្នុងប្រទេសខ្មែរ ។

## សោ ហឹយ


សោ ហឹយ ជាមួយនឹងកូនប្រុស

សោ ហឹយ អាយុ៥២ឆ្នាំរស់នៅស្រុកអង្គរជុំ ខេត្តសៀមរាប ។ ហឹយ ជាកូនទីពីរក្នុងចំណោមបងប្អូនប្រាំមួយនាក់ ។ ហឹយ រៀននៅសាលាវត្តរយៈពេលមួយឆ្នាំក៏ឈប់រៀន ដោយសារមូលហេតុគាត់ទៅរៀនយឺត ហើយម្យ៉ាងទៀតខ្លាចគ្រូវាយធ្វើបាប ។ ក្រោយពីឈប់រៀនមក ហឹយ មកជួយកិនស្រូវឪពុកម្តាយ និងការងារផ្សេងៗនៅផ្ទះវិញ ។

នៅឆ្នាំ១៩៧២ ហឹយ បានស្ម័គ្រចិត្ត ចូលបម្រើបដិវត្តន៍ ដោយដំបូងគាត់នៅខាងកងសិល្បៈស្រុកអង្គរជុំ ។ នៅពេលនោះ ហឹយ និងក្រុមសិល្បៈទាំងអស់ត្រូវចេញទៅហ្វឹកហាត់សម្តែងពីការធ្វើបាតុកម្មប្រឆាំងនឹងរបប លន់ នល់ នៅក្នុងភូមិព្រៃរំដួល ។ រៀងរាល់ថ្ងៃ ហឹយ ត្រូវហ្វឹកហាត់រហូតដល់ម៉ោង១១យប់ទើបឈប់សម្រាក ប៉ុន្តែដោយសារមានចំណង់ចំណូលចិត្តខាងសិល្បៈទើបគាត់ឆាប់ចេះ និងសម្តែងបានល្អ ។ ក្រោយពីហ្វឹកហាត់ចប់ ហឹយ ប្រឡងជាប់ក្នុងកងសិល្បៈភូមិភាគឧត្តរមានទីតាំងស្ថិតនៅក្នុងព្រៃដូនអែម ស្រុកវ៉ារិន ដែលមានសមមិត្ត សេង ជាអ្នកគ្រប់គ្រង ។ នៅទីនោះ ហឹយ បានចេញទៅសម្តែងនៅក្នុងតំបន់រំដោះ និងនៅសមរភូមិផ្សេងៗឲ្យកងទ័ពទស្សនា ។

ក្រោយពីកងទ័ពខ្មែរក្រហមរំដោះបានប្រទេសកម្ពុជាឆ្នាំ១៩៧៥ អង្គការបានជ្រើសរើស ហឹយ ពីខាងកងសិល្បៈមកចូលធ្វើពេទ្យតំបន់៥ (បច្ចុប្បន្នអនុវិទ្យាល័យស្វាយស៊ីសុផុន) ដោយមានឈ្មោះ គឿន និងឈ្មោះ ថៃ ជាអ្នកគ្រប់គ្រង ។ ដំបូងប្រធានពេទ្យឲ្យ ហឹយ ធ្វើការនៅផ្នែកជំងឺទូទៅ ប៉ុន្តែដោយសារគាត់ខ្លាចដំបៅនិងឈាមរបស់អ្នកជំងឺទើបសុំផ្លាស់ទៅធ្វើការនៅផ្នែកឆ្មបវិញ ។ នៅទីនោះ ហឹយ មិនបានចូលរៀនទេ គឺគាត់ត្រូវទៅបង្កើតកូនតែម្តង ដោយមានគ្រូពេទ្យនៅទីនោះចាំត្រួតពិនិត្យមើលផ្ទាល់ ។ ជារឿយៗ ហឹយ តែងតែទទួលការគំរាមពីអ្នកត្រួតពិនិត្យ នៅពេលធ្វើការមិនបានប្រុងប្រយ័ត្ន ឬមិនហ៊ានប៉ះពាល់អ្នកជំងឺ ។ ប៉ុន្តែប្រសិនបើមានអ្នកជំងឺធ្ងន់ធ្ងរ គ្រូពេទ្យត្រូវបញ្ជូនបន្តទៅព្យាបាលនៅមន្ទីរពេទ្យនៅស្រុកមង្គលបុរីវិញ ។

ក្រោពីការងារឆ្មប ប្រធានពេទ្យឈ្មោះ គឿន និង ថៃ បានចាត់តាំង ហឹយ ឲ្យដឹកកង់យកថ្នាំពេទ្យទៅចែកឲ្យពេទ្យសហករណ៍នៅទំបន់អាងត្រពាំងថ្ម ដែលនៅទីនោះគាត់បានស្តាប់ពេទ្យសហករណ៍ ត្អូញត្អែរពីការខ្វះខាតថ្នាំសង្កូវ និងមានអ្នកជំងឺចូលមកព្យាបាលកាន់តែច្រើន និងប្រជាជនស្លាប់ជាបន្តបន្ទាប់ ។ នៅពេលនេះគណៈស្រុកថ្មី អ៊ឹម ចែម ចូលមកនៅឆ្នាំ១៩៧៨ មានការចាប់ខ្លួនប្រធានពេទ្យតំបន់៥ ជាល ប្រធានអង្គការ (នារីយុទ្ធជន) អេត (អនុអង្គការនារីយុទ្ធជន) ហឹង (គណតំបន់) មង (គណៈស្រុក) វ៉ាល់, តាញឹម និង ចាប់ឪពុករបស់គាត់ដោយចោទថាជាប់ខ្សែជាមួយ លន់ នល់ ។ ចំណែក ហឹយ ត្រូវបានចាប់យកទៅដាក់គុក រហូតមកដល់កងទ័ពវៀតណាមចូលមករំដោះនៅឆ្នាំ១៩៧៩ ។ ប៉ុន្តែថ្ងៃមួយមិត្តភក្តិរបស់ ហឹយ ក៏មកលួងលោម ហឹយ ទៅរស់នៅ

ជាមួយខ្មែរក្រហម ។ ពេលនោះ គាត់ក៏យល់ព្រម រួចរត់ទៅរស់នៅតំបន់ជប់ និងត្រាង ក្នុងខេត្តឧត្តរមានជ័យ ដោយគាត់នៅខាងជីកជញ្ជូន ។ ក្រោយមកខ្មែរក្រហមបញ្ជូន ហ៊ីយ ឆ្លងកាត់តាមទឹកដីថៃមករស់នៅផ្សារម៉ាឡៃខេត្តបន្ទាយមានជ័យ ។

ហ៊ីយ បញ្ជាក់ថា «សព្វថ្ងៃគាត់មិនហ៊ានយកចំណេះដឹងរបស់គាត់ទៅជួយអ្នកភូមិទេ ព្រោះគាត់មិនបានរៀននៅសាលា និងគ្មានសញ្ញាប័ត្រ» ។

នៀត និង ហ៊ីយ បានចំណាយពេលយ៉ាងច្រើនដើម្បីសិក្សារៀនសូត្រផ្នែកពេទ្យនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែក្រោយពីរបបនេះដួលរលំទៅ នៀត និង ហ៊ីយ មិនបានយកចំណេះដឹងទាំងនេះទៅអនុវត្ត ឬព្យាបាលអ្នកជំងឺទេ ដោយសារគាត់ទាំងពីរនាក់មិនបានរៀនសូត្រនៅសាលាដែលមានការរៀបចំត្រឹមត្រូវ ។

ទោះបីខ្មែរក្រហមមានបំណងចង់ឲ្យផ្នែកសុខាភិបាលមានការលូតលាស់ក៏ដោយ ក៏ការជ្រើសក្មេងៗដែលមានចំណេះដឹងតិចតួចឲ្យមករៀនពិសោធន៍ និងអនុវត្តន៍ជំនាញពេទ្យផ្ទាល់បានធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងទៅលើផ្នែកសីលធម៌ វេជ្ជសាស្ត្រ និងអាយុជីវិតរបស់អ្នកជំងឺ ។ **សោម ប៊ុនថន**

# ស្វែងរកឪពុកមា

នាងខ្ញុំឈ្មោះ អ៊ុច នៀត ហៅ អ៊ុច នុង អាយុ៦០ឆ្នាំ បច្ចុប្បន្នរស់នៅឃុំប្រមោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ។ នាងខ្ញុំសូមប្រកាសស្វែររកឪពុកមាឈ្មោះ អ៊ឹ ឈុំ និងប្រពន្ធឈ្មោះ វីរ ។ អ៊ឹ ឈុំ មានកូនទាំងអស់៧នាក់គឺ ទី១) អ៊ឹ វ៉ាន់ នឿន ២) អ៊ឹ វ៉ាន់នី ៣) អ៊ឹ អង្គារី ៤) អ៊ឹ វុទ្ធី ៥) អ៊ឹ រិទ្ធី ៦) អ៊ឹ ចាន់ សុណា ហៅ ម៉េប និងទី៧) អ៊ឹ ចាន់ដាកានី ។ នៅឆ្នាំ១៩៧០ ឈុំ និងក្រុមគ្រួសារបានទៅរស់នៅស្រុកកំណើតខ្ញុំនៅភូមិកាត់ដៃ ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ ដោយពេលនោះម្តាយខ្ញុំបានទៅសុំក្រសួងឲ្យគាត់ធ្វើជាអ្នកបើកឡានពេទ្យ ។ ក្រោយមក ដោយសារតែមានជីវភាពខ្វះខាត នៅឆ្នាំ១៩៧២ ឈុំ បាននាំក្រុមគ្រួសារត្រឡប់មករស់នៅជាមួយបងរបស់គាត់នៅម្តុំផ្សារអូឡាំពិក (ចាស់) ភ្នំពេញវិញ ។

ចាប់តាំងពីឆ្នាំ១៩៧៥មក ខ្ញុំបាត់ដំណឹងគាត់រហូតដោយមិនដឹងថាខ្មែរក្រហមជម្លៀសទៅទីណាទេ ។ ប្រសិនបើបងប្អូនណាបានស្គាល់ឈ្មោះ ឬឮដំណឹងនេះ សូមមេត្តាទាក់ទងមកអាសយដ្ឋានរបស់នាងខ្ញុំដូចបានរៀបរាប់ខាងលើ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ឬទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ ***សូមអរគុណ***

# ស្វែងរកស្វាមីឈ្មោះ មូល វង្សបណ្ឌិត ហៅ ណោង


មាន គុណ

នាងខ្ញុំឈ្មោះ មាន គុណ សព្វថ្ងៃរស់នៅភូមិព្រែកទំលាប់ ឃុំព្រែកទំលាប់ ស្រុកលើកដែក ខេត្តកណ្តាល ។ នៅឆ្នាំ១៩៧៨ យើងរស់នៅខេត្តពោធិ៍សាត់ ហើយពេលនោះក្រុម ប៉ុល ពត តម្រូវឲ្យយើងបែកគ្នាដោយបញ្ជូនខ្ញុំនិងកូនស្រីខ្ញុំឈ្មោះ ណោង ក្រវ៉ាន់ ទៅភ្នំក្តោក ចំណែកឯប្តីខ្ញុំនៅភូមិព្រៃផ្តៅប ។ តាំងពីពេលនោះមក នាងខ្ញុំមិនដែលបានជួបគាត់សោះ មិនដឹងថាគាត់នៅរស់ឬក៏ក្រុម ប៉ុល ពត យកគាត់ទៅឯណាទេ ។ ប្រសិនបើប្អូនឃើញឬស្គាល់ប្តីនាងខ្ញុំឈ្មោះ មូល វង្សបណ្ឌិត ហៅ ណោង ។ សូមទំនាក់ទំនងមកនាងខ្ញុំតាមទូរស័ព្ទលេខ ០១១ ៦២០ ៧៩៩ ឬផ្ទះលេខ១ ផ្លូវ៥៤២ សង្កាត់ទួលគោក១ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិត នៅក្នុងរបបខ្មែរក្រហម ។ កន្លងមកមជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាងមួយលាននាក់រួចមក ហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាន នៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល : truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់ ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់ ៤) ភេទអ្នកស្លាប់ ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន) ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ : ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី) ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ : ស្លាប់នៅទីណា? មូលហេតុអ្វី?) ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ : រូបថត ឯកសារ ឬវត្ថុ ផ្សេងៗ) ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ : លេខទូរស័ព្ទ អាសយដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន ២) ភេទ ៣) អាយុ ៤) ត្រូវជាអ្វី ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ : រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។




ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុយអែត និងសហរដ្ឋអាមេរិក

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 136, April 2011 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.